ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2016, 15:05
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលពីរ**

**សាធារណៈ-កោសល្យ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៣៥៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ាយ

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អ៊ីសាប៊ែល ឌុយរ៉ង់ដ៍

*(Ms. Isabelle DURAND)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

សាធារណៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ប្រាក់ យុត (2-TCW-938) | ខ្មែរ |

សម្ងាត់

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោកស្រី ប្រាក់ យុត** (2-TCW-938)

សួរបន្តដោយលោក ខេល លីសាក់ ផ្ដើមពី ............................................................ ទំព័រ ៤

សួរដោយលោក ពេជ អង្គ ផ្ដើមពី ............................................................ ទំព័រ ៥៥

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ............................................................ ទំព័រ ៦៣

# កិច្ចដំណើរការនីតិវិធី

[០៩:០៣:២០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការជាអសាធារណៈបន្តស្តាប់សក្ខីកម្មសាក្សី ប្រាក់ យុត។

ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ លើកលែងតែសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអន្តរជាតិ លោកស្រី ម៉ារី ហ្គីរ៉ូដ៍ អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺ ប្រាក់ យុត។ លោកស្រី និងមេធាវី ប្រឹក្សារបស់លោកស្រីមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការសវនាការនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៥:១០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាដំបូងនេះ អង្គជំនុំជម្រះ សម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធ-

ភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦។ បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាព សុខភាពរបស់ជនជាប់ចោទ នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺខ្នង វិលមុខជាប្រចាំ ជាពិសេសនៅពេលអង្គុយ និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៦:៣០]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញលោករិចទ័រ កូប៉េ!

**លោក រិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។ ការដែលខ្ញុំក្រោយឈរនេះគឺថាសំណើសុំរបស់ខ្ញុំក៏ខ្ញុំយល់ថាមានប្រយោជន៍ដល់ភាគដទៃដែរ។ អង្គជំនុំជម្រះគឺថាបានផ្តល់ពេលវេលាឲ្យភាគីទាំងអស់តែមួយថ្ងៃកន្លះដើម្បីសាកសួរសាក្សីរូបនេះព្រឹកមិញនេះ ខ្ញុំបានបញ្ចប់ការរៀបចំការតាំងសំណួររបស់ខ្ញុំចំពោះសាក្សីរូបនោះ។ ខ្ញុំយល់ឃើញថា ខ្ញុំត្រូវការពេលវេលាច្រើនបន្ថែមទៀតដើម្បីសួរសាក្សីរូបនេះ យើងខ្ញុំមានមួយវគ្គកន្លះ ប៉ុន្តែនៅវគ្គទី២នេះ តែកន្លះវគ្គនេះ គឺថាខ្ញុំមិនគ្រប់ សួរមិនបានគ្រប់គ្រាន់ទេ។ ដូច្នេះយើងខ្ញុំសូមឲ្យពិចារណាទៅលើពេលវេលាដែលបានចែកជូនមួយថ្ងៃកន្លះនេះវិញ។

[០៩:០៨:១៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកត្រូវការពេលប្រហែលជាប៉ុន្មានស្មានៗទៅ?

**លោក វ៉ិចទ័រ កូប៉េ៖**

យើងខ្ញុំយល់ឃើញថាពីរថ្ងៃជាពេលវេលាសមហេតុផល។ ខ្ញុំ ក្រុមយើងខ្ញុំ សម្រាប់តែក្រុមយើងខ្ញុំៗមិនដឹងទេសម្រាប់ក្រុម ខៀវ សំផន គឺខ្ញុំត្រូវការបីវគ្គ។ បាទ អ៊ីចឹង ដូច្នេះពេលវេលាដែលបានបែងចែកនេះគឺថាមិនគ្រប់គ្រាន់សម្រាប់ការតាំងសំណួរពីសំណាកក្រុមយើងខ្ញុំទេ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញសហមេធាវីការពារក្តីខៀវ សំផន!

[០៩:០៨:៥៦]

**កញ្ញា អង់តា ហ្គីសសេះ៖**

សូមអរគុណលោកប្រធាន។ ចំពោះខ្ញុំមិនដូចខាងមេធាវី កូប៉េ ទេ។ យើងមិនត្រូវការដល់បីវគ្គៗទេ [redacted] ខ្ញុំគិតថាបីវគ្គសម្រាប់ក្រុមទាំងពីរហ្នឹងគឺវាខ្លីពេក អ៊ីចឹងគួរតែបន្ថែមមួយវគ្គបន្ថែមទៀតទៅ ប្រហែលជាបួនវគ្គសម្រាប់យើងទាំងពីរ។ ក៏ប៉ុន្តែខ្ញុំមិនដឹងថាជំហរសហព្រះរាជអាជ្ញា និងតំណាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងម៉េចទេចំពោះបញ្ហានេះ ក៏ប៉ុន្តែយើងឃើញថាចម្លើយរបស់សាក្សីពីមុនៗហ្នឹង មានច្រើនណាស់ អ៊ីចឹងមួយថ្ងៃកន្លះសម្រាប់សាក្សីរូបនេះហ្នឹងគឺវាមិនគ្រប់គ្រាន់ទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ឃើញថាផ្នែកមួយដែលយើងខ្ញុំក៏យល់ស្របជាមួយនឹងភាគីដទៃដែរ នោះគឺថាមិនមែនដោយសារតែសារៈសំខាន់នៃសាក្សីរូបនេះទេ។ ខ្ញុំអាចជម្រាបជូនអង្គជំនុំជម្រះថា កាលពីម្សិលមិញនោះ គឺមានការជំទាស់តវ៉ា មានការរំខាន ហើយក៏ដូចជាការឆ្លើយយ៉ាងវែងៗរបស់សាក្សី។ ហើយខ្ញុំមានពេលវេលាកាលពីម្សិលមិញ ដោយសារតែសារៈសំខាន់នៃសាក្សីរូបនេះ ក៏ដូចជាកំណត់ហេតុស្តាប់ចម្លើយ ក៏វាមានច្រើន យើងខ្ញុំយល់ឃើញថាថ្ងៃនេះ នឹងមិនមានការរំខានច្រើនទេ ប៉ុន្តែយើងខ្ញុំស្នើសុំរយៈពេលពីរថ្ងៃពេញតែម្តង។ មួយថ្ងៃសម្រាប់ៗមេធាវី -- សម្រាប់សហព្រះរាជ

អាជ្ញា និងមួយថ្ងៃសម្រាប់មេធាវីការពារក្តី។

**ប្រធានអង្គជំនុំ៖**

ម៉េចដែរ ខាងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សម្រាប់ខាងយើងខ្ញុំ យើងខ្ញុំត្រូវការរយៈពេលប្រហែលជា៣៥ នាទីទេ។

[០៩:១១:២៨]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១២:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះ សម្រេចយល់ព្រមតាមសំណើសុំរបស់ភាគី គឺមួយភាគី សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយថ្ងៃ ហើយភាគីការពារក្តីមានរយៈពេលមួយថ្ងៃក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ អ៊ីចឹង គឺបន្ថែមលើពេលវេលាដែលបានបែងចែករួចហើយហ្នឹង គឺមួយវគ្គ មួយភាគីបន្ថែមទៀត។ មួយភាគីហ្នឹង គឺភាគីខាងចោទ ហើយនិងភាគីខាងការពារ។

សូមអញ្ជើញ សហព្រះរាជអាជ្ញារងអន្តរជាតិ អញ្ជើញបន្តការកិច្ចការរបស់លោក។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** អរុណសួស្តីលោកស្រីសាក្សី។ កាលពីម្សិលមិញ យើងនិយាយអំពីពេលវេលាដែលលោកស្រីបានទទួលបញ្ជាពីកិច្ចប្រជុំរបស់ថ្នាក់តំបន់។ ខ្ញុំសូមចូលទៅបន្តកំណត់ត្រារបស់ខ្ញុំដែលត្រូវសួរលោកស្រី ពាក់ព័ន្ធទៅនឹងសំណួរទូទៅដែលខ្ញុំបានសួរលោកស្រី អំពីជនជាតិចាម នៅក្នុងស្រុកកំពង់សៀម។ លោកស្រីបានឆ្លើយថា ដកស្រង់៖ "នៅក្នុងឆ្នាំ១៩៧៧ គឺមានបញ្ជាចេញមកពីថ្នាក់តំបន់ ដើម្បីឲ្យបោសសម្អាតចាម"។ តើពេលដែលលោកស្រីទទួលបញ្ជាឲ្យបោសសម្អាតហ្នឹង នៅក្នុងឆ្នាំ១៩៧៧ឬ? លោក

ស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ចាប់ពីដើមដំបូងដែលពេលលោកស្រីទៅដល់ ឬក៏ពាក់កណ្ដាលឆ្នាំ ឬក៏ថានៅចុងឆ្នាំ១៩៧៧ទៅហើយ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមជម្រាបអំពីការបោសសម្អាតចាម។ នៅពាក់កណ្ដាល ខ្ញុំចូលទៅ មិនទាន់បានធ្វើទេ នៅពាក់កណ្ដាល -- នៅប្រហែលជាចុងឆ្នាំ។ ហេតុនេះការធ្វើជាមួយ ពូអាន នេះ ខ្ញុំគ្រាន់តែស្រង់បញ្ជីបញ្ជូនឱ្យគាត់ ក្នុងការធ្វើបញ្ជីចាម អត់មានធ្វើអីច្រើនទេ។ ហើយខ្ញុំបានធ្វើបញ្ជីឱ្យគាត់ហើយ ខ្ញុំរាយ-ការណ៍ឱ្យគាត់តែម្ដង នៅពាក់កណ្ដាល -- នៅចុងឆ្នាំ។

[០៩:១៥:១២]

**ស៖** អរគុណលោកស្រីសាក្សី។ ម្សិលមិញលោកស្រីបានជម្រាបជូនតុលាការថា ក្រោយពីទទួលបានបញ្ជានេះ លោកស្រីបានបញ្ជូនទៅថ្នាក់ក្រោមកូនចៅរបស់លោកស្រីឱ្យអនុវត្តបទបញ្ជានេះ។ តើថ្នាក់ក្រោម ឬក៏កូនចៅរបស់លោកស្រីនេះ តើជាអ្នកណាខ្លះ? ហើយអ្នកណាជាអ្នករៀបចំបញ្ជីឈ្មោះជនជាតិចាមទាំងនេះ?

**ឆ៖** ខ្ញុំសូមជម្រាប អ្នករៀបចំឈ្មោះបញ្ជីចាមទាំងនេះគឺ ក្នុងហ្នឹងមានអនុប្រធានស្រុកគឺឈ្មោះ ស៊ី។ ខ្ញុំមិនបានធ្វើខ្លួនឯងទេ គឺគាត់បានចុះទៅខាងក្រោម គឺឱ្យខាងក្រោមធ្វើ។

**ស៖** តើអនុប្រធានរបស់លោកស្រីឈ្មោះ ស៊ី មកពីណា? តើគាត់ជាកម្មាភិបាលមកពីភូមិភាគនិរតីដែលត្រូវទៅធ្វើការនៅភូមិភាគកណ្ដាល នៅមុំពេលដែលលោកស្រីទៅហ្នឹងដែរ ដូចគ្នាហ្នឹងដែរ ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំសូមជម្រាប លោកស៊ី គឺគាត់នៅខេត្តតាកែវ តែខ្ញុំទៅដល់ឃើញគាត់នៅហ្នឹងមុន។ ខ្ញុំមិនដឹងថាគាត់ទៅពីថ្ងៃណាទេ។

**ស៖** លោកស្រីខ្លួនឯងកើតនៅស្រុកត្រាំកក់។ តើ ស៊ី មកពីស្រុកត្រាំកក់ដែរឬក៏អត់ទេ?

**ឆ៖** លោក ស៊ី គាត់មកពី -- ខ្ញុំក៏មិនបានស្គាល់គាត់ច្បាស់ថា ស្រុកត្រាំកក់ ឬក៏ស្រុកណាទេ គ្រាន់តែឃើញថាគាត់នៅតាកែវដែរ ប៉ុន្តែខ្ញុំក៏មិនចាំថាគាត់នៅស្រុកតាំកក់ ឬក៏នៅស្រុកណាក៏ខ្ញុំអត់ច្បាស់ដែរ ព្រោះខ្ញុំទៅក្រោយគាត់។ គាត់នៅតាកែវដូចគ្នា តែស្រុកខ្ញុំក៏អត់ច្បាស់។

**ស៖** តើមានបុគ្គលម្នាក់ឈ្មោះ ណាន ដែលជាសមាជិកគណៈស្រុកជាមួយលោកស្រីដែរ ហើយតើឈ្មោះ ណាន នេះឬដែលជាអ្នកអនុវត្តបទបញ្ជាហ្នឹង?

[០៩:១៨:១៣]

**ផ៖** ខ្ញុំសូមជម្រាប ឈ្មោះ ណន នេះគាត់នៅក្នុងស្រុកកំពង់សៀមមែន តែខ្ញុំទៅដល់វាឃើញគាត់នៅហ្នឹងជាមួយ ពូស៊ី តែខ្ញុំក៏បានរៀបរយគាត់ឱ្យធ្វើប្រធានមន្ទីរស្រុក។ គាត់អត់បានយកបញ្ហា -- អត់មានធ្វើខាងហ្នឹងទេ គាត់ខាងប្រធានមន្ទីរស្រុក ដូចថារៀបរយខាងការរាយការណ៍ រៀបរយខាងនៅក្នុងស្រុក។ តែការដែលខ្ញុំឱ្យធ្វើគឺ ពូស៊ី ទាំងអស់។ បើចំពោះ ណន នេះគាត់មិនបានធ្វើទេ គាត់គ្រាន់ថាដឹងឮនៅក្នុងស្រុក។ នេះខ្ញុំសូមជម្រាប គាត់ប្រធានរបស់ខ្ញុំ ដូចថាខ្ញុំហ្នឹងការចេះអក្សរក៏វាតិចតួចអ៊ីចឹងខ្ញុំយកឱ្យគាត់ធ្វើប្រធាន ដើម្បីជួយរាយការណ៍គ្រប់បញ្ហានៅក្នុងស្រុក។

**ស៖** តើលោកស្រីស្គាល់នារីម្នាក់ឈ្មោះ វ៉ាន់? ហើយតើ វ៉ាន់ នេះគឺជានារីដែលលោកស្រីយកទៅឱ្យធ្វើការជាមួយលោកស្រី យកពីភូមិភាគនិរតី ទៅធ្វើការជាមួយលោកស្រីនៅភូមិភាគកណ្ដាលនោះឬ?

**ផ៖** ឈ្មោះ វ៉ាន់។ ទៅ គាត់មិនដឹងទៅជាមួយខាងណា ប៉ុនខ្ញុំទៅដល់ស្រុកហ្នឹង ឃើញឈ្មោះ វ៉ាន់ ហ្នឹងនៅមន្ទីរស្រុកហ្នឹងដែរ តែខ្ញុំក៏ឱ្យគាត់ធ្វើការជាមួយខ្ញុំពិតប្រាកដ។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានទេ ពេលនៅស្រុកកំពង់សៀមហ្នឹង វ៉ាន់ មានតួនាទីអ្វីដែរ?

**ផ៖** សូមជម្រាបកាលនៅស្រុកកំពង់សៀម ខ្ញុំបានរៀបរយ តែខ្ញុំក៏ភ្លេចថា មិនដឹងឱ្យនៅឃុំណា ភូមិណា -- ឃុំណា ខ្ញុំអត់ច្បាស់ដែរ មកដល់ថ្ងៃនេះ គឺវាភ្លេច មិនដឹងថា លោកស្រី វ៉ាន់ ហ្នឹងនៅឃុំណា។ តែបានរៀបរយហើយ តែមិនដឹងនៅឃុំណា វាអត់ច្បាស់ វាភ្លេច។

[០៩:២០:៤៩]

**ស៖** ខ្ញុំសូមជួយរំឭកការចងចាំរបស់លោកស្រីបន្តិច។ វ៉ាន់ បានមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយបានរៀបរាប់ជូនតុលាការអំពីតួនាទីមួយចំនួន ដែលដំបូងរៀបរាប់តាំងពីតួនាទីជានីរសារ ហើយគាត់ក៏ប្រធានកងចល័តស្រុក ហើយបន្ទាប់មកទៀត ហើយក៏តែងតាំងទៅជាសមាជិកគណៈឃុំរអាង ក្រោយមកគឺតែងតាំងតួនាទីមួយទៀត គឺសមាជិកគណៈកម្មាធិការ ឃុំរអាង។ តើអ៊ីចឹងមែនទេ?

**ផ៖** ចាស ពិត។

**ស៖** [redacted]

[redacted]

ឆ៖ [redacted]

[០៩:២៣:០០]

សៈ ម្សិលមិញលោកស្រីបានឆ្លើយថា លោកស្រីបានទទួលបញ្ជាពីថ្នាក់តំបន់ ដើម្បីបោសសម្អាតជនជាតិចាម។ ក្នុងឋានៈជាលេខាស្រុក តើលោកស្រីមានសិទ្ធិអំណាច ឬក៏មានឆន្ទានុសិទ្ធិ សិទ្ធិអំណាចអ្វីមួយសម្រេចឲ្យចាប់ខ្លួនជនជាតិចាម និងសម្លាប់ជនជាតិចាមទាំងអស់ចោលដែរទេ?

ឆ៖ ខ្ញុំសូមមានមតិ ក្នុងនេះខ្ញុំជា សិទ្ធិជាចៅហ្វាយស្រុក នៅក្នុងស្រុកកំពង់សៀមទាំងមូល។ តែការបោសសម្អាតចាមទាំងអស់នេះ ខ្ញុំក៏មិនមានសិទ្ធិធ្វើម្នាក់ឯង អត់មានខាងលើសម្រេច គឺខ្ញុំអត់ធ្វើអ៊ីចឹង។ នេះខ្ញុំសូមជម្រាប ព្រោះខ្ញុំជាចៅហ្វាយ ប៉ុន្តែមិន -- ព្រោះអានេះជាជីវិតរបស់មនុស្ស បើខ្ញុំយកខ្លួនខ្ញុំទៅពាំងថាចាប់ ខាងលើអត់ដឹង ក៏ខ្ញុំអត់ហ៊ានធ្វើដែរ។ ទាល់តែមានការសម្រេចពីខាងលើអីអ៊ីចឹង ខ្ញុំនឹងធ្វើតាមខាងលើ។

សៈ [redacted]

ឆ៖ [redacted]

[០៩:២៥:៤៥]

សៈ [redacted]

[redacted]

ឆ៖ [redacted]

ស៖ [redacted]

[០៩:២៩:២៥]

ឆ៖ [redacted]

ស៖ ជនជាតិចាមដែលថ្នាក់ស្រុកបានបញ្ជាឲ្យចាប់និងសម្លាប់ ថាតើជនជាតិចាមទាំងហ្នឹងមានបង្កបញ្ហាអ្វីមួយ ឬក៏ជំទាស់រារាំងប្រឆាំងនឹងអ្វីមួយដែលនាំឲ្យឈានទៅដល់ការចាប់ខ្លួន និង សម្លាប់នេះទេ?

ឆ៖ ជនជាតិចាមទាំងអស់នៅស្រុកកំពង់សៀម ទោះបីបញ្ជាមកខាងលើពិតប្រាកដមែន តែ

ការពិនិត្យពិច័យរបស់ខ្ញុំនៅក្នុងស្រុកកំពង់សៀម ក៏មិនចេះតែខុសដៃយកដៃ ខុសជើងយកជើង គឺខ្ញុំបានពិនិត្យពិច័យអ្នកខុស អ្នកត្រូវដែរនៅក្នុងស្រុក ដូចថា ខ្លះក៏អត់មានការប្រឆាំងអីក៏ ខ្លះក៏មានការប្រឆាំង។ នេះខ្ញុំសូមជម្រាប។ ហេតុនេះ ការចាប់ ការចងនេះ មុននឹងចាប់ក៏ខ្ញុំពិនិត្យពិច័យច្បាស់លាស់ដែរ ព្រោះថា អ្នកណាក៏ល្អ ខ្លះក៏អាក្រក់ ខ្លះក៏ល្អ មិនមែនអាក្រក់ទាំងអស់ ហើយក៏មិនមែនល្អទាំងអស់។

**ស៖** លោកស្រីសាក្សី ប៉ុន្មាននាទីមុននេះ ខ្ញុំបានសួរថា តើលោកស្រីក្នុងនាមជាលេខាស្រុក តើលោកស្រីមានសិទ្ធិអំណាចក្នុងសម្រេច ថាតើត្រូវចាប់ជនជាតិចាមណា ឬក៏អត់នោះទេ? ហើយលោកស្រីឆ្លើយថាអត់ទេ ប៉ុន្តែឥឡូវនេះ លោកស្រីឆ្លើយថា លោកស្រីក្នុងនាមជាមេស្រុក ជាអ្នកសម្រេចថាតើត្រូវចាប់ជនជាតិចាមណា ហើយនិងសម្លាប់ជនជាតិចាមណា។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំស្តាប់អត់ច្បាស់។

[០៩:៣២:៥០]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងអន្តរជាតិតាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្តងទៀតចំពោះសាក្សី!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ខ្ញុំសួរមុននេះបន្តិច លោក -- ខ្ញុំសួរថា ថាតើលោកស្រីក្នុងនាមជាលេខាស្រុក តើលោកស្រីទទួលខុសត្រូវតាមបញ្ជាហ្នឹង ថាតើក្នុងការចាប់ខ្លួន និងសម្លាប់ ឬជនជាតិចាម ឬក៏អត់? ហើយលោកស្រីឆ្លើយថាអត់ទេ។ ប៉ុន្តែខ្ញុំចង់សួថា ឥឡូវនេះ ក្នុងនាមជាលោកស្រី ៗជាលេខាស្រុក តើលោកស្រីជាអ្នកសម្រេចថាតើត្រូវចាប់ជនជាតិចាមណា សម្លាប់ជនជាតិចាមណា ឬមួយក៏ជាបញ្ជារបស់ខាងភូមិភាគដើម្បីឲ្យចាប់ជនជាតិចាមមួយណា ឬក៏ដើម្បីឲ្យសម្លាប់ជនជាតិចាមមួយណា? ខ្ញុំចង់សួរបែបនេះ។

**ឆ៖** ខ្ញុំសូមជម្រាប ក្នុងហ្នឹង គឺការចាប់ជនជាតិចាម អ្នក យើងត្រូវសម្លាប់ ឬមិនត្រូវសម្លាប់។ ក្នុងហ្នឹង គឺមានគណៈភូមិភាគនៅជិតដែរ ហើយក្នុងហ្នឹង គឺពូអាន ក៏គាត់បានដិតដល់ជាមួយភូមិភាគ។ អ៊ីចឹង ក្នុងស្រុករបស់ខ្ញុំ ខ្ញុំរាយការណ៍ ក៏ខ្ញុំរាយការណ៍ថាជនជាតិចាមខ្លះក៏យើងត្រូវបោសសម្អាត តែជនជាតិចាមខ្លះក៏យើងមិនត្រូវបោសសម្អាតដែរ ខ្លះក៏ល្អ ខ្លះក៏អាក្រក់។ ហេតុនេះ តាំងពីខ្ញុំធ្វើមក ដូចថា ការធ្វើសម្លាប់នេះ គឺវាមាន មិនមែនថាអត់ទេ គឺនៅក្នុងស្រុកកំពង់សៀមចាប់ៗសម្លាប់នោះ វាមាន។ តែឲ្យសម្លាប់ទាំងអស់ ក៏អត់ដែរ។ នៅដូចថាអ្នកល្អយើងទុកទៅ មិនទំនាស់ មិនធ្វើវិច្ឆេទកម្មអីនៅក្នុងស្រុក

ហ្នឹងទុក ប៉ុន្តែអ្នកណាទំនាស់ខ្លាំងអីអ៊ីចឹង គឺយើងក៏បោសសម្អាត។ នេះសូមជម្រាបប៉ុណ្ណឹង។

**សៈ** [redacted]

[០៩:៣៧:០៦]

**ឆៈ** [redacted]

**សៈ** ឥឡូវនេះ ខ្ញុំសួរការអំពីលេខាម្នាក់ -- គឺអ្នកជំនួយការម្នាក់ធ្វើការជាមួយលោកស្រីគឺឈ្មោះ ភា ដែលជាជនជាតិចាម។ តើលោកស្រីអាចប្រាប់បានទេ ថាតើមានអ្វីកើតឡើងចំពោះ ភា ក្រោយពេលដែលលោកស្រីទទួលបញ្ជាពីលេខាតំបន់ឲ្យចាប់ខ្លួន ហើយនិងសម្លាប់ជនជាតិចាមហ្នឹង។ តើមានអ្វីកើតឡើងចំពោះ ភា?

**ឆ៖** ខ្ញុំសូមជម្រាប។ ឈ្មោះភា នេះ -- ខ្ញុំសូមនិយាយប្រវត្តិបន្តិចចុះ -- កាលខ្ញុំនៅខេត្តកំពតគឺម៉ែឪគាត់បានយកកូនហ្នឹងមកផ្ញើៗទុកឲ្យខ្ញុំចិញ្ចឹម ខ្ញុំក៏នឹកឃើញថាកាលនោះអាយុ១២ ១៣ឆ្នាំទេ ១៤ ១៥ គាត់ម៉ែឪមកទាំងខ្លួន មកទាំងយកម៉ាស៊ីនដេរមកមួយទៀត ខ្ញុំក៏ចិញ្ចឹម ទុកគាត់ជាកន្លែងកាត់ដេរមួយជាមួយបងប្អូន។ ពេលខ្ញុំទៅកំពង់ចាម ខ្ញុំយល់ថា ឈ្មោះនេះ ម៉ែឪបានយកមកផ្ញើ។ បើសិនជាខ្ញុំទុកចោលនៅខេត្តកំពត ហាក់ដូចជាខ្ញុំហ្នឹងមិនពេញចិត្ត ព្រោះអ៊ីចឹងខ្ញុំក៏យកទៅខេត្តកំពង់ចាម។ ពេលខ្ញុំទៅឆ្នាំទី -- ខ្ញុំទៅឆ្នាំ៧៧នេះ ខ្ញុំក៏យកគាត់ទៅតាម។ យកតាម ដល់ខ្ញុំនៅបានប្រហែលជាពាក់កណ្ដាលឆ្នាំបានថាកើតរឿងដែលគេថា បោសសម្អាតចាមអ៊ីចឹងក៏ខ្ញុំអត់ដឹងដែរ ក៏ពូអាន គាត់មកប្រាប់ខ្ញុំថា "សមមិត្តចិញ្ចឹមចាមម្នាក់ដែលនៅក្នុងមន្ទីរហ្នឹង តើសមមិត្តមានបញ្ហាម៉េច? ខ្ញុំថាម៉េចចុះ រឿងម៉េច បានពូឯងសួរអ៊ីចឹង?" គាត់ថា៖"បានខ្ញុំមកសួរសមមិត្ត មកពីចាម គេត្រូវការខាងលើបញ្ជាមកបោសសម្អាត!" ហើយខ្ញុំភ្ញាក់ដែរ ភ្ញាក់ខ្លួនដែរ ព្រោះខ្ញុំចិញ្ចឹមចាមម្នាក់ដែរ ចំពោះខ្លួនខ្ញុំ។ អ៊ីចឹងខ្ញុំក៏មានមតិជាមួយគាត់ ខ្ញុំសូមនិយាយប្រវត្តិហ្នឹងបន្តិចចុះ។ "ថាពូឯងធ្វើអ៊ីចឹង មិនត្រឹមត្រូវទេ ព្រោះខ្ញុំបានចិញ្ចឹមតាំងពីខេត្តកំពតមកដល់កំពង់ចាម ខ្ញុំមិនអាចធ្វើអ៊ីចឹងបានទេ។ ខ្ញុំអង្វរពូឯងក៏បានដែរ។ គាត់ថា កុំបាច់និយាយ នៅឲ្យស្ងៀមទៅ បើសិនជាសមមិត្តបានចិញ្ចឹមហើយ ខ្ញុំក៏អត់មាត់"។

[០៩:៤១:៣២]

ដល់ទីបញ្ចប់ លោកប្រធានក្នុងមន្ទីរ ប្រធានណាន ហ្នឹងគាត់ប្រាប់ខ្ញុំ ខ្ញុំក៏ថា៖ "មិនបាច់និយាយទេរឿងហ្នឹង ព្រោះខ្ញុំយកគាត់មកឆ្ងាយណាស់"។ ដល់អ៊ីចឹងទៅ ក៏គាត់ថ្ងៃមួយ ខ្ញុំអង្គុយ គាត់មកយំ គាត់ភ័យ ហើយខ្ញុំក៏និយាយជាមួយគាត់ថា មិនបាច់យំ មិនស្រែកទេ។ បើសិនជាខ្ញុំយកអ្នកឯងមកពីនោះមកដល់ថ្ងៃនេះហើយ ខ្ញុំសម្លាប់អ្នកឯង ដូចជាសម្លាប់ជីវិតខ្ញុំអ៊ីចឹង។ ខ្ញុំមិនបាច់ឲ្យអ្នកឯងភ័យទេ។ ហើយខ្ញុំដឹងតាំងពីជំនាន់ថា បងឯងចិញ្ចឹមចាម ខ្ញុំអត់ដឹងដែរ។ កាលនោះ គាត់យកមកផ្ញើ ខ្ញុំមិនបានចាប់អារម្មណ៍ថាកូនចាម កូនខ្មែរអី វាផ្ញើច្រើន កាលនុ៎ង។ ហេតុនេះ ដល់ពេលហ្នឹងទៅ បានគាត់យំអ៊ីចឹង ខ្ញុំក៏ណែនាំគាត់ឈ្មោះ ភា ឥឡូវជាប្អូនថ្លៃរបស់ខ្ញុំ គាត់នៅស្ទឹងកែវសព្វថ្ងៃនេះ។ ខ្ញុំទុកជីវិតគាត់ម្នាក់ហ្នឹងដែរ។ ជាទស្សនៈរបស់ខ្ញុំ ខ្ញុំយល់ថា រូបគេ រូបខ្ញុំ ខ្ញុំគិតដែរហ្នឹង អ៊ីចឹងចំពោះ ភា ហ្នឹងខ្ញុំទុក ខ្ញុំអត់មានមាត់ មានកទេ រហូតដល់ថ្ងៃនេះដែលខ្ញុំទុកជីវិតគាត់។ តែគាត់ជាចាមមួយរូបនៅស្ទឹងកែវ ភូមិចាមតែម្ដង ប៉ុន្តែម៉ែឪដាច់ខាតជាមួយខ្ញុំ គាត់យកផ្ញើ។ ហេតុនេះ ខ្ញុំទុកជីវិតគាត់ដល់ថ្ងៃនេះ។ ប៉ុនខ្ញុំនិយាយអ៊ីចឹង វាធ្វើឲ្យលោកថា ហ៊ឺ! អ៊ីចឹងបុគ្គលស្រឡាញ់តែម្នាក់។ ចំពោះចាមដទៃនៅក្នុងស្រុក អត់មានគិត។ តែ

នេះជាផ្ទាល់ខ្លួនរបស់ខ្ញុំដែលគាត់នៅជាមួយទៅហើយ អ៊ីចឹងខ្ញុំក៏ទុកគាត់ ទាល់តែថ្ងៃហ្នឹង។ ឥឡូវជាប្អូនថ្លៃរបស់ខ្ញុំ គាត់នៅ -- សព្វថ្ងៃនៅស្ទឹងកែវ។ ហើយអត់ៗស្លាប់ទេ ហ្នឹងខ្ញុំសូមជម្រាបដោយការស្មោះត្រង់ គឺទស្សនៈខ្ញុំ គឺៗថា អត់មានអី ខ្ញុំគិតគាត់ អាណិតគាត់។ នេះសូមអស់។

[០៩:៤៣:៥៦]

**ស៖** [redacted]

**ឆ៖** [redacted]

**ស៖** [redacted]

**ឆ៖** [redacted]

[០៩:៤៦:៣៥]

**ស៖** [redacted]

**ឆ៖** [redacted]

**ស៖** [redacted]

**ឆ៖** [redacted]

**ស៖** [redacted]

[០៩:៥០:០០]

**ឆ៖** [redacted]

**ស៖** [redacted]

**ឆ៖** [redacted]

[redacted]

សៈ [redacted]

[០៩:៥៤:០១]

ឆៈ [redacted]

សៈ [redacted]

ឆៈ [redacted]

[redacted]

**សៈ** [redacted]

**ឆៈ** [redacted]

[០៩:៥៧:០០]

**សៈ** តើអ្នកស្រីចាំទេថា ការបោសសម្អាតទៅលើជនជាតិចាម គឺជាបញ្ហាដែលត្រូវរាយការណ៍ និងត្រូវពិភាក្សានៅក្នុងកិច្ចប្រជុំភូមិភាគដែលអ្នកស្រីចូលរួមដែរឬទេ?

**ឆៈ** ខ្ញុំអត់ដែលបានពិភាក្សាជាមួយភូមិភាគទេ ខ្ញុំពិភាក្សាជាមួយគណៈតំបន់។ ភូមិភាគ អាហ្នឹងជាការងាររបស់គាត់ជាមួយគណៈតំបន់ តែចំពោះខ្ញុំគឺអត់បានពិភាក្សាទេ ប្រជុំ គឺគ្រាន់តែប្រជុំលើកផែនការថ្មី អីចឹង ដូចជានៅក្នុងស្រុក នៅក្នុងឃុំ នៅក្នុងតំបន់ហ្នឹង មានបញ្ហាអី លើកយកមកប្រជុំ ដោះស្រាយ តែឲ្យការងារទាំងអស់នេះ ខ្ញុំក៏មិនបានដឹងទាំងអស់ មិនដឹងថាគាត់ប្រជុំក្នុងគណៈភូមិភាគគាត់យ៉ាងម៉េច ខ្ញុំមិនដែលបាន -- តាពក គាត់មិនដែលបានលើកក្នុងបញ្ហាហ្នឹងផង។

**សៈ** [redacted]

**ប្រធានអង្គជំនុំៈ**

[redacted]

**លោក វិចទ័រ កូប៉េៈ**

[redacted]

[redacted]

លោក ឌៀល លីសាក់៖

[redacted]

[១០:០០:០០]

ប្រធានអង្គជំនុំ៖

[redacted]

សួរដោយលោក ឌៀល លីសាក់៖

សៈ [redacted]

លោកស្រី ប្រាក់ យុត៖

ឆ៖ [redacted]

[១០:០១:០៥]

សៈ [redacted]

ឆ៖ [redacted]

[redacted]

[១០:០២:៤១]

សៈ [redacted]

ឆៈ [redacted]

ស៖ [redacted]

[១០:០៧:០៧]

ឆ៖ [redacted]

ស៖ [redacted]

ឆ៖ [redacted]

[១០:០៩:៣៣]

ស៖ [redacted]

ឆ៖ [redacted]

**ស៖** [redacted]

**ឆ៖** [redacted]

**ស៖** [redacted]

**ឆ៖** [redacted]

**ប្រធានអង្គជំនុំ៖**

ហើយបាទ អរគុណ។ បាទ ឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះក៏សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ ព្រមទាំងមេធាវីប្រឹក្សាសាក្សី មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៣៤ នាទី)*

[១០:៣៤:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីសាក្សី កាលពីព្រឹកនេះលោកស្រីបានប្រាប់យើងថា ក្រៅពីឈ្មោះ ភា គឺមិនមានជនជាតិចាម ដទៃទៀតដែលត្រូវបានលើកលែងនោះឡើយ។ ដូច្នេះ ខ្ញុំចង់សួរអ្នកស្រីទាក់ទងទៅនឹងការស្រាវជ្រាវមួយចំនួនដែលគេធ្វើឡើងនៅក្នុងស្រុកកំពង់សៀម ទាក់ទងទៅនឹងប្រធានបទមួយនេះ។ មានបុគ្គលម្នាក់ឈ្មោះ អ៊ីសា ឧស្មាន បានធ្វើការស្រាវជ្រាវអំពីសៀវភៅជនជាតិចាម។ នៅក្នុងសៀវភៅរបស់គាត់ គឺឯកសារឈ្មោះ អ៊ូគូបាស គឺឯកសារ E3/1822 អង់គ្លេសមានលេខ 00078568 ដល់ 69 គឺមិនមានឯកសារបកប្រែជាភាសាខ្មែរ និងបារាំងនោះទេ។ នៅក្នុងសៀវភៅនេះ លោក អ៊ីសា ឧស្មាន បានរៀបរាប់អំពីភូមិចំនួន១០ ដែលថាប្រជាជនចាម នៅក្នុងភូមិទាំង១០នោះ ត្រូវបានគេបោសសម្អាតចោលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្នុងចំណោម ហើយភូមិប្រាំ ក្នុងចំណោមភូមិទាំង១០

នោះ គឺនៅក្នុងស្រុកកំពង់សៀម គឺកោះប្រាក់ ចំការ៣០ ប្រហែលជា -- និងមួយទៀតគឺ គគរ និងមួយទៀត គឺរកា ហើយនិងភូមិលែងរវៀង ហើយក្នុងឯកសាររបស់រដ្ឋបាលមួយទៀត គឺនិយាយអំពីការបោសសម្អាតជនជាតិអ៊ីស្លាមនៅក្នុងកម្ពុជាប្រជាធិបតេយ្យ គឺឯកសារE3/2624 – E3/2624, អង់គ្លេសមានលេខ 00032978 គឺមានតែភាសាអង់គ្លេសប៉ុណ្ណោះ ហើយឯកសារផ្សព្វផ្សាយនេះបានដកស្រង់ដូចតទៅនេះ៖ "ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម គឺមានគ្រួសារជនជាតិចាម ប្រហែលជា២០០០នាក់ រស់នៅក្នុងភូមិប្រាំពីរ គឺកំពង់ក្របី ចំការ៣០ កោះគរ កោះរកា កោះប្រាក់ ភូមិរកា និងររអាង។ ភូមិទាំងអស់នេះត្រូវបានកម្ទេច"។ ចាមទាំងអស់នេះត្រូវបានកម្ទេច។ ដូច្នេះ ខ្ញុំចង់សួរអ្នកស្រីថា តើអ្នកស្រីបានដឹងអំពីគ្រួសារជនជាតិចាម ឬក៏ប្រជាជនចាម ដែលត្រូវបានគេលើកលែងជីវិត ហើយនៅរស់រានមានជីវិតដូចជំនួយការរបស់អ្នកស្រី គឺ ភា នោះដែរឬទេ? ឬមួយក៏ថាជនជាតិចាមទាំងអស់ត្រូវបានគេចាប់ខ្លួន ហើយសម្លាប់ទាំងអស់ តាមបញ្ជារបស់ខាងថ្នាក់លើ?

[១០:៣៨:៥៤]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមជម្រាប ប្រជាជនចាមទាំងអស់នោះ មិនមានសម្លាប់ទាំងអស់ទេ នៅសល់ខ្លះ។ សូមឆ្លើយខ្លីអ៊ីចឹង គ្រប់ភូមិដែលបានលើក។

**ស៖** តើអ្នកស្រីអាចប្រាប់បានទេថា ក្រៅពីជំនួសការអ្នកស្រី គឺភា ហ្នឹងថាតើមានជនជាតិចាមដទៃទៀតណា ដែលអ្នកស្រីនិយាយថា មិនបានសម្លាប់ ឬក៏ត្រូវបានគេលើកលែងនោះដែរឬទេ? តើអ្នកស្រីអាចប្រាប់ឈ្មោះ ឬក៏អំពីអត្តសញ្ញាណរបស់ជនជាតិចាមដែលនៅរស់នោះដែរឬទេ?

**ឆ៖** ខ្ញុំអាចប្រាប់បានទេ ព្រោះខ្ញុំ និយាយទៅវាភ្លេចដែរ យូរពេកហើយ មិនដឹងនៅសល់ប៉ុន្មានអីប៉ុន្មាន គឺខ្ញុំមិនបានចាំ។

**ស៖** តើអ្នកស្រីអាចប្រាប់បានទេថាតើអ្នកដែលត្រូវបានគេលើកលែងជីវិតហ្នឹង មកពីភូមិណាដែរ? អ្នកស្រីអាចជម្រាបបានទេ?

**ឆ៖** ជម្រាបមិនបានទេ ព្រោះតាមខ្ញុំដឹងថា ការពិតគឺមានលោកស្រី ភា មួយក្រៅពីហ្នឹង ខ្ញុំមិនអាចជម្រាបបានទេ មិនដឹងនៅភូមិណាខ្លះ។

**ស៖** [redacted]

[redacted]

ឆ៖ [redacted]

សៈ អ្នកស្រី ខ្ញុំមិនបានសួរអ្នកស្រីអំពីស្ថិតិ ហើយខ្ញុំក៏មិនឲ្យអ្នកស្រីប៉ាន់ស្មានអំពីចំនួនតួរលេខនោះដែរ ខ្ញុំគ្រាន់តែចង់ដឹងថាតើឃុំហ្នឹងមានជនជាតិចាមច្រើន ឬក៏អត់ផ្អែកទៅតាមបទពិសោធន៍របស់អ្នកស្រីជាមេស្រុក ថាតើអ្នកស្រីគិតថាឃុំហ្នឹងមានជនជាតិចាមច្រើនដែរឬទេ?

ឆ៖ ឃុំហ្នឹង បើគិតជារឿងចាម មិនច្រើនប៉ុន្មានទេ ចាញ់នៅភូមិឃុំទ្រានោះ តិចជាងឃុំទ្រាននេះសូមជម្រាបប៉ុណ្ណឹង។

សៈ តើមាន -- តើឃុំណាផ្សេងទៀតដែលមានជនជាតិចាមច្រើនជាងនេះរស់នៅ?

ឆ៖ ខ្ញុំមិនបានចាំអស់ដែរ ព្រោះវាច្រើនឃុំដែរ មិនដឹងឃុំណាច្រើនជាងឃុំណា ខ្ញុំមិនចាំបានទាំងអស់។ មិនដឹងថាក្រុមណាច្រើនជាងគេកាលនោះវា -- មិនអាចចាំបានទេ។

[១០:៤៣:៤០]

សៈ ឥឡូវនេះ ខ្ញុំសូមអាននូវសម្រង់មួយចេញពីការស្ដាប់ចម្លើយ គឺសាក្សីមកពីភូមិ -- មកពីឃុំគគរ គឺនៅក្នុងសៀវភៅ មានចំណងជើងថាការបះបោរជនជាតិចាម ឯកសារ E3/2653, ភាសាអង់គ្លេសមានលេខ 00219210 ដល់ 211, ភាសាខ្មែរមានលេខ 00904408 ហើយមិនមានការបកប្រែជាភាសាបារាំងទេ។ គឺជាការសម្ភាសជាមួយសាក្សីមកពីភូមិគគរ គាត់និយាយដូចតទៅនេះ៖ "ក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានប្រកាសថាមានខ្មាំងប្រហែលជា២០០០នាក់នៅក្នុងឃុំ រឿងនេះធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង ខ្ញុំចេះតែឆ្ងល់ក្នុងចិត្តពីព្រោះចំនួនហាក់ដូចជាច្រើនហួសប្រមាណ។ ប៉ុន្មានថ្ងៃបន្ទាប់មកក៏ស្រាប់តែខ្មែរក្រហមដើរកត់ឈ្មោះគ្រប់ជនជាតិចាមទូទាំងឃុំ ខ្ញុំចេះតែកើតការសង្ស័យអំពីរឿងនេះពីព្រោះជនជាតិចាមមានចំនួនប្រហាក់ប្រហែលនឹង ២.០០០នាក់ដូចតាមការគិតទុកមែន។ បន្ទាប់ពីកត់ឈ្មោះរួច ខ្មែរក្រហមបានរើសយកបុរសៗជនជាតិចាមទៅសម្លាប់មុនគេ។ ក្នុងមួយយប់ មានប្រមូលយកប្រាំនាក់ ឬរហូតដល់១០នាក់។ ដំបូងយើងមិនបានដឹងថា ខ្មែរក្រហមយកអ្នកនោះទៅសម្លាប់ឡើយ ប៉ុន្តែក្រោយមកទើបបានដឹង ពីព្រោះខ្មែរក្រហមបានយកខោអាវ និងស្បែកជើងអ្នកទាំងនោះ មកចែកឲ្យអ្នកភូមិវិញ។ ក្រោយពីប្រមូលបុរសអស់ហើយ ខ្មែរក្រហមបានប្រមូលយកស្ត្រី និងកុមារទៅសម្លាប់

ជាបន្តទៀត។" សូមបញ្ចប់ការដកស្រង់។ ខ្ញុំមិនបានសួរ -- ខ្ញុំមិនសួរឲ្យអ្នកស្រីឲ្យប៉ាន់ស្មានអំពីតួលេខដែលថាមានមនុស្ស២.០០០នាក់នោះទេ ហើយដោយសារតែអ្នកស្រីបញ្ជាក់ហើយ ថាអ្នកស្រីមិនដឹង។ ដូច្នេះ អ្វីដែលខ្ញុំចង់សួរអ្នកស្រី គឺដូចដែលខ្ញុំសួរនៅក្នុងភូមិដទៃទៀតអ៊ីចឹង។ ដូច្នេះ តើអ្នកស្រីដឹងទេថាតើមានជនជាតិចាមណាមួយនៅក្នុងឃុំគគរ ដែលត្រូវបានគេលើកលែងជីវិត ហើយរស់រានមានជីវិតឆ្លងកាត់របបខ្មែរក្រហមនោះមក?

**ឆ៖** កាលនោះនៅឃុំគគរ ដូចខ្ញុំមិនបានដឹងដែរ ថាអ្នកណារស់រានមានជីវិតក៏ខ្ញុំ ពេលនោះ ខ្ញុំក៏មកផុតហើយ មិនដឹងអ្នកណានៅអត់ អ្នកណានៅខ្លះ អ្នកណាមិននៅ គឺខ្ញុំអត់ច្បាស់លាស់ដែរ។ ដឹងនៅប៉ុន្មាននាក់។

[១០:៤៧:០៤]

**ស៖** [redacted]

**ឆ៖** [redacted]

**ស៖** [redacted]

**ឆ៖** [redacted]

**ស៖** មានចំណុចមួយទៀតដែលខ្ញុំចង់បញ្ជាក់ជាមួយអ្នកស្រីផងដែរគឺពាក់ព័ន្ធទៅនឹងអតីតទាហានលន់ នល់ តើបញ្ហាដែល គឺបញ្ហាដែលអ្នកស្រីទទួលពីតំបន់។ តើបញ្ហាហ្នឹង បញ្ហាឲ្យចាប់ខ្លួនហើយនិងសម្លាប់ទាហានលន់ នល់ ទាំងអស់ ឬមួយក៏ចាប់ខ្លួនតែទាហានដែលមានឋានន្តរសក្ដិជាក់លាក់មួយចំនួន ឬមួយក៏ឲ្យចាប់ខ្លួនតែអ្នកដែលប្រព្រឹត្តខុស ឧទាហរណ៍ដូចជា ប្រឆាំងជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាជាដើម។ ដូច្នេះ តើអ្នកស្រីអាចបញ្ជាក់ឲ្យលម្អិតបានទេ ថាតើបញ្ហាដែលអ្នកស្រីទទួលពីលេខាតំបន់អាន ហ្នឹងមានជាបញ្ហាបែបណាដែរ?

**ឆ៖** កាលនោះ បញ្ហារបស់គាត់ជាអតីតទាហានលន់ នល់ គឺយើងមិនមែនថា -- គាត់បញ្ហាមកគាត់ -- ខ្ញុំធ្វើតាមគាត់ទាំងអស់ តែក៏គាត់ឲ្យជ្រើសរើសដែរ។ ជ្រើសរើសអ្នកណាដែលយើងអាចមើលទៅដែលយើងថា មិនត្រឹមត្រូវ អ្នកណាល្អ គឺយើងទុក ហើយមិនអាចធ្វើអីគាត់កើតទេ។ ហេតុនេះ ខ្ញុំមានបីចំណុច។ ចំណុចទី១ ខ្ញុំជ្រើសរើសអ្នកល្អ អ្នកមធ្យម អ្នកណាដែលប្រឆាំងខ្លាំងអីទៅ ខ្ញុំក៏ធ្វើតាមបញ្ហាខាងលើដែរ។ បើអ្នកណាល្អខ្ញុំក៏ទុកគាត់អប់រំថែមអ៊ីចឹងទៅ។ សូមអស់។

[១០:៥២:០៣]

**ស៖** តើគេកំណត់យ៉ាងដូចម្ដេចថាតើទាហានលន់ នល់ ណាដែលប្រឆាំងជាមួយអង្គការ អ្នកណាដែលមិនប្រឆាំងជាមួយអង្គការ?

**ឆ៖** គាត់កំណត់ថា អ្នកណាប្រឆាំងជាមួយយើង អាហ្នឹងយើងត្រូវគិតដែរ។ អ្នកមិនប្រឆាំងក៏យើងអត់ធ្វើអីគាត់ដែរ។ ព្រោះយើងចេះតែធ្វើទាំងអស់ម៉េចកើត -- មិនកើតទេ ទាល់តែយើងជ្រើសរើស។ ដូចអ្នកប្រឆាំង ដូចថា មើលទៅអ្នកគេមិនសូវពេញចិត្តយើងខ្លាំង អាហ្នឹងចាំយើងគិត បើថាអត់ទេ ខ្ញុំក៏យកនយោបាយមួយអប់រំទុកឲ្យជួយកែប្រែគាត់ទៅ ព្រោះម្យ៉ាងគាត់មិនសូវយល់អីអ៊ីចឹង យើងចេះតែអប់រំគាត់ទៅ ហើយបើអ្នកខ្លាំងអ៊ីចឹងខ្ញុំក៏រាយការណ៍ឲ្យតំបន់ដែរថា ឥឡូវឈ្មោះនេះ ឈ្មោះអ៊ីចឹង ឈ្មោះនេះៗទៅ យើងឲ្យខាងលើជួយអប់រំថែមទៅ ឬមួយគាត់មានវិធានការយ៉ាងម៉េច អាហ្នឹងស្រេចខាងលើទេ។ តែចំពោះខ្ញុំខាងក្រោម ខ្ញុំយល់ថា បើអ្នកល្អក៏យើងមិនចេះតែយកគាត់ទៅដែរ ទុកយើងអប់រំគាត់ កែប្រែគាត់។ នេះខ្ញុំសូមជម្រាបខ្លីៗទេ ព្រោះកាលនោះ ខ្ញុំក៏វាមិនអាចចាំទាំងអស់ដែរ។ ខ្ញុំសូមជម្រាប វាភ្លេចដែរ ព្រោះច្រើនមុខ ភ្លេចភ្លាំងដែរ ហើយការយកទៅនេះ ក៏ខាងលើអ្នកវិភាគដែរ ព្រោះយើងរាយការណ៍ឲ្យគាត់។ អ្នកណាល្អ អ្នកណាអាក្រក់ អ្នកណាប្រឆាំង អ្នកណាមិនប្រឆាំងក៏យើងរាយការណ៍ឲ្យគាត់ដែរ។

**សៈ** ខ្ញុំចង់សួរថាតើអ្នកស្រីសម្រេចដោយរបៀបណា ឬក៏កំណត់ដោយរបៀបណាថាអ្នកណាជាអ្នកប្រឆាំង អ្នកណាជាអ្នកមិនពេញចិត្តជាមួយរបបជាដើមហ្នឹង។ តើអ្នកស្រីកំណត់ដោយរបៀបណា?

**ឆៈ** ពេលនោះ ខ្ញុំកំណត់ៗនែ៎ថា ក្នុងស្រុកខ្ញុំអ៊ីចឹង ខ្ញុំពិនិត្យមើលប្រវត្តិរូបគេខាងដើមអ៊ីចឹងទៅ អ្នកណាល្អ អ្នកណាអាក្រក់ ខ្ញុំចេះដូចថាអប់រំបណ្តើរៗអ៊ីចឹង អត់មានយកគាត់ទៅណាទេ។ ហើយបើជឿថាអ្នកណាដែលប្រឆាំងខ្លាំង ខ្ញុំអប់រំមិនបានអី ខ្ញុំបញ្ជូនឲ្យខាងលើជួយអប់រំ -- អ៎! ជួយអប់រំទៅ ដូចខាងពូអាន អ៊ីចឹង។ ហើយចំពោះខ្ញុំ គឺនៅខាងក្រោមអប់រំបណ្តើរៗ មិនទាន់ទៅជាយកទៅសម្លាប់ចោលអីព្រោះមនុស្សខ្លះក៏មិនមែនប្រឆាំងទាំងអស់អីណា វាមានអត់ មានមាន ខ្លះក៏គ្នាល្អអ៊ីចឹងទៅ យើងទុកអប់រំថែមទៅ។ នេះ ខ្ញុំសូមជម្រាបអ៊ីចឹង ហើយខាងលើក៏ អាហ្នឹង ខ្ញុំមិនដឹងគាត់យ៉ាងម៉េចទេ យើងបានបញ្ជូនរបាយការណ៍ឲ្យគាត់ហើយ គាត់យកទៅវិភាគ ដោះស្រាយយ៉ាងម៉េច អាហ្នឹងស្រេចតែគាត់។

[១០:៥៥:៣៦]

**សៈ** តើអ្នកស្រីមានឲ្យមេឃុំអ្នកស្រីផ្ញើរបាយការណ៍ទាក់ទងទៅនឹងទាហានលន់ នល់ នៅក្នុងឃុំរបស់ពួកគេទេ?

**ឆៈ** មុននឹងធ្វើអីមួយ ទាល់តែមេឃុំរាយការណ៍មក បានស្រុកដឹង។ ស្រុកដឹង រាយការណ៍តំបន់ទៅ។ គាត់រាយកាណ៍តើ តែក្នុងការនិយាយវាខ្វះមុខ ខ្វះក្រោយ សូមអត់ទោស។ មេឃុំក៏រាយ-ការណ៍ឲ្យខ្ញុំដែរ ថាមនុស្សល្អ អាក្រក់អី គាត់រាយមក ខ្ញុំការវិភាគរបស់ខ្ញុំ ក៏ខ្ញុំរាយទៅខាងលើទៅ មេឃុំគេរាយមក។

**សៈ** [redacted]

[redacted]

[១០:៥៨:៣០]

[redacted]

ឆ៖ [redacted]

[redacted]

ស៖ [redacted]

[redacted]

ធ៖ [redacted]

[redacted]

[១១:០២:២១]

ស៖ [redacted]

[redacted]

ធ៖ [redacted]

ស៖ [redacted]

[redacted]

ធ៖ [redacted]

[redacted]

ស៖ [redacted]

[redacted]

ធ៖ [redacted]

[១១:០៥:២៥]

**ស៖** [redacted] សូមលោកស្រីជួយបញ្ជាក់ជូនអង្គជំនុំជម្រះថា លោកស្រីបានរៀបការនៅក្នុងឆ្នាំ១៩៧៣ ឬក៏ឆ្នាំ១៩៧៥? គឺការរៀបការជាមួយប្ដីទី១ របស់លោកស្រី?

**ឆ៖** ក្នុងការរៀបចំការនេះ ខ្ញុំការជាមួយប្ដីនេះ គឺខ្ញុំលើកទាំងពីរវគ្គដែលបានសួរខ្ញុំនេះ ខ្ញុំមិនដឹងថាយក៧៥ ឬក៏៧៣ ខ្ញុំវាច្រឡំដែរ ហើយក៏វាយូរពេកហើយ តាំងពីនោះមក ហើយខ្ញុំអត់បានគិតរឿងថាប្ដីហ្នឹង មិនដឹងថាឆ្នាំ៧៥ ឬចិត ប៉ុនខ្ញុំថា ឆ្នាំចិតៗ ៧៣ដឹង។ ឥឡូវខ្ញុំថាយកតែមួយ គឺឆ្នាំ៧៣ទៅ ព្រោះខ្ញុំវា វាក់ដែរបញ្ហាហ្នឹង ការជាមួយប្ដីហ្នឹង។

**ស៖** លោកស្រីបានឆ្លើយថា អង្គការបានរៀបការឲ្យលោកស្រី សូមលោកស្រីជម្រាបជូនតុលាការផងមើលថា តើយ៉ាងម៉េចបានជាមានការរៀបការដោយអង្គការឲ្យលោកស្រីហ្នឹង?

**ឆ៖** សូមសួរម្ដងទៀត ខ្ញុំស្ដាប់អត់បាន។

[១១:០៧:៥៨]

**ស៖** សូមលោកស្រីរៀបរាប់ជូនតុលាការនៅពេលដែលលោកស្រីបានរៀបការជាមួយប្ដីទី១ របស់លោកស្រី។ ហេតុអ្វីបានជាអង្គការរៀបការឲ្យលោកស្រី?

**ឆ៖** ខ្ញុំសូមជម្រាប អង្គការការឲ្យខ្ញុំ ធម្មតាយើងរស់នៅជាមួយគ្នា និយាយរួមគឺនៅជាមួយគ្នាតែអង្កាល់នោះ ខ្ញុំក៏មិននឹកឃើញគ្រួសារអីដែរ ប៉ុន្តែដល់ តាចាប គាត់ថាឲ្យខ្ញុំយក ខ្ញុំយក។ មិនចង់បានគ្រួសារទេ ព្រោះកាលនោះ ខ្ញុំនៅក្មេងដែរ វានៅវ័យដែរ វានេះដែរ ហើយគាត់ថាឲ្យខ្ញុំការ ខ្ញុំនឹកឃើញថាបើខាងលើឲ្យការហើយ ខ្ញុំក៏ដាច់ចិត្តដែរ ខ្ញុំការជាមួយគាត់។ ប៉ុន្តែការពិតទៅ ខ្លួនខ្ញុំមិនមែនចង់ទាន់បានចង់បានប្ដីទេ តែអង្គ -- ខាងលើអង្គការឲ្យយកហើយ ខ្ញុំយកទៅ តែបើ -- គាត់ថាយកប្ដីទៅ នៅធ្វើអីទៀត។ ខ្ញុំក៏យកតាមគាត់ ហើយការ។ ការឆ្នាំ -- ខ្ញុំមិនបានចាំអស់ដែរ មិនដឹង៧៥ ឬក៏៧៣ ខ្ញុំអត់ច្បាស់។ ការហើយទៅ ក៏ប្ដីប្រពន្ធនេះ ក៏បានមិនបានជួបជុំគ្នាដែរ បែកបាក់គ្នា មួយនៅនេះ មួយនៅនោះ ខ្ញុំក៏ធ្វើការផ្សេង គាត់ធ្វើការផ្សេង។ តែក៏ខ្ញុំមិនដែលមានបញ្ហាអីជាមួយប្ដីប្រពន្ធដែរ ទោះបីបែកបាក់គ្នាមែន នៅឆ្ងាយពីគ្នាមែន តែខ្ញុំមិនដែលឈ្លោះគ្នាទេ ព្រោះគាត់ គាត់នៅកន្លែងកងទ័ពអីអីចឹង ខ្ញុំនៅកាន់ខាងស្រុកមួយអីចឹងទៅ គាត់នៅកន្លែងឆ្ងាយពីខ្ញុំ ខ្ញុំមិនដែលទៅមកអី។ លើកលែងតែពេលប្រជុំតំបន់អី

ខ្ញុំជួបគាត់ទៅ បើអត់ទេ ក៏ហីទៅ ធម្មតា។ ហើយថាការនេះ មិនមែនថា ខ្ញុំមិន -- ខ្ញុំត្រូវតែឯកភាពជាមួយខាងលើហើយ ព្រោះគាត់ទុកដាក់ ខ្ញុំយល់ចេះ យកតាមគាត់ទៅ តែការហើយក៏សុខដុមរហូតអត់មានបញ្ហាអីទេ។ នេះសូមជម្រាបប៉ុណ្ណឹង។

**ស៖** លោកស្រីបានបញ្ជាក់ថា អ្នកដែលរៀបការឲ្យលោកស្រីហ្នឹង គឺតាចាប តើតាចាបជាអ្នកណាលោកស្រី?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗឆ្លើយ!

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** តាចាប គាត់ជាប្រធានលេខាតំបន់កំពត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីទើបតែបានឆ្លើយថា លោកស្រីត្រូវតែយល់ស្របជាមួយនឹងការដែលរៀបការដោយអង្គការ។ ហេតុអ្វីបានជាលោកស្រីត្រូវតែសម្រេចចិត្តស្របតាមអង្គការក្នុងការរៀបការឲ្យលោកស្រីនេះ?

**ឆ៖** ត្រូវតែខ្ញុំសម្រេចចិត្ត ព្រោះខ្លួនខ្ញុំជាស្រីជៀសយកប្តីមិនរួច ខ្ញុំគិតអ៊ីចេះ។ អ៊ីចឹង ខ្ញុំយកតាមគាត់បណ្តោយ។ ព្រោះយើងជៀសមិនរួចទេ ព្រោះមុនក្រោយទេបើគាត់ -- មិនមែនថាគាត់បង្ខំទេ ទាល់ខ្ញុំស្រឡាញ់ដែរបានយកគ្នាកើត។ អ៊ីចឹង ខ្ញុំយកតាមគាត់បណ្តោយទៅ បើក្នុងហ្នឹងមានចិត្តស្រឡាញ់គាត់ដែរ ហើយក៏តាមគាត់បណ្តោយ បើអត់ស្រឡាញ់ក៏ខ្ញុំអត់យកដែរ ខ្ញុំប្រកែកហួសបាត់ហើយ តែខ្ញុំស្រឡាញ់គាត់ដែរ។ អ៊ីចឹងគាត់ថា "បើស្រឡាញ់គ្នា អើ បើស្រឡាញ់តាមខ្ញុំ អើបើស្រឡាញ់ហើយ ខ្ញុំគិតឲ្យ", ខ្ញុំថា "គិតទៅខ្ញុំយកតើ!"។ ខ្ញុំយកតាមគាត់រហូតទៅ។

[១១:១២:០៨]

**ស៖** លោកស្រីបានរៀបរាប់អំពីការរៀបការខុសពីនេះ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។ ខ្ញុំសូមអានសម្រង់នៃចម្លើយរបស់លោកស្រី និងសួរបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍មួយដែលលោកស្រីឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងខែសីហា គឺឯកសារ E3/9310, ERN អង់គ្លេស 01064271 ដល់ 72, ខ្មែរ 00968128, បារាំង 00115713។ សំណួរ "សួរ៖ អ្នកណាៗណែនាំឲ្យលោកស្រីរៀបការ? ឆ្លើយ៖ តាចាប។ និយាយសរុបគឺថាគាត់ជាអ្នករៀបចំ រៀបការឲ្យខ្ញុំ យើងមិនស្រឡាញ់គ្នាទេ

គាត់ផ្គូរផ្គងឲ្យយើងរៀបការនៅពេលដែលខ្ញុំអាយុ១៨ឆ្នាំ។ គាត់សួរខ្ញុំថាចង់បានប្តីទេ? ខ្ញុំឆ្លើយថាខ្ញុំមិនចង់រៀបការទេ ខ្ញុំចង់រស់នៅលីវ។ ដូច្នេះ កុំឲ្យមានអ្វីមករំខានដល់ជីវិតខ្ញុំ។ គាត់ហៅខ្ញុំថែ។ ថែនេះ គឺសំដៅទៅលើនារីដែលមានអាយុចាស់ជាង គាត់ណែនាំឲ្យខ្ញុំស្គាល់បុរសម្នាក់ជាកងទ័ព។ ខ្ញុំឆ្លើយថា ខ្ញុំមិនចង់រៀបការទេ។ តែចុងបញ្ចប់គឺថាគាត់បានរៀបការឲ្យយើងនៅក្នុងឆ្នាំ១៩៧៣ នៅពេលនោះយើងមិនអាចបដិសេធសំណើអង្គការឲ្យរៀបការទេ។ ជឿខ្ញុំចុះ ថាបើសិនណាជាយើងបដិសេធ គឺថាមានបញ្ហាហើយ អ៊ីចឹងយើងក៏ធ្វើទៅតាមហ្នឹងទៅ ដោយមិនគិតថាតើអនាគតវាយ៉ាងណាៗនោះ។" បញ្ចប់ការដកស្រង់។ លោកស្រីសាក្សី តើត្រឹមត្រូវដែរទេ ដែលថាមនុស្សម្នាក់ដែលគេបានផ្គូរផ្គងឲ្យរៀបការជាមួយលោកស្រី គឺជាមនុស្សដែលលោកស្រីមិនធ្លាប់ស្គាល់ លោកស្រីមិនស្រឡាញ់ទេនៅពេលនោះ។ ខ្ញុំដឹងថាក្រោយមកលោកមានទំនាក់ទំនងល្អជាមួយគាត់។ នៅពេល តាចាប ណែនាំឲ្យលោកស្រីរៀបការជាមួយបុគ្គលនោះលោកស្រីស្គាល់គាត់ទេ?

**ប្រធានអង្គជំនុំ៖**

លោកមេធាវី វ៉ិចទ័រ កូប៉េ!

[១១:១៥:00]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ទៅនឹងរបៀបតាំងសំណួរនេះ។ ខ្ញុំព្យាយាមរកដែរ ប៉ុន្តែរកអត់ទាន់បាន នូវសក្ខីកម្មរបស់គាត់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយមួយ ដែលគាត់បានឆ្លើយថា គាត់ស្រឡាញ់ប្តីគាត់ខ្លាំងមែនទែន។ គាត់សោកស្តាយណាស់ នៅពេលដែលប្តីគាត់ត្រូវបានចាប់ខ្លួន។ ឥឡូវ សហព្រះរាជអាជ្ញារងយកកំណត់ហេតុពីមជ្ឈមណ្ឌលឯកសារកម្ពុជាយកមកសំអាង ប៉ុន្តែនៅក្នុងកំណត់ហេតុស្តាប់ចម្លើយមួយ គាត់បានឆ្លើយថាគាត់ស្រឡាញ់ប្តីគាត់ខ្លាំងណាស់។

**លោក ឌេល លីសាក់៖**

[redacted]

[redacted]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា គឺលោក វ៉ិចទ័រ កូប៉េ ចំពោះការតាំងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិនេះ គឺការតាំងសំណួរនេះ គឺមានមូលដ្ឋានណាស់ហើយ ហើយអង្គជំនុំជម្រះក៏ត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សីចំពោះសំណួរដែលសួរដោយសហព្រះរាជអាជ្ញារងអន្តរជាតិនេះដែរ។

បាទ សូមអញ្ជើញបន្ត សហព្រះរាជអាជ្ញារងអន្តរជាតិ!

[១១:១៦:៥៩]

**លោក ឌេល លីសាក់៖**

[redacted]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** [redacted]

[១១:១៨:២៦]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** [redacted]

[redacted]

[១១:២០:០៥]

**ស៖** លោកស្រីសាក្សីនៅក្នុងសម្រង់ ដែលខ្ញុំទើបតែអានឲ្យលោកស្រីស្តាប់នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកស្រីបានឆ្លើយថា លោកស្រីមិនចង់រៀបការទេ "ប៉ុន្តែបើសិនណាជាខ្ញុំបដិសេធនោះ គេថាយើងនឹងប្រឆាំងនឹងអង្គការហើយ"។ [redacted] តើលោកស្រីចង់ថាយ៉ាងដូចម្តេចនៅពេលលោកស្រីនិយាយថា "ពេលនោះខ្ញុំខ្លាចណាស់ ខ្លាចអង្គការថាខ្ញុំនេះប្រឆាំងទៅនឹងគោលបំណងរបស់អង្គការ"។ ហេតុអ្វីបានជាលោកស្រីខ្លាច?

**ឆ៖** ខ្ញុំសូមច្បិចខ្លីថា ធម្មតាខ្ញុំក្រោមការដឹកនាំរបស់គាត់ បើយើងមិនខ្លាចគាត់ ដឹងខ្លាចអ្នកណា គាត់អ្នកដឹកនាំខ្ញុំទៅហើយ ខ្ញុំគិតអ៊ីចឹងវិញទេ។ បើការគ្រប់គ្រងទាំងអស់នៅក្នុងតំបន់៣៥ គាត់គ្រប់គ្រងទាំងអស់ ហើយបើខ្ញុំប្រឆាំង ហាក់ដូចជាខ្ញុំហ្នឹងមិនគោរព។ អ៊ីចឹងខ្ញុំតាមគាត់ទៅ ការបណ្តោយ ទោះបីខ្ញុំស្រលាញ់ មិនស្រលាញ់ក៏ត្រូវតែយកដែរ ព្រោះយើងគោរពការចាត់តាំង។ នេះ ខ្ញុំសូមច្បិចខ្លីអ៊ីចឹងតែម្តង។

[១១:២១:៣១]

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយពីអំឡុងពេលដែលលោកស្រីធ្វើជាលេខាស្រុកកំពង់សៀម

នៅក្នុងរបបនោះ តើបក្សនូវតែរៀបចំរៀបការប្ដីប្រពន្ធឲ្យគូស្រករដទៃៗទៀតដូចដែលបានធ្វើឲ្យលោកស្រីហ្នឹងដែរអត់? តើការរៀបការដែលរៀបចំដោយអង្គការនេះ នៅតែបន្តអនុវត្តធ្វើបែបនេះរហូតដល់ពេលលោកស្រីទៅធ្វើជាលេខាស្រុកកំពង់សៀមហ្នឹងឬ?

**ឆ៖** ខ្ញុំសូមជម្រាប ក្រោយពីខ្ញុំទៅស្រុកកំពង់សៀម ខ្ញុំបាន -- មិនបានរៀបចំការឲ្យប្រជា -- ចាត់ការឲ្យនោះទេ ព្រោះអាការ ការនេះក៏ខ្ញុំមិនហ៊ានអារកាត់ដែរ ព្រោះដល់សាមីខ្លួនទាំងពីរស្រលាញ់គ្នាពិតប្រាកដ។ ឧទាហរណ៍ ដូចប្អូនខ្ញុំអ៊ីចឹង ឈ្មោះ សោម ធិន លោកស្រីកុល ក្នុងតារាងហ្នឹង មានហើយ។ ខ្ញុំឧទាហរណ៍ប្អូនខ្ញុំអ៊ីចឹង ព្រោះប្អូនខ្ញុំបង្កើត ហើយពៅទៀត ខ្ញុំលើកឧទាហរណ៍ទេ។ ពីរនាក់ហ្នឹង ប្អូនខ្ញុំពៅហ្នឹង ខ្ញុំទៅនឹងខេត្តកំពត -- អ៎! ទៅនៅស្រុកអង្គរជ័យ ដល់ហើយប្រាប់ខ្ញុំថា ខ្ញុំស្រលាញ់ឈ្មោះ មិត្តកុល ហ្នឹងណា។ ដល់ពេលហ្នឹងប្អូនខ្ញុំប្រាប់ខ្ញុំ ប្រាប់ម៉ែខ្ញុំ ម៉ែខ្ញុំនៅហ្នឹងដែរ ហើយអ៊ីចឹងខ្ញុំថា "បើស្រលាញ់បងការឲ្យ តែបើអូនឯងអត់ស្រលាញ់បងអត់ការទេ ព្រោះយើងការអត់កើតទេ", ថា "ខ្ញុំស្រលាញ់"។ អង្កាល់ទុំងប្អូនៗខ្ញុំដឹកជញ្ជូនជើងគោកនៅភ្នំពេញហ្នឹង។ នេះខ្ញុំលើកឧទាហរណ៍ជាក់ស្ដែង ហើយបើសិនជាប្អូនខ្ញុំអត់ស្រលាញ់ ខ្ញុំក៏អត់ហ៊ានការដែរ។ ដល់ហើយ ខ្ញុំមិនអស់ចិត្តទេ ប្អូនខ្ញុំស្រលាញ់អ៊ីចឹងមក ក៏វាដឹកជញ្ជូនជើងគោកតាមផ្លូវកំពង់ចាម ទៅកំពង់ចាមមកភ្នំពេញ។ ដល់វាទៅបាត់ទៅ ខ្ញុំលួចសួរខាងស្រីដែលគាត់នីរសារខ្ញុំហ្នឹង ខ្ញុំលួចសួរផ្ទាល់ថា "អូនឯង ប្អូនខ្ញុំស្រលាញ់ អ្អែងយកអត់?" ខ្ញុំសួរគាត់ត្រង់តែម្ដង។ ហើយហ្នឹងនីរសារខ្ញុំ ខ្ញុំយកពីកំពតមកដែរ ដល់ហើយខ្ញុំថា "ខ្ញុំមិនមែនបង្ខំទេណា កុំធ្វើដូចខ្ញុំហើយតាអាំ" ខ្ញុំនិយាយប្រដូចអ៊ីចឹងទៀត។ ខ្ញុំធ្វើដូចខ្ញុំហើយតាអាំ។ "អ៊ីចឹងប្អូនឯងព្រមយកអត់? ប្អូនខ្ញុំទៅភ្នំពេញបាត់ហើយ ដឹកជញ្ជូនជើងគោកទៅភ្នំពេញហើយ តែចំពោះអូនឯងនៅជាមួយបងនេះ អូនឯងស្រលាញ់ប្អូនបងអត់? បើអ្អែងអត់ស្រលាញ់ថាអត់ស្រលាញ់ បើថាស្រលាញ់បងការឲ្យ" ខ្ញុំក៏និយាយអ៊ីចឹង។ នេះខ្ញុំលើកឧទារណ៍ចំពោះប្អូនខ្ញុំផ្ទាល់។

[១១:២៤:៣១]

ដល់ហើយបីថ្ងៃប្អូនខ្ញុំត្រឡប់មកវិញ ខ្ញុំក៏មិនបាននៅដែរ ខ្ញុំទៅឃុំដែរកាលហ្នឹង ខ្ញុំទៅធ្វើការយប់នៅគគរ ឬក៏ទៅភូមិទ្រានទេ ខ្ញុំក៏ប្រាប់ម៉ែខ្ញុំ ហើយប្រធានមន្ទីរមិត្តណានហ្នឹង ខ្ញុំថា "បើសិនជាលោកណាន ឯងចង់ដឹងច្បាស់សួរប្អូនថ្លៃខ្ញុំអាកុល ហ្នឹងឲ្យច្បាស់លាស់ទៅ។ កុំឲ្យថា ខ្ញុំបង្ខំដើម្បីប្អូនខ្ញុំ ខ្ញុំអត់ធ្វើអ៊ីចឹងទេណា។ ពេលថ្ងៃក្រោយជាគូជីវិតរបស់វា អានាគតរបស់វា បើលែងគ្នាខ្ញុំក៏ពិបាកដែរ។" ខ្ញុំក៏និយាយអ៊ីចឹង ខ្ញុំក៏ខ្ញុំភូមិគគរបាត់ទៅ។ ដល់ពេលខ្ញុំមកវិញ ខ្ញុំវាយឲ្យវែងបន្តិចចុះ ឲ្យពីពិសោធថា

សម័យនោះយើងធ្វើយ៉ាងម៉េច ហើយវាខុសយ៉ាងម៉េច ត្រូវយ៉ាងម៉េច។ ដល់ហើយខ្ញុំមកវិញ ពេល អាធឿន ណន នាំស្រីនោះថា “បងអត់អីទេ វាស្ម័គ្រចិត្តស្ម័គ្រកាយហើយ វាធ្វើប្អូនថ្លៃបងឯង ព្រោះវាឃើញមិត្តងិន ហ្នឹងស្លូត វាយកហើយ។ វានិយាយអ៊ីចេះ។” ដល់ហើយ ខ្ញុំក៏នឹកឃើញថា បើប្អូនស្រឡាញ់គ្នា ខ្ញុំក៏នឹកឃើញថា ម៉ែ ម៉ែៗគាត់នៅជាមួយបន្ទប់ជាមួយដែរ ខ្ញុំថា “អ៊ីចឹង ណន ឯងរៀបចំការឲ្យវាទៅ។ ខ្ញុំមិនបាច់ចេញមុខ ព្រោះអូនឯងប្រធានមន្ទីរ។” ខ្ញុំក៏ឲ្យរៀបចំប្អូនខ្ញុំហ្នឹង។ “រៀបចំការអីស្រួលបួលអូន! ហៅមេឃុំ មេអី ហូបឲ្យស្រួលបួល ធ្វើ -- យើងធ្វើម្ហូបត្រឹមត្រូវទៅ។” ក៏ខ្ញុំការឲ្យរហូតដល់ថ្ងៃហ្នឹង ប្អូនខ្ញុំអត់បែកបាក់ទេ អានេះ។ ហើយពិសោធអ្នកដទៃដែលនៅជាមួយខ្ញុំ ដូចជា ចែមាន វ៉ាន់ ដូចស្អីៗ ស្រីៗទាំងអស់ដែលនៅក្នុងឃុំ ខ្ញុំអត់មានរៀបរយឲ្យទេ ព្រោះកាលណារៀបរយឲ្យ កាលណាគេអត់ស្រឡាញ់គ្នា យើងទៅបង្ខំចិត្ត ហ្នឹងវាខុសដែរ។ ខ្ញុំមើលក្នុងឯកសារខ្លះដែរ ខ្ញុំមិនមែនចេះតែធ្វើទេ។ អ៊ីចឹងបានន័យថាវាអត់មានបញ្ហាទេ។ ក្រោយមក ខ្ញុំអត់បានរៀបចំឲ្យអ្នកណាទេ ប៉ុន្តែក្រែងលោចម្លើយខាងណាមកនិយាយយ៉ាងម៉េច ខ្ញុំមិនដឹងដែរ។ អាហ្នឹងជារឿងចម្លើយច្រើនណាស់ ខ្ញុំមើល ចម្លើយមកក្រៅ។ អ៊ីចឹងធ្វើឲ្យខ្ញុំមានការលំបាកដែរ ចម្លើយថ្មីៗអ៊ីចឹង។ អ៊ីចឹង ខ្ញុំសូមឲ្យលោកជួយវិនិច្ឆ័យទៅចុះ។ តែចំពោះដែលសំណួរលោក ខ្ញុំយល់ហើយថា យើងការតើវាមានការតទៅទៀត។ មាន! តែទាល់តែស្ម័គ្រចិត្តរៀងខ្លួន បានខ្ញុំហ៊ានការ បើអត់ ខ្ញុំធ្វើដូចប្អូនខ្ញុំដែរ។ ខ្ញុំពិសោធមក ការ វាមានការបែកបាក់គ្នារហូតដែរហ្នឹង។ នេះខ្ញុំសូមជម្រាបខ្លីប៉ុណ្ណឹងទេ។ វាអត់មានរឿងបញ្ហាទេ។ តែបើមានសំណួរអីក្រៅពីហ្នឹង ក៏លោកសួរ ខ្ញុំអត់ថាអី។

[១១:២៧:១៩]

**ស៖** លោកស្រីសាក្សី តើលោកស្រីមានសិទ្ធិអំណាចអ្វី ក្នុងការសម្រេចរៀបការឲ្យអ្នកណាដែរ ក្នុងនាមជាលេខាស្រុក ឬក៏លោកស្រីត្រូវតែមានការយល់ព្រមពីថ្នាក់តំបន់ មុននឹងរៀបការឲ្យអ្នកណាម្នាក់?

**ឆ៖** ខ្ញុំអត់មានសិទ្ធិទេ ប៉ុន្តែខ្ញុំនិយាយនេះ ព្រោះខ្ញុំអត់ទាន់បានរៀបការទេ។ បើខ្ញុំ បើនិយាយទៅការអ្នកដទៃ ខ្ញុំមានការសួរគណៈតំបន់ តែប្អូនខ្ញុំមួយ ខ្ញុំអារកាត់ដែរ ព្រោះខ្ញុំនឹកឃើញថា អ៊ីចេះ នឹកឃើញថាខ្ញុំយល់ចិត្តយល់ថ្លើមប្អូនថ្លៃហ្នឹង ហើយប្អូនខ្ញុំបងបង្កើត ព្រោះប្អូនថ្លៃនៅជាមួយខ្ញុំតាំងពីអាយុ ១២ឆ្នាំនោះ។ ខ្ញុំយល់បងប្អូនសាច់ញាតិគាត់ ខ្ញុំយល់។ គេប្រគល់ឲ្យខ្ញុំអ៊ីចឹង។ ដល់អ៊ីចឹងទៅ អ្នកដទៃក្រៅពីនេះ ខ្ញុំអត់មានអារកាត់ទេ ព្រោះខ្ញុំអត់មានសិទ្ធិ។ សិទ្ធិគឺគណៈតំបន់ បានអ្នកសម្រេចបាន។

**ស៖** ចុះតើហេតុអ្វីបានជាថ្នាក់តំបន់ត្រូវតែជាអ្នកសម្រេចក្នុងការរៀបការ? ហេតុអ្វីក៏ ហេតុអ្វីមិនឲ្យគូស្រករខ្លួនគេផ្ទាល់ជាអ្នកសម្រេចថាទៅ ព្រមរៀបការ ឬក៏មិនព្រម?

**ឆ៖** មុននឹងខ្ញុំបានសម្រេច យើងបានសួរព្រមព្រៀងខាងក្រោមហើយអស់ហើយ បានយើងស្នើតំបន់។ ខាងក្រោមអត់ព្រមព្រៀង ក៏អត់ប៉ានដែរ។ បានខាងក្រោមហ្នឹង ដូចថាសាមីខ្លួនទាំងពីរហ្នឹងព្រមព្រៀងអីចឹង យើងសរសេរអក្សរលាយលក្ខណ៍ឈ្មោះក ឈ្មោះខ ឈ្មោះគ អ៊ីចឹងទៅ យើងស្នើឲ្យគាត់។ បើគាត់ថា ឥឡូវ បើខាងក្រោម -- ខាងហ្នឹងគេមានការសម្រេចចិត្តទាំងពីរអ្នកហើយ ខាងតំបន់ក៏អត់មានបញ្ហាដែរ។ ប៉ុន្តែមិនមែនថា ដូចប្អូនខ្ញុំ អាហ្នឹងផ្សេង អ្នកដទៃផ្សេង។ យើងសួរដែរ មិនមែនថាយើងចេះតែការទេ។

**ស៖** តើមានច្បាប់ទម្លាប់អីដែលកំណត់ថាអ្នកណាត្រូវរៀបការជាមួយអ្នកណាទេ? តើជនជាតិចាម និងជនជាតិវៀតណាម អនុញ្ញាតឲ្យរៀបការជាមួយជនជាតិខ្មែរទេ?

**ឆ៖** សម័យនោះមានតើ។ ជនជាតិចាមអីមានការមួយខ្មែរដែរតើ។ ប៉ុន្តែចំពោះវៀតណាម ខ្ញុំមិនដឹងថាមាន ឬក៏អត់ ខ្ញុំវាអត់ច្បាស់លាស់ដែរ ប៉ុនបើចាម គឺមាន។ ខ្ញុំមិនបានតាមដានល្អិត។

[១១:៣០:៣៣]

**ស៖** ខ្ញុំសូមអានសក្ខីកម្មដែល វ៉ាន់ បានឆ្លើយនៅថ្ងៃទី១៤ ខែមករា ២០១៦ នៅម៉ោង ១៤:២៦ វិនាទី មានសំណួរសួរថា៖ "តើមានច្បាប់កំណត់ថា អ្នកណាត្រូវរៀបការ កំណត់រៀបការជាមួយអ្នកណាទេ?" គាត់ឆ្លើយដូចតទៅ សូមដកស្រង់៖ "ខ្មែរត្រូវរៀបការជាមួយខ្មែរ ចាមត្រូវរៀបការជាមួយចាម។ គាត់មិនចង់ឲ្យមានការរៀបការដោយមានធាតុចម្រុះគ្នាយ៉ាងដូច្នេះទេ។" បន្តទៅទៀត សូមដកស្រង់៖ "តាមដែលខ្ញុំយល់ គេមិនចង់ឲ្យមានឈាមជ័រកាត់គ្នាចេញពីអាពាហ៍ពិពាហ៍នេះទេ។" បញ្ចប់ [redacted] លោកស្រី តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកស្រីទេ? តើត្រឹមត្រូវទេ ដែលថាចាមត្រូវរៀបការតែជាមួយនឹងចាមគ្នាឯង ខ្មែររៀបការតែជាមួយនឹងខ្មែរទេ?

**ឆ៖** បើសិនជាយើងយកជនជាតិចាម ថាការឲ្យជាមួយខ្មែរ។ សំណួររបស់លោកស្រី វ៉ាន់។ ខ្ញុំ

មានឃើញនៅកំពត កាលខ្ញុំនៅ៣៥ មានការជាមួយចាមដែរតើ មិនមែនអត់ណា។ ហេតុនេះ បើស្រឡាញ់ចាម ការឲ្យមួយចាម។ ហើយដល់ទៅនៅកំពង់សៀម គាត់លើកមតិនេះឡើង [redacted] រឿងនេះប្រហែលជាលោកស្រី វ៉ាន់ គាត់ដឹង ឬក៏ខ្ញុំមិនបានដឹង! នេះខ្ញុំសូមជម្រាបអ៊ីចឹង។

[១១:៣៣:៣២]

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ។ បាត ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនៅវេលាម៉ោងមួយកន្លះរសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោមឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកស្រីសាក្សី យើងបាននិយាយគ្នាអំពីការរៀបការនៅក្នុងស្រុករបស់លោកស្រី ហើយបន្តទៅនេះ ខ្ញុំនឹងសួរលោកស្រីអំពីចម្លើយរបស់ វ៉ាន់ ដែលជាសមាជិកគណៈកម្មាធិការឃុំរអាង។ សំណួររបស់ខ្ញុំសួរថានៅពេលដែលលោកស្រីធ្វើជាលេខាស្រុកកំពង់សៀម តើលេខាតំបន់ឈ្មោះ អាន ហ្នឹងធ្លាប់ដែលផ្ដល់យោបល់យល់ស្របឲ្យរៀបការរវាងខ្មែរនិងចាមដែរទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** បញ្ហានេះ ខ្ញុំឆ្លើយ បើថាការរៀបការនេះគាត់ធ្លាប់បានផ្ដល់យោបល់ឲ្យខ្ញុំដែរ រៀបការចាមនិង-- ចាមនិងខ្មែរ ចាមនិងចាមក៏មានដែរ។ គាត់ធ្លាប់ផ្ដល់យោបល់ឲ្យខ្ញុំ។

**ស៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**អ្នកបកប្រែ៖**

លោកប្រធានស្ដាប់អត់ឮគាត់ អត់បានបក។ បាទ ជម្រាបលោកប្រធាន ក្បាលមីក្រូបើកតែអ្នកបកប្រែស្ដាប់អត់ឮ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** [redacted]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** [redacted]

**ស៖** [redacted]

**ឆ៖** [redacted]

**ស៖** [redacted]

ឆ៖ [redacted]

ស៖ អ៊ីចឹងតើលោកស្រីនៅនឹកឃើញទេថាគូប្តីប្រពន្ធបែបនោះធ្លាប់រស់នៅត្រង់កន្លែងណាដែរ?

ឆ៖ ប្តីប្រពន្ធបែបនោះ ខ្ញុំចាំមិនបាន មិនដឹងជានៅកន្លែងណា នៅក្នុងឃុំណា ភូមិណា ខ្ញុំចាំអត់បាន។

[១៣:៣៧:៤០]

ស៖ តើការរៀបការចម្រុះពូជសាសន៍នៅក្នុងស្រុកកំពង់សៀម គឺការរៀបការទ្រង់ទ្រាយធំប្រារព្ធធ្វើឡើងនៅឯណា? ហើយបើមានធ្វើបែបហ្នឹង តើអ្នកណាជាអ្នកទៅធ្វើអធិបតីភាពក្នុងពេលរៀបការក្នុងទ្រង់ទ្រាយធំចម្រុះជាតិសាសន៍បែបនេះ?

ឆ៖ តាមខ្ញុំដឹង សម័យនោះមិនមានអាចរៀបជាទ្រង់ទ្រាយធំៗទេ គឺធ្វើតាមដែលលទ្ធភាពដែលយើងមាន។ វាមួយទៀត រៀបចំបើថានៅក្នុងឃុំណា គឺយកមេឃុំហ្នឹងធ្វើអធិបតី។ ភូមិណា ក្នុងភូមិហ្នឹងគឺយកមេឃុំហ្នឹងជាអធិបតី អត់មានរៀបជាទ្រង់ទ្រាយធំទេ។

ស៖ [redacted]

ឆ៖ [redacted]

[១៣:៤១:១៣]

សៈ [redacted]

ឆៈ [redacted]

សៈ [redacted]

ឆៈ កាលនោះ ខ្ញុំមិនបានចាំទាំងអស់ទេ តែមិនដឹងថាគាត់បានប្រកាស ឬក៏មិនប្រកាស។ ខ្ញុំមិនបានចាំទាំងអស់ទេ ព្រោះអារឿងទាំងអស់នេះ គឺខ្ញុំសូមនិយាយស្មោះត្រង់ ព្រោះការហើយ ខ្ញុំក៏ហើយៗ ក៏មិនបានថា ពូអាន គាត់ប្រកាស មិនប្រកាស ក៏ខ្ញុំមិនបានដឹងដែរ។ វាអត់មាន អត់បាននឹកឃើញអារឿងហ្នឹងទេ។

[១៣:៤៤:១៧]

សៈ ចុះមានអ្វីកើតឡើងចំពោះគូស្រករដែលបដិសេធមិនព្រមរួមដំណេកជាមួយគ្នា?

ឆៈ ឥឡូវ ខ្ញុំនិយាយថា បដិសេធថាមិនរួមរស់នៅជាមួយគ្នាទៅ ក៏ខ្ញុំមិនប៊ានថា។ ឥឡូវ ថារួមដំណេកជាមួយគ្នា ក៏ខ្ញុំមិនប៊ានថាដែរ ប៉ុន្តែបើតាមជាគំនិតរបស់ខ្ញុំ ខ្ញុំថាដូចជាមិនមានបញ្ហាអីដែលទំនាស់ក្នុងគ្រួសារហ្នឹងទេ ព្រោះការហើយទៅហើយ បើកាលមុនការអាហ្នឹងយើងទំនាស់គ្នា តែបើការហើយ គឺគាត់ស្រលាញ់គ្នា បានគាត់យកគ្នា។ អាហ្នឹងជាគំនិតរបស់ខ្ញុំទេ ហើយខ្ញុំក៏មិនដែលឮថាប្រជា

ជនទាស់គ្នាពីរឿងចុះដំណោក មិនចុះដំណោកក៏មិនមាន សូម្បីតែចាមក៏អ៊ីចឹង ខ្មែរក៏អ៊ីចឹង។ អានេះខ្ញុំនិយាយឱ្យឃើញ តែបើមានចម្លើយក្រៅពីហ្នឹងទៀត ខ្ញុំក៏--។

**សៈ** [redacted]

លោកស្រីសាក្សី ក្នុងឋានៈលោកជា -- លោកស្រីជាលេខាស្រុក តើលោកស្រីមានសិទ្ធិអំណាចសម្រេចធ្វើយ៉ាងម៉េចដែរចំពោះគូស្រករដែលមិនព្រមរួមដំណោកជាមួយគ្នា? ហើយដែលគូស្រកហ្នឹងត្រូវបានកម្រិតផ្សេងៗហ្នឹង គេជម្រាបមកលោកស្រីហើយនោះ?

[១៣:៤៧:២៧]

**ឆៈ** ខ្ញុំ ចំពោះគូស្រករមិនរួមដំណោក ខ្ញុំអត់មានវិធានការអីដែលធ្វើឱ្យគូស្រករទាំងពីរនាក់នោះបាត់បង់អីទេ មានតែការអប់រំនៅក្នុងស្រុក ដើម្បីឱ្យគូស្រករទាំងពីរនោះចេះយល់ចិត្ត យល់គំនិតគ្នាព្រោះយើងការរួចហើយ តែថាឱ្យយកគូស្រករទាំងពីរនាក់នេះ ខ្ញុំជាចៅហ្វាយស្រុកដែលគាត់មិនបានរួមដំណោក ហើយយកគាត់ធ្វើបាបធ្វើទោស គឺអត់មាន។

**សៈ** សូមអរគុណលោកស្រីសាក្សី។ ឥឡូវខ្ញុំសូមចូលទៅប្រធានបទថ្មីមួយទៀត។ ខ្ញុំសួរពេលវេលាពាក់ព័ន្ធទៅនឹងពេលដែលគេបញ្ជូនលោកស្រីពីតំបន់៣៥ កំពត ហើយភូមិភាគនិរតី ទៅភូមិភាគកណ្តាល ឬភូមិភាគឧត្តរចាស់។ ទី១ មុនពេលគេបញ្ជូនលោកស្រីចេញពីកំពត ទៅភូមិភាគកណ្តាល តើលេខាភូមិភាគ តាម៉ុក នេះមានបានហៅលោកស្រីប្រជុំទេ? ហើយបើមានហៅប្រជុំ សូមលោកស្រីជម្រាបជូនតុលាការថា នៅក្នុងអង្គប្រជុំជាមួយ តាម៉ុក ហ្នឹង គឺគេនិយាយអំពីអ្វីខ្លះ?

**ឆៈ** ខ្ញុំសូមជម្រាបអំពីបញ្ហា ខ្ញុំបានចេញពីកំពតទៅនឹងកំពង់ចាម តែខ្ញុំសូមជម្រាបថា ចម្លើយទាំងពីរនេះ ខ្ញុំសូមនិយាយតែរឿង កង ចាប ទេ។ ចំពោះតាម៉ុក ខ្ញុំអត់បាននិយាយទេ ព្រោះគាត់អត់បានជួបខ្ញុំទេ -- ខ្ញុំសូមជម្រាបបន្តិច -- ខ្ញុំអត់បានជួបគាត់ទេ មុននឹងខ្ញុំចេញទៅកំពង់ចាម។ មានតែ កង

ចាប ដែលគាត់និយាយ គាត់ឲ្យមេការខ្ញុំមកប្រាប់ថា ឲ្យខ្ញុំហ្នឹងរៀបចំខ្លួនទៅកំពង់ចាម ហើយនិងគឺថា នីរសាររបស់ កង ចាប, តែចំពោះ តាម៉ុក គឺអត់មានទេ។ គាត់អត់បានជម្រាបខ្ញុំទេ នេះខ្ញុំនិយាយដោយការពិត។ អាហ្នឹងមួយទៀត ក៏ប្រាប់ខ្ញុំហើយ ខ្ញុំក៏មិនថាអី ក៏មិននិយាយអីដែរ ក៏ខាងលើចាត់តាំង ខ្ញុំគោរពធ្វើតាមខាងលើ។ ហេតុនេះបើគាត់ឲ្យនីរសារគាត់មកប្រាប់ថា ត្រូវរៀបចំទៅកំពង់ចាម ខ្ញុំទៅ តែឲ្យខ្ញុំទៅជួបមួយ តាម៉ុក នេះអត់មានសោះ។ បើជួបមួយ កង ចាប គាត់ហៅខ្ញុំទៅជួបនៅកំពត គាត់និយាយថា "ត្រូវទៅកំពង់ចាម", ខ្ញុំថា "ហេតុអីបានដកខ្ញុំទៅកំពង់ចាម? ខ្ញុំក៏មិនយល់បញ្ហាសោះ", គាត់ថាគាត់អត់ដឹងដែរ ព្រោះខាងលើបញ្ហា។ ហើយខ្ញុំក៏ឈប់មាត់ត្រឹមហ្នឹងទៅ ក៏ខ្ញុំរៀបចំរបស់របបសម្ភារៈដែលខ្ញុំត្រូវចេញ គាត់ឲ្យខ្ញុំចេញ តែមិនទាន់ដល់ថ្ងៃកំណត់ដែលត្រូវចេញទេ។ នេះខ្ញុំសូមជម្រាបលោក។ តែចំពោះ តាម៉ុក មិនដឹងថា មកជួបខ្ញុំនៅកន្លែងណា ទីណា ខ្ញុំអត់បានជួបគាត់ទេ។ បើចំពោះ តាចាប ឲ្យនីរសារមកប្រាប់ ខ្ញុំក៏ជួបគាត់មែន។ គាត់ថា ខ្ញុំទៅកំពង់ចាមមែន។ ឯចំពោះភូមិភាគ ខ្ញុំអត់បានជួបគាត់ទេ។

**ចៅក្រម ក្ដូខា ហ្វេនស៍៖**

លោកសហព្រះរាជអាជ្ញារង ស្ដាប់លោកមិនឮទេ។

[១៣:៥១:៤៤]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** [redacted]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** [redacted]

[redacted] បើសិនជាខ្ញុំជួប តាម៉ុក តែរឿងប្ដីចាប់នេះទេ។ តែចំពោះខ្ញុំឡើងទៅកំពង់ចាម ខ្ញុំអត់បានជួបគាត់ និងមកប្រជុំតាកែវទៀត។ ខ្ញុំខ្លាចថាច្រឡំថាខ្ញុំនេះ កាលខ្ញុំមុននឹងប្ដីចាប់ តាម៉ុក ហៅខ្ញុំពីភូមិភាគកណ្ដាលទៅភូមិភាគនិរតី ខ្ញុំបានជួបគាត់មែន។ តែដល់សំណួរនេះ ខ្ញុំដូចជាមិនយល់ ហើយក៏ដូចជាខ្ញុំមិននឹកឃើញ ព្រោះខ្ញុំអត់បានជួបទេមុននឹងទៅកំពង់ចាម គឺបានជួបតែជាមួយតែ ចាប ទេ។ តាចាប បានប្រាប់ខ្ញុំ ហើយជាមួយតាម៉ុក ខ្ញុំជួបតែរឿងប្ដីចាប់ ខ្ញុំជួបពិតប្រាកដ។ ខ្ញុំទៅដេកនៅនិរតី គឺមួយយប់។ [redacted]

[១៣:៥៤:៤០]

**ស៖** មិនថ្វីទេលោកស្រីសាក្សី។ ដំណើររបស់លោកស្រីពីខេត្តកំពតទៅខេត្តកំពង់ចាម នៅពេលធ្វើដំណើរនុ៎ង តើលោកស្រីមានឈប់នៅភ្នំពេញទេ? ហើយបើបានឈប់នៅភ្នំពេញ តើលោកស្រីស្នាក់នៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំមកពីកំពត ខ្ញុំបានមកឈប់នៅភ្នំពេញ ឈប់ភ្នំពេញនេះឈប់កន្លែងដែលរបស់ភូមិភាគកណ្ដាល ខ្ញុំឈប់បានមួយយប់។ ប៉ុន្តែខ្ញុំសូមជម្រាបថា ខ្ញុំបានលើកបញ្ហាអ៊ីចឹង [redacted] ប៉ុន្តែការពិត ខ្ញុំមកឈប់នៅកំពង់ចាម -- អ៎! ឈប់នៅកន្លែងភូមិភាគ មួយយប់ហ្នឹង ដើម្បីចេញមកកំពង់ចាម។

**ស៖** នៅពេលលោកស្រីស្នាក់នៅភ្នំពេញតើមានការប្រជុំជាមួយថ្នាក់ដឹកនាំដែលស្នាក់នៅភ្នំពេញដែរទេ?

**ឆ៖** កាលខ្ញុំមកពីនិរ -- កាលមកពីតំបន់៣៥ ខ្ញុំមកស្នាក់នៅហ្នឹង ព្រោះផែនការហ្នឹងរៀបចំមកពីកំពត ហើយថាត្រូវចេញ មកស្នាក់នៅកន្លែងមន្ទីរភាគ។ ហេតុនេះអត់មានអ្នកណាមកប្រជុំជាមួយខ្ញុំ ដើម្បីរៀបរយកម្លាំងហ្នឹងចេញទៅ គឺថាព្រលឹមឡើងឃើញដឹកចេញទៅ ហើយខ្ញុំអត់បានចូលប្រជុំកន្លែងណាទៀត។ ប៉ុនគ្រាន់ ខ្ញុំភ្លេចភ្លាំងយ៉ាងម៉េច ខ្ញុំមិនច្បាស់ដែរ។

**ស៖** [redacted]

[redacted] តើចំណុចនេះ ជួយរំឮកដល់ការចងចាំរបស់លោកស្រីទេថា មានការប្រជុំជាមួយកម្មាភិបាលជាន់ខ្ពស់នៅពេលលោកស្រីស្នាក់នៅទីក្រុងភ្នំពេញ?

[១៣:៥៨:២៤]

**ឆ៖** កាលខ្ញុំស្នាក់នៅទីក្រុងភ្នំពេញ ខ្ញុំអត់បានប្រជុំជាមួយថ្នាក់កំពូលផង។ បើប្រជុំជាមួយ [redacted]ជាមួយ កែ ពក អាហ្នឹងមកប្រជុំនៅកំពង់ចាម តែជាមួយភ្នំពេញ ខ្ញុំអត់បានចូលរួមប្រជុំទេ។ អានេះ ខ្ញុំនិយាយ ព្រោះកាលនេះ ខ្ញុំមក ខ្ញុំដេកនៅកន្លែងហ្នឹង ហើយរឿង តាពក រឿង[redacted]គាត់ប្រជុំឬក៏យ៉ាងម៉េច ខ្ញុំអត់បានប្រជុំដែរ ខ្ញុំបានទៅប្រជុំនៅកំពង់ចាម តែចំពោះភ្នំពេញ ខ្ញុំអត់បានប្រជុំទេ មុននឹងចេញទៅកំពង់ចាម។

**សៈ** [redacted]

[១៤:០១:១២]

**ប្រធានអង្គជំនុំ៖**

[redacted]

**កញ្ញា អង់តា ហ៊្គីសសេ៖**

[redacted]

[១៤:០២:០៣]

**លោក ឌេល លីសាក់៖**

[redacted]

**សួរដោយលោក ឌេល លីសាក់៖**

សៈ ជាដំបូង ថាតើអ្នកស្រីសាក្សី អ្នកស្រីធ្លាប់ឃើញ ខៀវ សំផន ជិះឡានក្រុងដែរឬទេ? តើអ្នកស្រីធ្លាប់ជួបនូវហេតុការណ៍ដែលថាឃើញ ខៀវ សំផន ជិះនៅលើឡាន នៅលើរថយន្តក្រុងដែរឬទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមចម្លើយ រឿងដែលខ្ញុំបានឃើញ និយាយរួមលោក ខៀវ សំផន ខ្ញុំមិននិយាយថាយ៉ាងម៉េចទេ ប៉ុនដូចលោកស្រី វ៉ាន់ បានលើក យកខ្ញុំទៅប្រជុំនៅភ្នំពេញ ប្រជុំជាមួយ ខៀវ សំផន។ រឿងនេះខ្ញុំសុំជំទាស់ ព្រោះខ្ញុំវាអត់បានប្រជុំជាមួយគាត់សោះ នេះខ្ញុំសូមជំទាស់មែន ព្រោះលោកស្រី វ៉ាន់ កាលនោះតូចតើ គាត់ទៅតាមខ្ញុំហ្នឹង ឥឡូវហេតុអីបានគាត់ដឹងរឿង គាត់មិនមែនថា តូចហើយក៏គាត់មិនមែនដឹងថារឿងទៅប្រជុំភ្នំពេញ ប្រជុំជាមួយ ខៀវ សំផន ជាមួយតាពក ជាមួយអី។ ខ្ញុំថាដូចជាខ្ញុំមិនទាន់យល់ស្រប។ ហើយខ្ញុំមិនបានឃើញលោក ខៀវ សំផនហ្នឹង ជិះឡានក្រុង ជិះអីខ្ញុំអត់បានឃើញទៀត ហើយបើសិនជាខ្ញុំយកមកលើកក្នុងអង្គជំនុំនេះ ខ្ញុំចេះតែនិយាយទទេ ក៏វាអត់សមរម្យ ការពិតលោកស្រី វ៉ាន់ ដឹងជាងខ្ញុំទៅទៀត។ នេះខ្ញុំសូមលើកនៅកណ្តាលសាលាជំនុំទៅចុះ។ ហើយការគាត់ជិះឡានក្រុងអីខ្ញុំអត់បានឃើញផងហ្នឹង។ ហេតុនេះកាលនោះ ខ្ញុំមិនបានទៅប្រជុំជាមួយ ខៀវ សំផន ហ្នង។ បញ្ហានេះ ខ្ញុំសូមជំទាស់ទៅចុះ ព្រោះខ្ញុំវាអត់បាន ពិតគឺការពិតតែម្តង។ ហើយលោកស្រីបានលើកនេះ ខ្ញុំអត់មានការចាប់អារម្មណ៍ទេ ព្រោះកាលនោះគាត់តូច ហើយគាត់ម៉េចក៏ដឹងរឿងច្រើនជាងខ្ញុំទៅទៀត។ តែរឿងនេះខ្ញុំគ្រាន់ថាលើកទេ មិនមែនថាខ្ញុំនេះបដិសេធអី អត់ទេ គ្រាន់ថាខ្ញុំចង់ថាវាមិនជាក់ស្តែង ហើយក៏វាមិនច្បាស់លាស់ដែរ ព្រោះខ្ញុំចេញទៅកំពង់ចាមហ្នឹង គាត់នៅតូចតើ គាត់ទៅជាមួយខ្ញុំតើ ហើយគាត់ម៉េចក៏ដឹងរឿងច្រើនជាងខ្ញុំទៅទៀត នេះខ្ញុំចង់ឆ្លល់ត្រង់នេះ។ អ៊ីចឹងសូមឲ្យជួយវែកញែកបញ្ហានេះឲ្យច្បាស់លាស់ដែរ កុំឲ្យថាខ្ញុំនេះពង្វាងពង្វៃ ខ្ញុំហ្នឹងមិននិយាយឲ្យអស់។ ការពិតទៅរឿងដែលលោកបានសួរខ្ញុំនេះ ខ្ញុំចេះតែអង្គុយក្នុងចិត្តនឹកឃើញដែរ តែវាអត់មានឃើញក្នុងការប្រជុំនៅភ្នំពេញហ្នឹងសោះ ហើយប្រជុំជាមួយ ខៀវ សំផន ហើយក៏ខ្ញុំមិនបានឃើញគាត់ជិះឡានក្រុងហ្នឹងទៀត ហើយបើខ្ញុំនិយាយទៅ វានិយាយទទេដដែលហ្នឹង វាអត់មានសាច់ការអីផងហ្នឹង។ នេះខ្ញុំសូមជម្រាបលោកអ៊ីចឹងតែម្តង។

[១៤:០៦:៤១]

**ស៖** ឥឡូវនេះ ខ្ញុំនឹងសួរព័ត៌មានបន្ថែមទៀតពីកម្មាភិបាលម្នាក់មកពីពាយ័ព្យ។ តើអ្នកស្រីស្គាល់កម្មាភិបាលម្នាក់ឈ្មោះឈឹម -- ជឹម ដែលជាលេខាស្រុកត្រាំកក់ដែរឬទេ? ហើយនិងម្នាក់ទៀត ឈ្មោះកម្មាភិបាល សាន់ មកពីខាងនិរតីកំពង់ចាម តើអ្នកស្រីឈ្មោះ -- ស្គាល់ឈ្មោះ ជឹម នេះទេ?

**ឆ៖** ខ្ញុំស្គាល់ឈ្មោះ ជឹម ស្រុកកំណើតគាត់នៅតាកែវ តែខ្ញុំបានតែស្គាល់ទេ តែការពិត គាត់មិនដឹងធ្វើការនៅកន្លែងណា ខ្ញុំបែកគាត់រហូត។ ខ្ញុំបានស្គាល់គាត់កាលនៅ ជំនាន់ខ្ញុំនៅកំពង់ចាម គាត់នៅ

ចម្ការកៅស៊ូជប់ ខ្ញុំស្គាល់កាលហ្នឹងទេ។ តែក្រោយមក តាំងពីថ្ងៃនោះមកដល់ថ្ងៃនេះ ខ្ញុំមិនបានទាក់ទងគាត់ទេឈ្មោះ ជឹម ហ្នឹង។ ហើយឈ្មោះមួយទៀតនោះ ឈ្មោះអី? សូមលោកបញ្ជាក់ឈ្មោះមួយទៀត ជឹមមួយ ឈ្មោះអីមួយទៀត?

**សៈ** ប្រហែលជាដោយសារការបកប្រែ ព្រោះខ្ញុំនិយាយតែម្នាក់ទេ គឺឈ្មោះ ជឹម គឺជាលេខាស្រុកត្រាំកក់នៅពេលដែលគេបញ្ជូនគាត់ទៅភូមិភាគកណ្ដាល ហើយគាត់ក្លាយទៅជាប្រធានចម្ការកៅស៊ូ គាត់មិនមែនជាក្មេងស្រីម្នាក់ទេ គាត់ជាលេខាស្រុក ហើយគាត់ផ្ដល់ចម្លើយនៅក្នុងចម្លើយស្ដាប់ចម្លើយរបស់គាត់ គឺថាក្រុមដែលគាត់ទៅជាមួយហ្នឹង គឺរួមមានលោកស្រី ហើយនិងតាអាន ហើយគាត់បានរៀបរាប់យ៉ាងលម្អិតអំពីការប្រជុំនៅក្នុងទីក្រុងភ្នំពេញនៅពេលដែលឈប់សម្រាកនៅទីនោះ។ ហើយក្នុងកិច្ចប្រជុំហ្នឹងគឺមាន ប៉ុល ពត ហើយនិង នួន ជា បានចូលរួម ហើយក្នុងការប្រជុំហ្នឹងគឺបានពិភាក្សាអំពីស្ថានភាពភូមិភាគ។ ឥឡូវនេះ ខ្ញុំចង់ឲ្យលោកស្រីឆ្លើយតបទៅលើបញ្ហានេះ។ តើលោកស្រីនឹកឃើញទេថា មានកិច្ចប្រជុំមួយដែលអ្នកស្រីធ្លាប់ចូលរួម ឬក៏អ្នកស្រីធ្លាប់ឮ។ គឺការប្រជុំនៅក្នុងទីក្រុងភ្នំពេញដែលដឹកនាំដោយ ប៉ុល ពត ហើយនិង នួន ជា ហើយមានការចូលរួមកម្មាភិបាលនិរតីដែលត្រូវគេបញ្ជូនទៅខាង ទៅភូមិភាគផ្សេង?

[១៤:០៩:៣៦]

**ធៈ** ខ្ញុំសូមសួរចម្លើយ តាជឹម។ កាលហ្នឹងគ្រាន់តែ ខ្ញុំមិនបាន គាត់នៅក្នុងស្រុកកំពង់សៀមដែរ ឬក៏យ៉ាងម៉េច ព្រោះកាលខ្ញុំនៅកំពង់សៀមក៏មិនឃើញ -- អត់ឃើញៗ ឈ្មោះជឹម ហ្នឹងនៅជាមួយខ្ញុំផង ហើយកាលខ្ញុំធ្វើដំណើរទៅក៏ខ្ញុំអត់បានឃើញ តាជឹម ដែរ ហើយឥឡូវគាត់លើកថាបានប្រជុំជាមួយ ប៉ុល ពត, ជាមួយ នួន ជា។ តើប្រជុំ -- កាលហ្នឹង តាជឹម គាត់ទៅនៅកន្លែងចំការកៅស៊ូជប់ទេ គាត់មិនបានចូលរួមភូមិភាគកណ្ដាលទេដឹង! ទេម៉េច ខ្ញុំមិនបានច្បាស់ដែរ។ ហើយបើសិនជា តាជឹម ហ្នឹង គាត់និយាយអ៊ីចឹង គាត់ចូលរួមប្រជុំនៅក្នុងភ្នំពេញ គាត់ឃើញខ្ញុំ ឃើញតាអាន។ ខ្ញុំចង់ដឹងដែរបញ្ហានេះ។ តែខ្ញុំមិនបានឃើញឈ្មោះ ជឹម ហ្នឹងទេ ហើយគាត់ក៏មិនដឹងទៅពីថ្ងៃណា ខែណា ទៅនៅកន្លែងចំការកៅស៊ូជប់ហ្នឹង ខ្ញុំវាអត់បានដឹងដែរ ហើយដល់ពេលប្រជុំ ខ្ញុំក៏មិនបានរួមដំណើរជាមួយគាត់ដែរ។ នេះខ្ញុំ និយាយនេះមិនមែនចង់និយាយថា ឆ្លើយដើម្បីខ្លួនខ្ញុំទេ តែការពិត ខ្ញុំវាអត់បានឃើញ ហើយឈ្មោះ ជឹម ហ្នឹង វាមិនបានចូលរួមជាមួយខ្ញុំដែរ ព្រោះខ្ញុំទៅនេះ ខ្ញុំអត់បានឃើញឈ្មោះ ជឹម ហ្នឹងទេ ព្រោះគាត់មិនដឹងខាងលើរៀបចំឲ្យគាត់ទៅនៅចំការកៅស៊ូជប់អីយ៉ាងម៉េច។ នេះ ខ្ញុំសូមចម្លើយខ្ញុំប៉ុណ្ណឹងសិន

ហើយយ៉ាងម៉េច--

[១៤:១១:៣៣]

**ស៖** អ្នកស្រីសាក្សី ខ្ញុំរំឭកអ្នកស្រីបែបនេះ ដើម្បីសង្ឃឹមថាអ្នកស្រីនឹកឃើញបានខ្លះ។ ប៉ុន្តែ សក្ខីកម្មរបស់ពួកគាត់ គឺដូចអ្នកស្រីដែរ គឺថាគេបញ្ជូនគាត់ពីខាងនិរតីមកកំពង់ចាម។ ហើយក្នុងពេលដែលគាត់ធ្វើដំណើរទៅកាន់តួនាទីថ្មីរបស់គាត់ គឺថាគាត់ឈប់នៅទីក្រុងភ្នំពេញ ហើយចូលរួមក្នុងកិច្ចប្រជុំ ដែលចូលរួមដោយខាងនិរតី។ ដូច្នេះ ខ្ញុំអាចនិយាយថាអ្នកស្រីមិនដែលចូលរួមការប្រជុំទេ ប៉ុន្តែខ្ញុំចង់សួរថា តើអ្នកស្រីធ្លាប់ឮការប្រជុំនៅភ្នំពេញដែលដឹកនាំដោយ ប៉ុល ពត ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំចង់ឲ្យមានការនិយាយយោងឲ្យបានច្បាស់លាស់អំពីសក្ខីកម្មរបស់ ពេជ្រ ជឹម នេះ។

**លោក ឌេល លីសាក់៖**

មិនមានបញ្ហាអ្វីនោះទេ គឺឯកសារ E3/9462 នៃសំណួរចម្លើយទី១។

[១៤:១២:៤១]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ពេជ្រ ជឹម បានផ្ដល់ឆ្លើយដូចតទៅនេះ៖ "ខ្ញុំបានស្គាល់ តាអាន តាំងពីឆ្នាំ៧៧។ នៅពេលដែលខ្ញុំត្រូវបានគេបញ្ជូនទៅជាមួយ ប្រាក់ យុត, តាអាន, សាន, ស៊ីម ទៅភូមិភាគកណ្ដាល។ នៅក្នុងខែមេសា ឆ្នាំ៧៧ គឺពួកគេបានបញ្ជូនយើងទៅភ្នំពេញ ហើយបានជួប កែ ពក ហើយ កែ ពក បានបញ្ជូនយើងទៅកំពង់ចាម។" ហើយបន្ទាប់មកទៀត ក៏បានរៀបរាប់អំពីការប្រជុំនៅក្នុងទីក្រុងភ្នំពេញ ដែលកម្មាភិបាលទាំង១០ ដែលមកពីខាងភូមិភាគនិរតីបានចូលរួមនៅក្នុងកិច្ចប្រជុំនោះ ហើយគាត់បានរៀបរាប់អំពីព័ត៌មានលម្អិត គឺនៅក្នុងឯកសារ E3/9487 ដើម្បីជាកំណត់ត្រាប្រតិចារឹក។ លោកស្រីសាក្សី ដូច្នេះ ខ្ញុំចង់សួរថាតើអ្នកស្រីចាំ ឬក៏មិនចាំ អំពីការប្រជុំទាំងអស់នេះ? តើអ្នកស្រីធ្លាប់ឮអំពីការប្រជុំដែលដឹកនាំដោយ ប៉ុល ពត និង នួន ជា នៅក្នុងទីក្រុងភ្នំពេញ គឺការប្រជុំសម្រាប់កម្មាភិបាលនិរតីដែលត្រូវបញ្ជូនតដែរឬទេ?

**លោកស្រី ប្រាក់ យុត៖**

**ធ៖** ខ្ញុំសូមឆ្លើយសំណួរ។ ខ្ញុំមិនដឹងដែរ តែរឿងការប្រជុំនៅភ្នំពេញ ខ្ញុំបានឮ បានដឹង គាត់ប្រជុំ។ តែចំពោះខ្ញុំ វាកាលនោះវាមិនទាន់មានឋានៈអីបានឡើងទៅប្រជុំដល់ភ្នំពេញទេ។ ព្រោះខ្ញុំ ដូចជាហៅថានៅស្រុកកំពត សមាជិកទី៤អីអ៊ីចឹង ហើយខ្ញុំគ្រាន់តែថា ឃើញៗទាំងអស់គ្នា ព្រោះយើងទៅជួបជុំគ្នានៅកន្លែងហ្នឹង ដូចតាជឹម គាត់លើកអ៊ីចឹង គាត់ឃើញមែន។ តែការប្រជុំ ខ្ញុំមិនបានប្រជុំទេ។ ហើយការឮប្រជុំនៅភ្នំពេញ ខ្ញុំបានឮ មិនមែនថាមិនឮ ខ្ញុំឮតើ ខ្ញុំដឹង គ្រាន់ថាបានប្រជុំ។ តែថាប្រជុំបញ្ហាអីៗ ខ្ញុំអត់ដឹង។

[១៤:១៥:២៣]

**ស៖** ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទចុងក្រោយរបស់ខ្ញុំ។ ក្នុងនាមជាលេខាស្រុក ហើយនិងក្នុងនាមជាសមាជិកគណៈតំបន់ ទាំងនៅក្នុងស្រុកកំពង់សៀម ឬក៏នៅខេត្តកំពត ខ្ញុំចង់សួរថាតើអ្នកស្រីត្រូវបានគេតម្រូវឲ្យចូលរួមក្នុងវគ្គរៀនសូត្រនយោបាយនៅទីក្រុងភ្នំពេញដែរឬទេ?

**ធ៖** ខ្ញុំនៅខេត្តកំពត នៅកំពង់ចាម នៅខេត្តកំពត ជួនកាលខ្ញុំបានមកៗម្ដងម្បាមដែរ។ បើនៅកំពង់ចាមក៏អ៊ីចឹងដែរ ព្រោះកាលណាហៅគណៈតំបន់៣ ដែលដើរតួ។ អ៊ីចឹងខ្ញុំជាសមាជិកក៏មិនសូវបានជាប់លាប់ទេជាមួយខាងលើ បើទៅរៀនទៅអី គឺបានម្ដងម្បាម ដូចថា កាលណាគេហៅទាំងប្រាំនាក់អ៊ីចឹង ខ្ញុំបានចូលខ្លះ -- អ៊ំ! បានចូលដែរ។ បើអត់ហៅសមាជិកទាំងបួននាក់អ៊ីចឹង គឺខ្ញុំអត់បានចូលទេមិនមែនទៅបានញឹកញាប់ទេ។ សំខាន់ គឺគណៈបីនាក់ដែលគណៈអចិន្ត្រៃយ៍បានចូលជាប់ ហើយចំពោះខ្ញុំម្ដងម្បាមទេ មានការចាំបាច់ អាហ្នឹងហៅខ្ញុំទៅ បើអត់ទេ ក៏អត់បានទៅដែរ។

**ស៖** មូលហេតុដែលខ្ញុំសួរអ្នកស្រីបែបនេះ ព្រោះថានៅក្នុងការជំនុំជម្រះយើងបានស្ដាប់នូវលេខាស្រុកជាច្រើនដូចអ្នកស្រីអ៊ីចឹង គឺថាក្នុងនោះ រួមមាន ពេជ្រ ជឹម ហើយនិងម្នាក់ទៀតឈ្មោះ នាង អ៊ូច ហៅ តាសាន ដែលពួកគាត់ទាំងពីរនេះ គឺជាលេខាស្រុកត្រាំកក់ ហើយនិងសាក្សីដទៃទៀត ដែលបានរៀបរាប់ ថាតើលេខាស្រុករួមទាំងពួកគេផងហ្នឹង ត្រូវបានគេតម្រូវឲ្យចូលរួមក្នុងវគ្គរៀនសូត្រនយោ-បាយប្រចាំឆ្នាំនៅភ្នំពេញ ដែលវគ្គហ្នឹងគឺគេរៀនអស់រយៈពេលរាប់សប្ដាហ៍ ហើយគេធ្វើនៅចុងឆ្នាំ។ ហើយនៅក្នុងសក្ខីកម្មកាលពីសប្ដាហ៍មុន គឺថ្ងៃ១៤ មករា ២០១៦ នៅម៉ោង១៤:៣០ ដល់ម៉ោង ១៤:៣៥ រហូតដល់១៤:៣៦ គឺមានការផ្ដល់សក្ខីកម្មថា អ្នកស្រីម្ដងម្កាលបានចូលរួមកិច្ចប្រជុំនៅភ្នំពេញ រួមបញ្ចូលទាំងវគ្គរៀនសូត្រ ដែលមានរយៈពេល១០ថ្ងៃ ឬក៏ដល់ពីរសប្ដាហ៍ឯណោះ។ ដូច្នេះ ខ្ញុំចង់សួរថា

វគ្គដែលអ្នកស្រីចូលរួមម្តងម្កាលនោះ រួមបញ្ចូលទាំងវគ្គរៀនសូត្រនយោបាយសម្រាប់លេខាស្រុកនុ៎ង គឺចាចង់និយាយអំពីវគ្គដែលធ្វើជារៀងរាល់ឆ្នាំនៅចុងឆ្នាំ អាចខែវិច្ឆិកា ធ្នូ ហ្នឹង។ តើអ្នកស្រីនឹកឃើញអំពីហេតុការណ៍នេះទេ?

[១៤:១៩:០២]

**ឆ៖** ខ្ញុំសុំចម្លើយ។ ការប្រជុំនេះ ខ្ញុំបានទៅប្រជុំ ដូចខ្ញុំបានជម្រាប ដូចថាមួយឆ្នាំអ៊ីចឹងទៅ ខ្ញុំបានទៅម្តងអ៊ីចឹងទៅ ជួនកាលក៏អត់។ ប៉ុន្តែសរុបលទ្ធផលក្នុងរយៈកាលមួយឆ្នាំអ៊ីចឹង ខ្ញុំបានចូលរួមជាមួយប្រជុំជាមួយខាងលើដែរ។ មិនមែនថាមិនដែលបានប្រជុំទេ គឺបានប្រជុំដែរ តែវាមិនបានជាប់លាប់ ដូចគណៈកម្មការ គណៈអចិន្ត្រៃយ៍ តែក្នុងហ្នឹងក៏ថាខ្ញុំបានចូលរួម ដាច់ឆ្នាំអ៊ីចឹងខ្ញុំទៅ ប្រាំ -- ១០ ថ្ងៃអី អ៊ីចឹងទៅ អាហ្នឹងខ្ញុំបានចូលរួម ដូចបានលើក។

**ស៖** ហើយវគ្គរៀនសូត្ររាល់ឆ្នាំដែលអ្នកស្រីចូលរួមនៅចុងឆ្នាំរៀងរាល់ឆ្នាំហ្នឹង តើអ្នកស្រីចាំទេថាតើវគ្គរៀនសូត្រហ្នឹង គេធ្វើនៅកន្លែងណាដែរក្នុងទីក្រុងភ្នំពេញហ្នឹង?

**ឆ៖** វគ្គរៀនសូត្ររាល់ឆ្នាំហ្នឹង ខ្ញុំក៏មិនស្គាល់ភ្នំពេញអស់ដែរកាលនោះ មិនដឹងនៅកន្លែងណាអីកន្លែងណា។ ចេះតែទៅ ដល់ហៅមករៀនចេះតែមក ប៉ុនថាឲ្យខ្ញុំស្គាល់ ខ្ញុំអត់ស្គាល់ដែរ ព្រោះខ្ញុំអត់សូវបានមកភ្នំពេញញឹកញាប់ ហើយខ្ញុំអត់ស្គាល់ដីទៀត មិនដឹងថានៅកន្លែងណា ប៉ុនខ្ញុំដឹងវគ្គទី១ ខ្ញុំរៀននៅស្តាតម្តង អាហ្នឹងមុនគេផងតាំងពី៧៥ម្ល៉េះ។ ក្រោយមកទៀត ខ្ញុំអត់ស្គាល់ មិនដឹងនៅកន្លែងណាទៀត ខ្ញុំស្គាល់តែស្តាតមួយទេ។ អាហ្នឹងមករៀនមុនគេ ប៉ុនថាក្រៅពីហ្នឹង ខ្ញុំអត់ស្គាល់អស់ទេមិនដឹងថាកន្លែងណាទេ ព្រោះភ្នំពេញខ្ញុំអត់ស្គាល់ដីដែរ ខ្ញុំមិនដែលបានមកភ្នំពេញញឹកញាប់ មិនដឹងសាលាណាខ្លះ។

**ស៖** នៅក្នុងវគ្គរៀនសូត្រដែលអ្នកស្រីបានចូលរួម តើអ្នកណាជាអ្នកឡើងថ្លែងសុន្ទរកថា? ហើយតើអ្នកណាជាអ្នកបង្រៀនអំពីនយោបាយនៅពេលនោះ?

[១៤:២១:៤៨]

**ឆ៖** អានោះ កាលអ្នកបង្រៀន ដែលគាត់អ្នកបើកវគ្គបើកអី អ៊ំប៉ុល ពតហ្នឹងឯង។ គាត់បង្រៀនតែការរៀនសម័យនោះ ខ្ញុំឃើញតែគាត់បើកវគ្គ តែការចងចាំ ខ្ញុំក៏មិនចាំអស់ដែរ ព្រោះរៀនវាមិនដឹងស្អីជាស្អី ខ្ញុំក៏មិនសូវចេះ ហើយគាត់និយាយ ខ្ញុំចេះតែកត់ទៅ ប៉ុនថាឲ្យចាំទាំងអស់តែម្តង វាអត់ចាំ។ ប៉ុនគាត់ហ្នឹងអ្នកបើកវគ្គអប់រំ ប៉ុល ពតហ្នឹងឯង។ ហើយក្រៅពីនោះទៀត មិនដឹងអ្នកណាខ្លះ ខ្ញុំក៏មិនទាន់ស្គាល់មនុស្សអស់ដែរ និយាយរួម មិនដឹងអ្នកណាមកអង្គុយជាអធិបតី ឈ្មោះអីៗ ខ្ញុំអត់ចាំអស់ដែរ។

**ស៖** អ្នកស្រីសាក្សី គឺយើងបានស្ដាប់សាក្សីមួយចំនួនអំពីបញ្ហានេះ។ ដើម្បីជួយឲ្យអ្នកស្រីនឹកឃើញឡើងវិញ ខ្ញុំសូមអានជូនអ្នកស្រីស្ដាប់នូវកំណត់ត្រាពីលេខាស្រុកចំនួនពីរនាក់ ដែលបានរៀបរាប់អំពីការប្រជុំនេះ។ ពេជ្រ ជឹម នៅក្នុងចម្លើយរបស់គាត់គឺ E3/401, ខ្មែរមានលេខ 00373478, អង់គ្លេសមានលេខ 00381028 និងបារាំងមានលេខ 00426217 បានផ្ដល់ចម្លើយដូចតទៅនេះ៖ "ខ្ញុំឃើញ នួន ជា នៅពេលដែលខ្ញុំចូលរួមរៀននៅភ្នំពេញ ហើយនៅពេលនោះ នួន ជា ជាគ្រូ។ ការបង្រៀននេះ គឺបង្រៀនគណៈស្រុកទូទាំងប្រទេស ហើយបន្ទាប់មកទៀត អតីតលេខាស្រុកគឺ តាសាន នៅក្នុងសក្ខីកម្មរបស់គាត់ នៅថ្ងៃ១០ មីនា ២០១៥ ឯកសារE3/207 បានផ្ដល់សក្ខីកម្មថា៖ "ខ្ញុំបានជួប អ៊ំនួន ជា នៅក្នុងការរៀនសូត្រប្រចាំឆ្នាំ ដែលធ្វើឡើងនៅក្នុងខែកញ្ញា ឬក៏តុលា។" ហើយក្រោយមកទៀត នៅម៉ោង១១:១៧ ដល់ ១១:២០៖ "ខ្ញុំមកភ្នំពេញរៀងរាល់ឆ្នាំដើម្បីចូលរួមវគ្គប្រចាំឆ្នាំ ហើយវាធ្វើឡើងនៅក្នុងឆ្នាំ៧៧ និងឆ្នាំ៧៨ ហើយនៅក្នុងវគ្គនេះ ខ្ញុំបានចូលរួម ហើយគ្រូបង្រៀនគឺ នួន ជា។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំចង់សួរថាតើអ្នកស្រីអាចនឹកឃើញបានដែរឬទេថា នួន ជា គឺជាអ្នកបង្រៀន អំពីនយោបាយ ហើយក៏ជាអ្នកឡើងថ្លែងនៅក្នុងវគ្គរៀនសូត្រនេះ។ តើអ្នកស្រីនឹកឃើញទេ?

[១៤:២៥:00]

**ឆ៖** ខ្ញុំសូមតបចម្លើយ ដល់ការលើកឡើងរបស់ពូជឹម ហេតុនេះវាប៉ះពាល់ដល់ខ្ញុំដែរ។ អ៊ីចឹង ខ្ញុំសូមលើកថាសំណួរនេះ យកសំណួរខាងក្រៅមកដាក់លើខ្ញុំទាំងអស់។ អ៊ីចឹងខ្ញុំការភ្លេចភ្លាំង ការចងចាំក្នុងខ្លួនខ្ញុំវាចេះតែភ្លេចហើយ ព្រោះការគាប -- ការសំណួរទាំងអស់នេះ តាមខ្ញុំស្ដាប់មើលសំណួរក្រៅច្រើនណាស់ អ៊ីចឹងការយល់ ការដឹងរបស់ខ្ញុំគឺថាវាភ្លេចដែរ។ ប៉ុន្តែឥឡូវនេះលើកសំណួរមកនេះ គឺថាតាជឹម គាត់បានអត្ថាធិប្បាយច្រើនណាស់ គាត់ស្គាល់ទាំង នួន ជា, ស្គាល់ទាំងប៉ុល ពត។ អ៊ីចឹងទៅវាលើកមកធ្វើឲ្យខ្ញុំមានការលំបាកស្មុគស្មាញក្នុងអារម្មណ៍ដែរ។ នេះខ្ញុំនិយាយត្រង់ហើយនេះ! សំណួរដែលខ្ញុំបានឆ្លើយ គឺវាមិនសំណួររបស់ខ្ញុំពិតប្រាកដមានហើយ តែមកសំណួរច្រើន សំណួរសាក្សីផ្សេងៗ។ អ៊ីចឹងការចងចាំរបស់ខ្ញុំមានការវិលវល់ក្នុងអារម្មណ៍នេះ ឥឡូវលើកជា ពូជឹម, លើកជាស្រី វ៉ាន់ អ៊ីចឹងលើកពីណាណីមក អ៊ីចឹងបានន័យថា សំណួររបស់ខ្ញុំដែលបានលើកតាំងពីព្រឹកវាចប់សព្វ--

**ប្រធានអង្គជំនុំ៖**

អ៊ីចេះទេ លោកស្រីសាក្សី អានេះជាបច្ចេកទេស និងនីតិវិធីនៃការសួរដេញដោលនៅចំពោះមុខតុលាការ នេះប្រភេទសំណួរដូច្នេះ។ អ៊ីចឹងហើយបានជាមានការផ្ទួរផ្ទង រវាងចម្លើយរបស់លោកស្រី

ដែលផ្តល់ ហើយនិងចម្លើយអ្នកដទៃទៀតដែលមានការផ្តល់ព័ត៌មានមកឲ្យអង្គជំនុំជម្រះហ្នឹងពេលមុនកន្លងមកហើយដែលវាមានពេលវេលា វាមានទីកន្លែងវាប្រហាក់ប្រហែលគ្នា ហើយប្រសិនបើលោកស្រីដឹងក៏លោកស្រីអាចឆ្លើយថាដឹងទៅ ហើយលោកស្រីថាមិនដឹង ក៏ជាចម្លើយដែរ អាហ្នឹងគេហៅថាជាចម្លើយដែរណា៎! អង្គជំនុំជម្រះមិនបង្ខំឲ្យលោកស្រីថាត្រូវតែឆ្លើយ ទោះបីមិនដឹងក៏ត្រូវឆ្លើយថាដឹងនោះទេ ប៉ុន្តែនេះជាបច្ចេកទេស និងនីតិវិធីនៃការសួរដេញដោលតាមផ្លូវតុលាការ ដែលគេប្រើពាក្យខ្មែរគឺសួរដេញដោល គឺជជីកសួរដើម្បីស្វែងរកការពិត។ ដូច្នេះលោកស្រីប្រឹងប្រែងដើម្បីផ្តង់អារម្មណ៍ស្តាប់សំណួរឲ្យបាន ហើយឆ្លើយតបនូវសំណួរនូវអ្វីដែលលោកស្រីដឹង អ្វីមិនដឹងគឺលោកស្រីឆ្លើយថាមិនដឹងទៅបានហើយ។ លោកស្រីមិនអាចតវ៉ាពីរឿងកិច្ចការផ្សេងៗដែលដាក់សម្ពាធ តាំងថាយកសំណួរផ្សេងៗ យកអង្គហេតុផ្សេងៗដែលអ្នកផ្សេងឆ្លើយនោះយកមកសួរលោកស្រីបានទេ។ ភាគីដទៃទៀតរួមទាំងអង្គជំនុំជម្រះផងគេបានប្រកាន់នូវ មានការផ្តង់អារម្មណ៍ពាក់ព័ន្ធនឹងការ រៀបចាត់ការរឿងនេះហើយ ហើយប្រសិនបើមានបញ្ហាគេឡើងជំទាស់តវ៉ារវាងភាគី ឬអង្គជំនុំជម្រះកាត់មិនឲ្យលោកស្រីឆ្លើយតបនឹងសំណួរដែលសួរឥតប្រយោជន៍នោះទេ។ លោកស្រីយល់ទេ?

[១៤:២៨:៥៩]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** លោកប្រធានបានលើក ខ្ញុំសូមយល់ស្របទាំងស្រុង។ តែតាមការគិតរបស់ខ្ញុំ ខ្ញុំអង្គុយគិតដល់អ៊ីចឹងខ្ញុំឃើញលោកប្រធាននិយាយ ខ្ញុំក៏ឯកភាពដែរ ដើម្បីជីកឫស ជីកគល់ រកកែវឲ្យឃើញ។ ក្នុងហ្នឹងខ្ញុំសូមជម្រាបពីសំណួរហ្នឹងវិញ ព្រោះគាត់បានលើកអ៊ីចឹង ខ្ញុំក៏អត់មានបញ្ហាអីទេ ព្រោះខ្ញុំជាគំនិតរបស់ខ្ញុំៗបានឃើញដូច តាជឹម ដែរ តែខ្ញុំនិយាយនេះ បើសិនជាខ្ញុំនិយាយបកមកវិញ បានន័យថាខ្ញុំហ្នឹងលាក់កំនួច ឬក៏លាក់មិនបាននិយាយ តែបើ ពូជឹម គាត់និយាយអ៊ីចឹង ខ្ញុំក៏បានចូលរួមក្នុងការប្រជុំ ការរៀនសូត្រនេះដែរ។ អ៊ីចឹងដូចថាគាត់លើកអំពី នួន ជា, អំពីអ្នករដ្ឋ -- គាត់ជាអ្នកនយោបាយ គាត់ជាអ្នកបំពាក់នយោបាយអប់រំក្នុងសាលាទាំងមូល។ អ៊ីចឹងយើងខ្ញុំក៏បានចូលរួមដែរក្នុងការប្រជុំនេះ ការរៀនសូត្រនេះ។ អ៊ីចឹងខ្ញុំអត់មានបញ្ហាអីដែលធ្វើឲ្យស្មុគស្មាញក្នុងអារម្មណ៍ទៀតទេ។ ខ្ញុំជ្រះស្រឡះ ព្រោះខ្ញុំអង្គុយគិតមកតាំងពីព្រឹក ស្មុគស្មាញដែរ។ តែខ្ញុំមកជ្រះស្រឡះ ដូចថាលោកប្រធាន បានលើក ខ្ញុំសូមឯកភាពហ្នឹង។ នេះសូមអស់មតិ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តទៅទៀត លោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកស្រីទទួលស្គាល់ថា លោកស្រីបានចូលរួមនៅក្នុងវគ្គរៀនសូត្រនយោបាយរៀងរាល់ឆ្នាំជាមួយលេខាស្រុក ដែលប៉ុល ពត ជាអ្នកបើកវគ្គនោះ។ ដូច្នេះ ខ្ញុំចង់សួរថា តើអ្នកណាជាអ្នកឧទ្ទេសនាម ឬក៏អ្នកបង្រៀននៅក្នុងវគ្គនេះ ក្រៅពី ប៉ុល ពត? តើអ្នកស្រីចាំថាតើមាន នួន ជា មានអ្នកដទៃទៀតនិយាយនៅក្នុងវគ្គរៀនសូត្រនេះទេ?

[១៤:៣១:០៥]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ពេលបើកវគ្គម្តងៗ គឺខ្ញុំនិយាយដោយការពិត គឺមានលោក ប៉ុល ពត គាត់ជាប្រធាននយោបាយ។ គាត់អ្នកឧទ្ទេសនាមមួយថ្ងៃ ពីព្រឹកទល់ម៉ោងម៉ាដណ្តប់អ៊ីចឹងទៅ។ គាត់ឧទ្ទេសនាមរហូត។ តែក្នុងហ្នឹងក៏មានលោក អ៊ំ នួន ជា ដែរ ក៏គាត់អ្នកឧទ្ទេសនាមដែរ។ នេះខ្ញុំសូមជម្រាប។ ប៉ុន្តែសំខាន់ គឺអ៊ំប៉ុល ពត គឺហ្នឹងគាត់ឧទ្ទេសនាមពីនយោបាយហ្នឹង គឺតាំងពីព្រឹកមកទល់ម៉ោងម៉ាដណ្តប់អី គាត់ឧទ្ទេសនាមរហូតអ៊ីចឹងទៅ។ តែក្នុងការងាររបស់គាត់ គាត់ចែកពេលវេលារបស់អ៊ំទាំងពីរ។ គាត់ចែកគ្នាធ្វើកិច្ចការហ្នឹង។ តែយើងខ្ញុំអង្គុយចាំតែស្តាប់ទេ។

**ស៖** សូមអរគុណអ្នកស្រី។ ឥឡូវនេះ ខ្ញុំមានសំណួរបន្តទៀត ខ្ញុំចង់សួរថាតើ ខៀវ សំផន ធ្លាប់ឧទ្ទេសនាមនៅក្នុងវគ្គរៀនសូត្រនានាដែលអ្នកស្រីធ្លាប់បានចូលរួមដែរឬទេ?

**ឆ៖** តាមខ្ញុំដឹង ខ្ញុំចូលវគ្គហ្នឹង ខ្ញុំមិនដែលឃើញគាត់ចូលឧទ្ទេសនាមឯកសារទេ។ អានេះ ខ្ញុំនិយាយយកការពិតហ្នឹង មែនថាគាត់នៅអង្គុយពីមុខហើយ មិនហ៊ាននិយាយទេ។ តែខ្ញុំនិយាយដោយស្មោះត្រង់ គាត់មិនដែលឧទ្ទេសនាមទេចំពោះឯកសារ។ បើគាត់អញ្ជើញមកអីម្តងម្យាមហ្នឹង គាត់មកជាអធិបតី។ ឋានៈគាត់ជាអធិបតី មិនមែនឋានៈគាត់អ្នកឧទ្ទេសនាមឯកសារទេ។ ហើយតាមខ្ញុំដឹង គាត់ក៏មិនដែលបានប្រឡូកក្នុងនយោបាយដែរ។ គាត់ច្រើននៅក្រៅប្រទេសអ៊ីចឹង។ អ៊ីចឹងគាត់អត់បានប្រឡូកទេ ក្នុងនយោបាយ គឺមានតែ -- គាត់មិនបានឧទ្ទេសនាមអីក្នុងហ្នឹង គាត់អត់ដែលបានទេ។ នេះខ្ញុំ

និយាយការពិតមក និយាយដោយមានភ្លើងអ៊ីចឹងណ៎ះ! អត់មានដែលចូលប្រឡូកក្នុងការនិយាយឧទ្ទេសនាមឯកសារអីទេ គឺមានតែលោក ប៉ុល ពត ហើយបើកាលណាគាត់ចែកភារកិច្ចគ្នាពីរនាក់ហ្នឹង លោកពីរហ្នឹង គាត់និយាយ។ បើក្រៅ -- បើថាលោក ខៀវ សំផន គឺអត់ហ្មង អត់ដែលមាន។ អ្នកហ្នឹង ខ្ញុំទៅប្រទះទេ មិនមែនថានិយាយកែប្រែអ៊ីចេះអ៊ីចុះ អត់ទេ។ និយាយការពិត។ មិនដែលឃើញគាត់និយាយពីឯកសារអីមួយទេ។

[១៤:៣៣:៥៦]

ហើយខ្ញុំសូមបកបន្តិច ដូចថាលោកស្រី វ៉ាន់ និយាយថាជួបគាត់នៅលើឡានអី ខ្ញុំអត់បានជួបទេ។ អើបើចូលវគ្គ ដូចដែលឯកសារលើក ខ្ញុំបានចូលទៅ គាត់ចូលរួមជាអធិបតីនៅក្នុងសាលាអី ខ្ញុំបានឃើញម្តងម្យាម។ បើថាគាត់ជិះឡានអីតាមផ្លូវ ឬគាត់មកបើកវគ្គនៅតាមខេត្ត តាមភូមិភាគអី គាត់មិនដែលមកទេ។ អត់ដែលសោះហ្មង ព្រោះតាមខ្ញុំដឹង ខ្ញុំនិយាយដោយ--

**ប្រធានអង្គជំនុំ៖**

បាន១ ប៉ុណ្ណឹងហើយលោកស្រី ប្រាក់ យុត។ លោកស្រីឆ្លើយតបភាពចាំបាច់ទៅនឹងសំណួរបានហើយ ដែលលោកស្រីឆ្លើយច្រើន នៅពេល -- នៅថ្ងៃស្អែក នៅថ្ងៃខានស្អែកទៀត ដែលលោកស្រីត្រូវឆ្លើយសំណួរច្រើនទៀតណះ! ម្យ៉ាងខាតពេលផង ម្យ៉ាងភាពឆ្លើយ សូមឲ្យឆ្លើយតែភាពចាំបាច់តបនឹងសំណួរបានហើយណ៎ះ!

[១៤:៣៤:៥៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** អ្នកស្រីសាក្សី អរគុណច្រើនដែលអ្នកស្រីបានបញ្ជាក់។ អ្នកស្រីនិយាយថា ប៉ុល ពត ហើយនិង នួន ជា ជាអ្នកបង្រៀន។ ដូច្នេះ ខ្ញុំចង់សួរថាតើពួកគាត់មាននិយាយអំពីខ្មាំងរបស់បក្សដែរឬទេនៅក្នុងកិច្ចប្រជុំនេះ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ពេលនោះ គាត់អត់មានពីខ្មាំងនៅក្នុងបក្សទេ គាត់និយាយពីនយោបាយបំពាក់បំប៉នពីរឿងធ្វើទំនប់ ធ្វើប្រឡាយ ឲ្យពួកខ្ញុំទៅវិញ ធ្វើប្រឡាយ និងធ្វើទំនប់ហ្នឹង ស្រែប្រាំងស្រែអីជូនប្រជាជនហ្នឹង តែចំពោះរឿងផ្ទៃក្នុងគាត់មិនដែលបាននិយាយជាមួយពួកខ្ញុំទេ។ គាត់បំពាក់បំប៉នតែនយោបាយឲ្យទៅខំធ្វើស្រែចម្ការ ធ្វើប្រឡាយ ធ្វើទំនប់អ៊ីចឹងណា អាហ្នឹងគាត់និយាយ។

**ស៖** ឥឡូវនេះ ខ្ញុំព្យាយាមរំឭកការចងចាំរបស់អ្នកស្រីម្តងទៀត។ នៅក្នុងសវនាការ ការជំនុំជម្រះរបស់ ពេជ្រ ជឹម គឺតាជឹម នោះឯង។ នៅក្នុងឯកសារ E1/215.1 នៅម៉ោង១១:៣១ បានផ្តល់សក្ខីកម្មដូចតទៅនេះ "សំណួរ៖ នៅពេលដែល នួន ជា បង្រៀនលោក តើគាត់ធ្លាប់លើកប្រធានបទអំពីខ្មាំងខាងក្នុងខាងក្រៅដែរឬទេ? ចម្លើយ៖ បាទ គាត់ធ្លាប់លើក គឺគាត់និយាយគ្រប់ចំណុចទាំងអស់"។ ប្រសិនបើមិនបាននិយាយអំពីខ្មាំងផ្ទៃក្នុងផ្ទៃក្រៅទេ គឺប្រាកដជាមិនអាចឲ្យអ្នកដទៃអាចដឹង ថាតើខ្មាំងជាអ្នកណានោះឡើយ។ ដូច្នេះ ខ្ញុំចង់សួរថាតើអ្នកស្រីសាក្សី អ្នកស្រីអាចនឹកឃើញដែរឬទេ ថាអ្នកស្រីធ្លាប់ទទួលការពន្យល់បង្ហាញអំពី ប៉ុល ពត ឬក៏ នួន ជា អំពីប្រភេទមនុស្សបែបណាដែលជាខ្មាំងនោះ តើអ្នកស្រីហ្នឹងឃើញទេ?

[១៤:៣៧:០២]

**ឆ៖** ខ្ញុំនឹកអត់ឃើញទេ។ មិនដឹងគាត់និយាយពីអីៗខ្លះ ខ្ញុំនឹកមិនឃើញទេ សូមជម្រាប។ បើតាជឹម គាត់និយាយអ៊ីចឹង អាហ្នឹងខ្ញុំ ដូចថា ខ្ញុំនឹកមិនឃើញទេ បើគាត់ថានិយាយអ៊ីចឹងក៏និយាយ។ តែចំពោះខ្ញុំ នឹកអត់ឃើញ។

**ស៖** តើប៉ុល ពត និងនួន ជា បាននិយាយអំពីវៀតណាម ឬក៏ចាមដែរឬទេ នៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** អត់មានដែលនិយាយពីរឿងវៀតណាម រឿងចាមអីគាត់មិនដែលនិយាយផង។

**លោក ខេល លីសាក់៖**

ខ្ញុំសួរអ្នកស្រីច្រើនណាស់ទៅហើយ ដូច្នេះខ្ញុំសូមអរគុណអ្នកស្រី ហើយខ្ញុំឥឡូវនេះ សូមអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់វេទិកាជូនទៅសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីវិញ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្រេសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:២០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ។

បាទ អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមគោរពលោកស្រីសាក្សី។ ខ្ញុំបាទឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅលោកស្រី ដើម្បីឲ្យមានការបញ្ជាក់បន្ថែម។ ជាដំបូង ពាក់ព័ន្ធទៅនឹងអ្វីដែលលោកស្រីមានប្រសាសន៍មុននេះបន្តិចថា លោកស្រីបានឃើញលោក ខៀវ សំផន ធ្វើជាអធិបតីម្តងម្យាម។ សំណួររបស់ខ្ញុំ ចង់សួរថា តើលោកស្រីធ្លាប់បានឃើញលោក ខៀវ សំផន នោះ នៅក្នុងកម្មវិធីអ្វីខ្លះ?

[១៥:០៥:២៥]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ ខ្ញុំបានឃើញគាត់ពេលដែលកម្មវិធីបើកវគ្គម្តងម្យាម យូរៗម្តងទេ មិនឃើញជាប្រចាំ ពេលគាត់បើកវគ្គ គាត់មកធ្វើប្រធានអធិបតីតែមួយដងនុ៎ង។

**ស៖** លោកស្រីអាចនិយាយឲ្យបានច្បាស់លាស់ជាងនេះបានទេ តើកម្មវិធីបើកវគ្គអ្វី ជាកិច្ចប្រជុំ

ឬក៏ជាមហាសន្និបាត? សូមបញ្ជាក់ឲ្យបានច្បាស់លាស់។

**ប្រធានអង្គជំនុំ៖**

ទាន់ កុំអាលទាន់ឆ្លើយ!

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ពេលខ្ញុំបានជួបគាត់ នៅពេលបើកវគ្គរៀនសូត្រម្ដងម្យាម។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទអរគុណលោកស្រី។ វគ្គរៀនសូត្រម្ដងម្យាម។ តើលោកស្រីអាចបញ្ជាក់ទេ ប៉ុន្មានដង ដែលវគ្គនុ៎ងមានប៉ុន្មានវគ្គដែលលោកស្រីបានចូលរួម ហើយលោកស្រីបានឃើញគាត់ហ្នឹង?

**ឆ៖** បើកវគ្គជារាល់ឆ្នាំ ប៉ុនជួនកាល ខ្ញុំបានជួបគាត់តែមួយដងហ្នឹង។ ជាវគ្គក្រោយៗទៀត ខ្ញុំអត់ដែលបានជួប។ វគ្គនោះ វាច្រើនដងដែរ មួយឆ្នាំ ជួនកាល ខ្ញុំមកជួបគាត់មួយដងអ៊ីចឹងទៅ មួយឆ្នាំហ្នឹង ជួនកាលពីរឆ្នាំ មួយឆ្នាំក្រោយទៀត ខ្ញុំអត់បានជួបគាត់ទេ។ ខ្ញុំបានជួបគាត់តែម្ដងម្យាម ដែលត្រូវការបើកវគ្គហ្នឹង។

**ស៖** ចង់ឲ្យលោកស្រីជួយបញ្ជាក់ឲ្យបានច្បាស់ "ម្ដងម្យាម" ម្ដងម្យាមហ្នឹងមានន័យថា មួយដង ឬក៏ពីរដង ឬក៏បីដង ដែលលោកស្រីបានឃើញគាត់?

[១៥:០៧:៤៣]

**ឆ៖** សូមបញ្ជាក់។ ពេលជួបគាត់ ក្នុងពេលបើកវគ្គ ឧទាហរណ៍ថា ខ្ញុំមកមួយឆ្នាំនេះ គឺជួបគាត់មួយដង តែឆ្នាំក្រោយៗទៀត ខ្ញុំអត់បានមក អត់បានជួបទេ។ បើកវគ្គរៀនសូត្រអ៊ីចឹង។ ហើយដល់ក្រោយមក ខ្ញុំអត់ដែលបានរៀន ក៏ខ្ញុំអត់ដែលបានជួបគាត់ដែរ។

**ស៖** អ៊ីចឹងក្នុងពេលដែលលោកស្រីបានឃើញគាត់ ឬក៏បានជួបគាត់ តើគាត់មាននិយាយអីខ្លះទេ ក្នុងនាមជាអធិបតីនៅក្នុងវគ្គរៀនសូត្រហ្នឹង?

**ឆ៖** តាមខ្ញុំបានជួប ក្នុងវគ្គរៀនសូត្រនេះ គាត់ជាអធិបតី គាត់មិនដែលបាននិយាយអីទេ។ តាមខ្ញុំឃើញនៅក្នុង -- ឃើញ គាត់មិនដែលបាននិយាយទេ គឺគាត់គ្រាន់ជាធិបតី។

**ស៖** តើគាត់អង្គុយ គាត់នៅចូលរួមជាអធិបតីហ្នឹង គាត់នៅយូរទេ ក្នុងពេលវគ្គរៀនសូត្រហ្នឹង? មានន័យថា តាំងពីដើមរហូតទៅដល់ចប់ ឬក៏គាត់នៅក្នុងពេលរៀនសូត្រហ្នឹង តែមួយពេលណាមួយ?

**ឆ៖** គឺថា ពេលខ្ញុំនៅក្នុងសាលាហ្នឹង ដូចថា ពេលគាត់បើកវគ្គធំ ឃើញគាត់។ ក្រោយមក គាត់

អត់មានមកចូលរួមទៀតទេ។

**ស៖** អ៊ីចឹង ខ្ញុំអាចនិយាយថា ក្នុងវគ្គធំហ្នឹង គាត់ចូលរួមនៅក្នុងវគ្គហ្នឹង តាំងពីពេលដំបូង រហូតទៅដល់ពេលចប់វគ្គ។ អ៊ីចឹងមែនទេ?

**ឆ៖** អាហ្នឹង ដូចខ្ញុំមិនសូវច្បាស់ដែរកាលហ្នឹង ដូចថាវាអត់ចាំ មិនដឹងថាគាត់អង្គុយរហូត ឬក៏គាត់អង្គុយតែមួយថ្ងៃបើកវគ្គហ្នឹង ខ្ញុំក៏វាមិនបានចាំដល់ថ្ងៃហ្នឹងដែរនេះ ភ្លេច។

**ស៖** បាទ អ៊ីចឹងអរគុណ។ បាទ លោកស្រីបាននិយាយថា លោកស្រីម្តងម្កាលបានមករៀនសូត្រនៅភ្នំពេញ ឬក៏ប្រជុំនៅភ្នំពេញនៅពេលចុងឆ្នាំ។ តើលោកស្រីអាចបញ្ជាក់បានទេ លោកស្រីបានមកភ្នំពេញប៉ុន្មានដងនៅក្នុងការចូលរួមការរៀនសូត្រ? មានន័យថាតាំងពី១៩៧៥ រហូតទៅដល់ ០៦ មករា ១៩៧៩ លោកស្រីបានចូលរួមប្រជុំប៉ុន្មានដងនៅភ្នំពេញ?

[១៥:១១:១៤]

**ឆ៖** ខ្ញុំសូមជម្រាប ពី៧៥ មកទល់៧០ ខ្ញុំសរុបខ្លួនឯងប្រហែលជា ប្រាំដងចុះ។ អាហ្នឹងឃើញខាងគាត់ហៅ កង ចាប គាត់ហៅខ្ញុំមក។ ហើយក្រោយមកខ្ញុំអត់ដែលបានមកប្រជុំទេគាត់ ខ្ញុំអត់ដែលបានមកប្រជុំទេ គាត់ហៅមកតែប្រាំដងហ្នឹង ដូចថាមានការចាំបាច់អីគាត់ហៅខ្ញុំមក ថាអត់ ខ្ញុំមិនសូវដែលបានមកទេ។ គាត់ច្រើនតែមកគ្នាគាត់បីនាក់។

**ស៖** ក្នុងរយៈពេលប្រាំដងដែលលោកស្រីបានមកចូលប្រជុំនៅភ្នំពេញហ្នឹង គឺប្រាំដងហ្នឹងក្នុងពេលលោកស្រីបានត្រូវបានផ្លាស់ប្តូរទៅកំពង់ចាមហើយ ឬក៏ពេលខ្លះលោកស្រីនៅកំពតទេ ក៏ប៉ុន្តែលោកស្រីត្រូវបានកោះហៅមកប្រជុំនៅភ្នំពេញដែរ?

**ឆ៖** ខ្ញុំទៅនៅកំពង់ចាម ឆ្នាំ៧៧។ ចុងឆ្នាំ៧៧ ខ្ញុំបានមករៀនម្តង ហើយខ្ញុំនៅកំពតប្រជុំបានមករៀនបួនដង។ នៅកំពង់ចាម ខ្ញុំនៅបានតែ៧៧ បានតែម្តងទេ ខ្ញុំមកប្រជុំ មករៀននៅមកភ្នំពេញ។

**ស៖** អ៊ីចឹងមុនៗនេះ នៅពេលឆ្លើយសំណួរទៅនឹងសហព្រះរាជអាជ្ញារងអន្តរជាតិ លោកស្រីថាបានប្រជុំម្តងនៅភ្នំពេញគឺពេលនោះមានរយៈពេល១៥ថ្ងៃ ហើយលោកស្រីអាចបញ្ជាក់បានទេ ថាតើប្រជុំ១៥ថ្ងៃហ្នឹង គឺប្រជុំនៅឆ្នាំណា នៅឆ្នាំ១៩៧៧ ដែលលោកស្រីបានបញ្ជាក់អម្បាញ់មិញ ឬក៏មុននេះ?

**ឆ៖** ខ្ញុំៗដូចស្តាប់សំណួរមិនសូវបានសូមឲ្យលោក--។

[១៥:១៣:៤៩]

**ស៖** បាទ ខ្ញុំលើកសំណួរសាជាថ្មី។ នៅពេលដែលសហព្រះរាជអាជ្ញាបានសួរទៅលោកស្រី

លោកស្រីថាមានប្រជុំប្រចាំឆ្នាំមួយដែលលោកស្រីបានមកភ្នំពេញរយៈពេល១៥ថ្ងៃ ដើម្បីប្រជុំ។ តើកិច្ចប្រជុំមួយហ្នឹងនៅឆ្នាំណា?

**ឆ៖** ខ្ញុំបានមកប្រជុំរយៈកាល១៥ថ្ងៃនេះ គឺខ្ញុំទៅនៅកំពង់ចាម។ ខ្ញុំមកប្រជុំរយៈកាល១៥ថ្ងៃមកប្រជុំនៅភ្នំពេញ បូកសរុបលទ្ធផល មួយឆ្នាំ១។ នេះខ្ញុំបានប្រជុំរយៈកាល១៥ ថ្ងៃ។

**ស៖** បូកសរុបលទ្ធផលមួយឆ្នាំហ្នឹង តើអ្នកណាគេជាអធិបតីនៅក្នុងអង្គប្រជុំហ្នឹង លោកស្រី?

**ឆ៖** ក្នុងពេលនោះខ្ញុំបានចាប់អារម្មណ៍ថា អ៊ំ១ នួន ជា អ្នកសរុបសេចក្តីនោះ ខ្ញុំវាអត់បានចាំ១ពិតប្រាកដដែរ ព្រោះខ្ញុំកាលហ្នឹងមិនបានចាំថាឈ្មោះ នួន ជា ឬក៏យ៉ាងម៉េច នេះតាមខ្ញុំគិតមើលដូចជាមិនចាំឈ្មោះទេ ឈ្មោះគេពីរនាក់ហ្នឹងមិនដឹង អ៊ំ ប៉ុល ពត ឬ អ៊ំ នួន ជា ខ្ញុំវាអត់ច្បាស់។ ប៉ុនអ្នកសរុបមិនគាត់ទាំងពីរហ្នឹង ឬក៏ម្នាក់។

**ស៖** បាទ អរគុណ។ ខ្ញុំចង់សួរថាតើនៅពេលនោះ គេសរុបប្រចាំឆ្នាំនៃការងារហ្នឹង ថាតើគេនិយាយអំពីបញ្ហាអ្វីខ្លះ?

**ឆ៖** លើកដូចថាយើងដាក់ផែនការមួយឆ្នាំ សំខាន់គឺថានៅក្នុងស្រុក ក្នុងតំបន់ រៀបចំថាដូចថាធ្វើទំនប់នៅកន្លែងណា ជីកប្រឡាយនៅកន្លែងណា ហើយធ្វើស្រែប្រាំងនៅកន្លែងណា យើងសរុបពីការងារ យើងមិនបានសរុបពីអីទេ ព្រោះអាហ្នឹងការងារប្រចាំឆ្នាំសម្រាប់យើងអនុវត្ត សំខាន់គឺធ្វើស្រែធ្វើប្រឡាយធ្វើទំនប់ហ្នឹង អត់មានអីក្រៅពីហ្នឹងផង ព្រោះយកផែនការហ្នឹងទៅពិនិត្យ ផែនការចាស់ហ្នឹងទៅពិនិត្យវិញ តើធ្វើបានប៉ុន្មានហើយ នៅសល់ប៉ុន្មានទៀត។ នេះខ្ញុំសូមលើក។

[១៥:១៧:០៨]

**ស៖** តើពេលនោះ អ៊ំមានបានឮគេនិយាយអំពីទំនប់១មករា ឬក៏ទំនប់ត្រពាំងថ្មទេ ក្នុងពេលប្រជុំដែលអ៊ំបានចូលរួមមួយនឹង?

**ឆ៖** ដែលឮទំនប់ហ្នឹងដែរខ្ញុំ។ នៅត្រពាំងថ្ម នៅឮថាទំនប់ហ្នឹងធំ ទំនប់របស់១ តាពក គាត់ធ្វើតែខ្ញុំក៏មិនបានទៅជិតដែរ គ្រាន់ថាវាឮ១ តែខ្ញុំមិនដែលបានទៅចូលរួមចំណែកជាមួយ តាពក ទេ ព្រោះទំនប់ហ្នឹងគេដាក់ថាទំនប់ភូមិភាគ អ៊ីចឹងខ្ញុំមិនដែលបានទៅជិតទេ។

**ស៖** សូម១កាត់បន្តិចអ៊ំ លោកស្រីសាក្សីសូមបញ្ជាក់បន្តិច។ នៅពេលដែលគេសរុបសកម្មភាពប្រចាំឆ្នាំនៅមជ្ឈិមហ្នឹង -- នៅភ្នំពេញហ្នឹង ថាតើគេមានបាននិយាយអំពីទំនប់ទាំងពីរដែលខ្ញុំបាននិយាយអម្បាញ់មិញ មានន័យថាទំនប់១មករា ដែលនៅកំពង់ធំ ហើយទំនប់ត្រពាំងថ្ម នៅបាត់ដំបង ឥឡូវនៅ

ក្នុងខេត្តបន្ទាយមានជ័យនោះ ថាតើនៅពេលនោះគេមាននិយាយអំពីទំនប់ទាំងពីរនោះដែរឬទេ?

**ឆ៖** ពេលនោះគឺបានសរុបលទ្ធផលដែលធ្វើមួយឆ្នាំហ្នឹង។ ទំនប់ តែចំពោះទំនប់បន្ទាយមានជ័យ ក៏ខ្ញុំអត់ឮ មិនដឹងថាគាត់លើកយកមកសរុបអីយ៉ាងម៉េច បើទំនប់នៅត្រពាំងថ្ម អាហ្នឹងជាទំនប់របស់ភូមិភាគ មិនដឹងថាគាត់លើកទំនប់ហ្នឹងយ៉ាងម៉េច ខ្ញុំអត់បានដឹងដែរ ព្រោះខ្ញុំក៏មិនបានស្ដាប់បានទាំងអស់ និយាយទៅ សូម្បីទំនប់នៅបន្ទាយមានជ័យក៏អីចឹង ទំនប់ត្រពាំងថ្មក៏អីចឹង មិនដឹងថាគាត់លើកយ៉ាងម៉េចទេ ប៉ុន្តែការពិតរបស់ភូមិភាគទំនប់ហ្នឹង។ ហើយដល់ពេលសរុបក៏ខ្ញុំស្ដាប់មិនបានទាំងអស់ដែរ មិនដឹងជាបាន--

**ស៖** សូមកាត់លោកស្រីបន្តិច។ ទំនប់ត្រពាំងថ្មគឺស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យពីមុន អាហ្នឹងជាផ្នែកមួយនៃខេត្តបាត់ដំបង ក្នុងទំនប់ត្រពាំងថ្ម។ ហើយទំនប់មួយទៀតគឺទំនប់១មករា ដែលខ្ញុំនិយាយហើយគេច្រើនតែនិយាយថាជាទំនប់នៅកំពង់ថ្ម។ កំពង់ថ្មហើយនិងត្រពាំងថ្មខុសគ្នា។ អីចឹងនេះសូមបញ្ជាក់ឱ្យច្បាស់រឿងហ្នឹងបន្តិច។

**ឆ៖** ទំនប់ត្រពាំងថ្ម ខ្ញុំអត់សូវច្បាស់ទេ ព្រោះនៅក្នុងខេត្តបន្ទាយមានជ័យ ហើយការសរុបខាងបន្ទាយមានជ័យ ក៏ខ្ញុំមិនបានយកចិត្តទុកដាក់ដែរ ព្រោះខ្ញុំអត់ស្គាល់។ តែបើទំនប់ត្រពាំងថ្ម ខ្ញុំ -- របស់ភូមិភាគកណ្ដាល ខ្ញុំស្គាល់ តែគ្រាន់តែស្គាល់ តែខ្ញុំក៏មិនបានគិតថាខាង តាពក គាត់រាយការណ៍យ៉ាងម៉េច អីយ៉ាងម៉េច ចំពោះខាងលើ ខ្ញុំអត់ច្បាស់ដែរបញ្ហាហ្នឹង។ គ្រាន់តែស្គាល់។

[១៥:២០:៣៩]

**ស៖** អរគុណៗ ខ្ញុំសូមកាត់បន្តិច។ លោកស្រីលើកឡើងថាទំនប់ត្រពាំងថ្ម តើទំនប់ហ្នឹងលោកស្រីសំដៅទៅលើទំនប់១មករា ហ្នឹង ក៏មែនទេ?

**ឆ៖** ខ្ញុំស្គាល់តែទំនប់ បើទំនប់ត្រពាំងថ្ម លោកថា ទំនប់បន្ទាយមានជ័យ ហើយទំនប់ស្ទឹងអី--

**ស៖** ស្ទឹងជីនិត?

**ឆ៖** ស្ទឹងជីនិត អាហ្នឹង បានទំនប់ខាងស្រុក -- ខាងកំពង់ចាម។ ហើយត្រពាំងថ្មនេះ ខ្ញុំអត់ស្គាល់ ប៉ុនខ្ញុំស្គាល់ថា ទំនប់ជីនិតហ្នឹង ខ្ញុំស្គាល់។ អាហ្នឹងទំនប់របស់ភូមិភាគដែលគាត់ធ្វើ របស់ តាពក តែត្រពាំងថ្ម ខ្ញុំដូចអត់ស្គាល់។

**ស៖** បាទៗអរគុណ។ ពាក់ព័ន្ធទៅនឹងទំនប់១មករា ខ្ញុំសូមផ្លៀតសួរលោកស្រីសាក្សីតែម្ដងទៅ។ លោកស្រីសាក្សីមានធ្លាប់បញ្ជូនមនុស្សពីស្រុករបស់លោកស្រី ដើម្បីទៅចូលរួមធ្វើការងារ លើកទំនប់

នៅ១មករា នៅស្ទឹងជីនិតនេះដែរឬទេ?

**ឆ៖** ខ្ញុំ -- ខ្ញុំបានបញ្ជូនមនុស្ស តែការសុំស្នើរបស់តំបន់យកឲ្យភូមិភាគ។ ការបញ្ជូន គឺខ្ញុំបញ្ជូនតែមនុស្សទេ តែចំពោះខ្លួនខ្ញុំ ខ្ញុំមិនដែលបានទៅ ហើយខ្ញុំមិនសូវបានស្គាល់ទំនប់ហ្នឹងទៀត។

**ស៖** សូមកាត់លោកស្រី លោកស្រីនៅចងចាំទេ លោកស្រីបានបញ្ជូនមនុស្សប៉ុន្មាននាក់ ដើម្បីឲ្យទៅចូលរួមធ្វើការងារនៅទំនប់១មករា ស្ទឹងជីនិតនេះ?

[១៥:២២:៣៧]

**ប្រធានអង្គជំនុំ៖**

សាក្សីឈប់ឆ្លើយតបទៅ មិនបាច់ឆ្លើយតបទេ!

មេធាវីសួរសំណួរតទៅទៀតទៅ។ ហើយសំណួរនេះ ទំនងមិនពាក់ព័ន្ធនឹងអង្គហេតុចាមទេ។ ហើយក៏មិនមានពាក់ព័ន្ធអីច្បាស់លាស់ទៅលើការអនុវត្តគោលនយោបាយស៊ីជម្រៅអ្វីដែរ។ ហើយពេលវេលាដូចជាអស់ ចំណាយពេលវេលាច្រើនហើយ ទី១។ ទី២ កត់សម្គាល់ឃើញថា ការតាំងសំណួរគឺគប្បីអង្គុន់សំណួរឲ្យខ្លីៗ គឺងាយក្នុងការឆ្លើយតប។ បើលោកច្របល់គ្នាអ៊ីចឹង ពិបាកក្នុងការឆ្លើយតបណាស់ ហើយយើងគិតវ័យគាត់ផង គាត់វ័យចាស់ហើយ ហើយរឿងអតីតកាល វាកើតជិត៤0ឆ្នាំមកហើយ។

តាំងសំណួរផ្សេងទៀត តទៅទៀត ទៅមុខទៀត!

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំលើកសំណួរនេះ ដោយសារខ្ញុំយល់ថា ទំនប់១មករា ជាវិសាលភាពនៃសំណុំរឿង00២/0២ដែរ តែខ្ញុំនឹងបន្តសំណួរបន្តទៅទៀត ទៅផ្នែកផ្សេងទៀត។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោកស្រីបាននិយាយអំពីការរៀបអាពាហ៍ពិពាហ៍នៅក្នុងស្រុករបស់លោកស្រី តើលោកស្រីបានចូលរួមនៅក្នុងការរៀបការអាពាហ៍ពិពាហ៍ប៉ុន្មានដងនៅក្នុងស្រុករបស់លោកស្រីនៅកំពង់ចាម?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ការរៀបចំអាពាហ៍ពិពាហ៍នៅក្នុងស្រុករបស់ខ្ញុំមិនដឹងជាបានប៉ុន្មានដង ខ្ញុំភ្លេចអស់បាត់ហើយ មិនដឹងជារៀបនៅកន្លែងណា ហើយនៅប៉ុន្មានដងទេ ខ្ញុំចាំមិនអស់ដែរ ខ្ញុំសូមជម្រាប។ ចាំអត់អស់។

[១៥:២៤:៣៦]

**សះ** តើលោកស្រីអាចនៅចងចាំទេ នៅពេលដែលលោកស្រី លោកចូលរួមការរៀបការនៅកំពង់ចាមហ្នឹង មានតែលោកស្រីតែម្នាក់ចូលរួមនៅក្នុងពេលនោះ ឬក៏ថាមានកម្មាភិបាលផ្សេងទៀតបានចូលរួមនៅក្នុងពេលនោះដែរ?

**ឆះ** ឥឡូវឲ្យខ្ញុំនិយាយថា ការនៅកំពង់ចាម លោកស្រីបានចូលរួម មិនបានចូលរួម ហើយបានប៉ុន្មានដង? ខ្ញុំថា ការនេះមិនដឹងប៉ុន្មានដង ខ្ញុំភ្លេចអស់ហើយ ខ្ញុំសូមនិយាយត្រង់តែម្តង។ មិនដឹងថា ការនៅប៉ុន្មានដងទៅមុខ អំ! ប៉ុន្មានដងទៀត ខ្ញុំវាភ្លេច។ ព្រោះការរៀប វារៀបហើយ ប៉ុន្តែមិនដឹងប៉ុន្មានដងវាអត់ចាំ។

**សះ** ចង់សួរចំណុចផ្សេងមួយទៀតដល់លោកស្រី។ លោកស្រីពេលឆ្លើយទៅនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា លោកស្រីបាននិយាយថា បុរសស្រ្តីហ្នឹងបានសរសេរក្រដាសមួយមុននឹងបញ្ជូនមកស្រុកដើម្បីឲ្យលោកស្រីសម្រេចថានឹងរៀបការ ហើយតើក្រដាសនេះជាក្រដាសអ្វី? ជាក្រដាសបញ្ជាក់អំពីថាពីរនាក់ហ្នឹងគាត់បានព្រមព្រៀងគ្នា ឬយ៉ាងម៉េច?

**ឆះ** ខ្ញុំសូមបញ្ជាក់ កាលយើងមុននឹងការ យើងមានការព្រមព្រៀង បានយើងហ៊ានសរសេរ បើអត់ព្រមព្រៀងអត់សរសេរទេ។ នេះ ខ្ញុំសូមបញ្ជាក់ខ្លីអ៊ីចឹង។

[១៥:២៦:៥៨]

**សះ** តើលោកស្រីពេលនោះមានបានផ្ទៀងផ្ទាត់ទេថា ទាំងសងខាង ទាំងស្រីទាំងប្រុសដែលលោកស្រីរៀបការឲ្យហ្នឹង គាត់ទាំងពីរនាក់សុខព្រមជាមួយគ្នាពិតប្រាកដមែនឬទេ? តើមានបានផ្ទៀងផ្ទាត់ទេនៅពេលនោះ?

**ឆះ** ពេលការពេលនោះ យើងមិនបានផ្ទៀងផ្ទាត់គ្រប់។

**សះ** នៅពេលដែលលោកស្រីថាមិនបានផ្ទៀងផ្ទាត់គ្រប់ហ្នឹង មានន័យថា លោកស្រីបានផ្ទៀងផ្ទាត់ដែរ។ ថាតើលោកស្រីធ្វើយ៉ាងម៉េចដើម្បីផ្ទៀងផ្ទាត់ថា ប្រុសហើយនិងស្រី ដែលមករៀបការនៅចំពោះមុខលោកស្រីហ្នឹង ពួកគាត់បានឯកភាពគ្នាពិតប្រាកដមែនទេ? នៅក្នុងការរៀបការហ្នឹងលោកស្រីផ្ទៀងផ្ទាត់យ៉ាងម៉េចអាចបញ្ជាក់រឿងនុ៎ងបានទេ?

**ឆះ** ខ្ញុំសូមបញ្ជាក់ កាលនោះយើងបានបញ្ជាក់មិន -- យើងបានបញ្ជាក់ទាំងពីរនាក់ហ្នឹង គឺច្បាស់លាស់ហើយ បានយើងរៀបការ។ បើសិនជាមិនច្បាស់លាស់ ខ្ញុំក៏មិនរៀបការដែរ។ ហ្នឹងសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** បាទ ខ្ញុំសួរទៅរឿងបញ្ហាចាមវិញ។ ថាតើលោកស្រីមានបានឃើញចាមដែលរស់នៅក្នុងស្រុករបស់លោកស្រីខ្លួនឯងដែរឬទេ? ហើយបើឃើញលោកស្រីមានបានសង្កេតឃើញទេ ថាតើគាត់ស្លៀកពាក់សម្លៀកបំពាក់យ៉ាងដូចម្តេចដែរ?

**ឆ៖** ខ្ញុំអង្គាល់ហ្នឹងក៏មិនមានចាំអារម្មណ៍រឿងចាមស្លៀកពាក់ទេ គ្រាន់ឃើញតែចាម តែខ្ញុំដឹងគាត់ស្លៀកអី ខ្ញុំក៏មិនបានៗចាំទុកទេនេះ។ នេះ ខ្ញុំសូមជម្រាប។ ព្រោះវាមិនបានចាំ រៀបចំថាគាត់ស្លៀកពាក់អី ជាស្លៀកពាក់អីទេ ព្រោះគាត់រស់នៅជាមួយប្រជាជន ហើយខ្ញុំក៏មិនបានចាប់អារម្មណ៍ដែរ។

[១៥:២៩:៥៥]

**ស៖** បាទ ដោយសារលោកស្រីអត់សូវបានចាប់អារម្មណ៍អំពីបញ្ហាទាំងអស់នេះ ខ្ញុំចង់សួរលោកស្រីពាក់ព័ន្ធទៅនឹងប្រធានបទចុងក្រោយ ពាក់ព័ន្ធទៅនឹងរឿងវត្តអារាម និងព្រះពុទ្ធសាសនា ព្រះសង្ឃ។ ទាំងពេលដែលលោកស្រីនៅកំពត ហើយនិងពេលដែលលោកស្រីមកនៅធ្វើការនៅកំពង់ចាម។ តើលោកស្រីមានឃើញថា មានព្រះសង្ឃ ហើយនិងប្រជាជនមានគោរពព្រះពុទ្ធសាសនាដែរទេ? មានន័យថា ពីឆ្នាំ៧៥ រហូតទៅដល់ឆ្នាំ៧៩?

**ឆ៖** តាំងពីឆ្នាំ៧៥ ដល់៧៩ អត់មានៗលោកសង្ឃ អត់មានវត្តផង។

**ស៖** ហើយលោកស្រីមានដឹងថា មានគោលនយោបាយអីពាក់ព័ន្ធទៅនឹងរឿងការគោរពព្រះពុទ្ធសាសនានោះទេ? ថាតើគេឲ្យមានព្រះសង្ឃ ឬក៏ថាមានការប្រតិបត្តិគោរពព្រះពុទ្ធសាសនាដែរទេ ក្នុងសម័យនោះពាក់ព័ន្ធនឹងបញ្ហាគោលនយោបាយ?

**ឆ៖** សម័យនោះ អត់មានលើកបញ្ហាវត្ត បញ្ហាលោកសង្ឃផង គឺថាអត់មានៗ អត់មានគោលនយោបាយអីត្រូវបង្កើត។

**ស៖** [redacted]

[១៥:៣២:៣៥]

[redacted]

[redacted]

ឆ៖ [redacted]

**លោក ពេជ អង្គ៖**

បាទ អរគុណ លោកស្រី ដែលបានឆ្លើយសំណួររបស់ខ្ញុំ។ ខ្ញុំអស់សំណួរហើយ សូមអរគុណ។ សូមអរគុណលោកប្រធាន។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ អរគុណ។ លោកស្រី ប្រាក់ យុត យើងខ្ញុំមានសំណួរបន្តិចបន្តួច សួរបញ្ជាក់លោកស្រី ដោយសាររយៈពេលប៉ុន្មានសំណួររបស់ភាគីសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសួរលោកស្រីកន្លងមកនេះ ពាក់ព័ន្ធជាមួយនឹងខាងស្រុកកំពង់សៀមនៃតំបន់៤១ ភូមិភាគកណ្ដាលច្រើនហើយ ហើយពាក់ព័ន្ធជាមួយនឹងអាពាហ៍ពិពាហ៍ ក៏ដូចជាកិច្ចរៀនសូត្រដែលលោកស្រីធ្លាប់បានបណ្ដុះ ទទួលការបណ្ដុះបណ្ដាលនៅជំនាន់កម្ពុជាប្រជាធិបតេយ្យ។ ហើយយើងសួរបញ្ហាតែមួយចំនួនទេ។

[១៥:៣៤:៥០]

[redacted]

ហើយសំណួរសួរថា តើលោកស្រីបានត្រូវបានតែងតាំងជាលេខាស្រុកកំពត និងជាសមាជិកនៃតំបន់៣៥ ពិតប្រាកដដែរឬទេ ហើយបើមានការតែងតាំងដូច្នេះមែន តើតែងតាំងពីពេលណាមក?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំបានតែងតាំងគណៈតំបន់កំពត ឆ្នាំ៧០ តែខ្ញុំវាអត់ៗចាំពីរឿងថ្ងៃខែ ខ្ញុំអត់ចាំថ្ងៃខែ ប៉ុន្តែតែងតាំងគឺបានឆ្នាំ៧០ គឺចូលទៅវិញគឺខ្ញុំនៅក្នុងកំពត។ ដល់ចឹង បានតែងតាំងគណៈ

តំបន់ហ្នឹងនៅឆ្នាំ៧០ៗ ឥឡូវ ខ្ញុំសូមអត់ទោសថា ៧០ ឬក៏ ៧០គត់ ឬក៏ ៧១ តែងតាំងនៅខេត្តកំពតហ្នឹងហ្នង។ ព្រោះខ្ញុំនៅតែងតាំងហើយ ៧២ ចិតអី ខ្ញុំមកនៅស្រុកកំពតវិញ។ អ៊ីចឹងការតែងតាំង តាំងពី៧១ ឬក៏ ៧០គត់ ទាំងពីរហ្នឹង មិនដឹងថាមួយណាមួយទេ ប៉ុនខ្ញុំយល់ថា ឆ្នាំ៧០។

**ស៖** បាទអរគុណ ហើយចុះនៅក្រោយថ្ងៃទី១៧ មេសា ៧៥ ក្រោយពីរបបលន់ នល់ ដួលរលំដោយកងវាយចូលលុកទីក្រុងភ្នំពេញដោយកងទ័ពរំដោះ តើលោកស្រីធ្វើអ្វីដែរ?មានតួនាទីអ្វីដែរនៅក្នុងជំនាន់នោះ? ក្រោយ ១៧ មេសា ឆ្នាំ១៩៧៥?

**ឆ៖** ខ្ញុំ ក្រោយ ៧៥ ហ្នឹង ខ្ញុំមិននាទី ប៉ុន្តែខ្ញុំបានឆ្លើយក្នុងៗទំព័រទីប៉ុន្មានទេ ខ្ញុំដូចជារំដោះហើយខ្ញុំនៅកន្លែងកាត់ដេរ ហើយយ៉ាងម៉េច ខ្ញុំភ្លេច។ កាត់ដេររបស់តំបន់ ឬក៏យ៉ាងម៉េចទេ ខ្ញុំមិនបានចាំអស់លោកប្រធាន។

**ស៖** យើងបានពិនិត្យមើលឯកសារអំមិញ គឺចម្លើយរបស់លោកស្រីដែលយើងបានបញ្ជាក់ខាងលើអំមិញគឺលោកស្រីបញ្ជាក់ថា លោកស្រីត្រូវបានក្លាយជាលេខាស្រុកកំពត និងជាសមាជិកតំបន់៣៥ក្រោយឆ្នាំ១៩៧៥ ហើយអំមិញនេះ គឺលោកស្រីឆ្លើយថា ឆ្លើយបានជាទៅជាសមាជិកគណៈតំបន់៣៥ហ្នឹងឆ្នាំ៧០ ឬក៏៧១ ។ ឥឡូវហ្នឹងយើងបញ្ជាក់ឲ្យច្បាស់លាស់ថាតើក្រោយឆ្នាំ១៩៧៥ លោកស្រីមានតួនាទីអ្វីពិតប្រាកដ? ក្រោយៗថ្ងៃរំដោះភ្លាម រំដោះ ១៧ មេសា ឆ្នាំ៧៥ ភ្លាម?

**ឆ៖** ក្រោយរំដោះភ្លាម ខ្ញុំដូចជារៀងវាក់ ដូចថាមិនដឹងថាធ្វើអីក្រោយរំដោះហើយនេះ ខ្ញុំដូចមិនចាំម៉េចទេ។ មិនចាំថាតួនាទីក្រោយរំដោះហើយធ្វើអី ខ្ញុំដូចអត់ចាំ ដូចថាមានការភ្លេចៗ។

[១៥:៣៩:២៩]

**ស៖** អរគុណ។ ចុះលោកស្រីចងចាំទេ ថាលោកស្រីធ្វើជាប្រធានកាត់ដេរហ្នឹងគឺនៅតំបន់ណាដែរ ហើយនៅពេលណាដែរ? -- ឆ្លើយតប?

**ឆ៖** ខ្ញុំធ្វើប្រធានកាត់ដេរនៅក្នុងតំបន់៣៥ នៅតំបន់៣៥ហ្នឹងហ្នង ព្រោះគណៈតំបន់ គាត់ឲ្យខ្ញុំខាងកាត់ដេរ នារី១៥០នាក់ កាត់ដេរខោអាវកងទ័ព។ ប៉ុនកាលហ្នឹងមិនដឹងថា ខ្ញុំមិនចាំត្រង់ថាតួនាទីមិនដឹងធ្វើអីខ្ញុំភ្លេចដែរ។

**ស៖** អរគុណ។ ហើយអង្គជំនុំជម្រះសាលាដំបូងហ្នឹងបានស្តាប់នូវការផ្តល់ភស្តុតាងពីកិច្ចប្រជុំមួយចំនួននៅទីក្រុងភ្នំពេញ ជាពិសេសគឺកិច្ចប្រជុំនៅក្នុងអំឡុងខែឧសភា ឆ្នាំ១៩៧៥ ដែលមានមនុស្សទូទាំងប្រទេសចូលរួមយ៉ាងច្រើនកុះករនៅពេលនោះ ហើយមានការប្រកាសអំពីបញ្ហាការពិភាក្សាអំពី

ការអនុវត្តគោលនយោបាយនានាផង។ តើលោកស្រីបានចូលរួមកិច្ចប្រជុំដ៏សំខាន់នេះដែរឬទេនៅទីក្រុងភ្នំពេញ នៅក្នុងអំឡុងខែឧសភា ឆ្នាំ១៩៧៥ បានន័យថានៅក្នុងអំឡុងពេលបន្តិចក្រោយពេលថ្ងៃរំដោះ ១៧ មេសា ៧៥ រំដោះទីក្រុងភ្នំពេញ?

**ឆ៖** ក្រោយរំដោះ៧៥ ខ្ញុំបានមកប្រជុំភ្នំពេញ អាហ្នឹងដល់ហើយប្រជុំបីថ្ងៃ។ ខាងលើឲ្យមកប្រជុំ ហើយកាលហ្នឹងវាខាងខ្ញុំៗមិនទាន់ស្គាល់ទេ តែរំដោះហើយគឺឲ្យមកបីថ្ងៃ មកប្រជុំ។ តែជាគោលនយោបាយរបស់ខាងលើលើកយ៉ាងម៉េច ខ្ញុំក៏មិនសូវយល់ដែរ ព្រោះកាលហ្នឹងមិនទាន់បានរៀនសូត្រច្បាស់លាស់ដែរ ប៉ុនមកប្រជុំមកហើយ ប្រជុំប្រាំថ្ងៃ ឬក៏បីថ្ងៃកាលហ្នឹង។

**ស៖** បាទ អរគុណ។ ហើយលោកស្រីមកប្រជុំហ្នឹងគឺប្រជុំនៅទីក្រុងភ្នំពេញហ្នឹងដែលថាលោកស្រីថាក្រោយពេលថ្ងៃរំដោះ១៧មេសា បន្តិចហ្នឹង តើមកកិច្ចប្រជុំហ្នឹងប្រជុំនៅទីកន្លែងណាដែរលោកស្រី?

**ឆ៖** កាលហ្នឹងដូចជានៅប្រជុំនៅស្តាត១អូឡាំពិក អ៊ីចឹងហើយយ៉ាង បើខ្ញុំវាចាំមិនអស់ដែរ ប៉ុនតាមខ្ញុំដឹងដូចជានៅស្តាត ព្រោះមកមនុស្សច្រើនគ្រប់កន្លែង។ មកប្រជុំនៅស្តាតអ៊ីចឹង។

[១៥:៤២:២៧]

**ស៖** កិច្ចប្រជុំនោះ លោកស្រីចាំច្បាស់លាស់ទេ ប្រហាក់ប្រហែលជាខែណា ឬក៏ក្រោយពេលថ្ងៃរំដោះទីក្រុងភ្នំពេញ១៧ មេសា ប្រហែលជាប៉ុន្មានថ្ងៃ ឬក៏ប៉ុន្មានខែ?

**ឆ៖** ខ្ញុំចាំអត់អស់ មិនដឹងជាថ្ងៃណា ខែណាទេ ប៉ុនដឹងថាឆ្នាំ៧៥។ មិនដឹងជាថ្ងៃប៉ុន្មាន ខែប៉ុន្មានខ្ញុំអត់ចាំ។

**ស៖** ហើយតើអ្នកណា -- ខាងណាគេដែលបានអញ្ជើញលោកស្រីមកប្រជុំនៅទីក្រុងភ្នំពេញកាលពីពេលនោះ?

**ឆ៖** កាលហ្នឹង ហ្នឹងដូចតំបន់ហ្នឹងហៅ អីក៏ម៉េច ខ្ញុំវាមិនចាំដែរកាលហ្នឹងវាយូរពេកហើយ។ ខាងតំបន់កំពតហ្នឹងហៅ ឬក៏ខាងភាគហៅ ខ្ញុំវាមិនច្បាស់ត្រង់ហ្នឹង។ រំដោះហើយ៧៥ហ្នឹង មិនដឹងគណៈតំបន់ហៅ ឬក៏គណៈភាគ ខ្ញុំវាអត់ច្បាស់ ដូចចាំអត់បាន។

**ស៖** បាទ មិនអីទេ អរគុណ។ ហើយលោកស្រីគិតឡើងវិញមើល រកនឹកឡើងវិញមើលថាតើកិច្ចប្រជុំដែលនៅលោកស្រីថាបានប្រព្រឹត្តនៅស្តាតអូឡាំពិក ហើយរយៈពេលប្រហែលជាបីថ្ងៃ ទៅប្រាំថ្ងៃនោះ មានអ្នកណាខ្លះ បុគ្គលណាខ្លះដែលចូលរួមធ្វើជាគណៈអធិបតីនៅក្នុងកិច្ចប្រជុំដ៏សំខាន់នោះ?

**ឆ៖** តាមខ្ញុំចាំដូចៗជាមានតាម៉ុក មានសោ ភឹម លោកអ៊ំ ប៉ុល ពត។ ខ្ញុំចាំដូចមានប៉ុណ្ណឹង

ហើយក្រៅពីនោះ ខ្ញុំក៏មិនសូវស្គាល់ដែរ ព្រោះខ្ញុំឡើងទៅដូចថាឆ្នាំ៧៥ យើងមិនទាន់បានស្គាល់គ្នាដែរ មិនដឹងអ្នកណាខ្លះដែរ ប៉ុនខ្ញុំចាំគឺមានតាម៉ុក មាន សោ ភឹម ហើយមាន អ៊ំ ប៉ុល ពត ហើយក្រៅពីនោះទៀត មិនដឹងគ្នា មិនដឹងអ្នកណាខ្លះទេ ខ្ញុំចាំមិនអស់។

**ស៖** ចុះកាលនោះ មាន នួន ជា មានលោក ខៀវ សំផន ដែរទេ? កុំអាលទាន់ៗឆ្លើយ!

**ឆ៖** កាលនោះដូចជាមាន លោក នួន ជា ដែរ ឬក៏យ៉ាងម៉េច ខ្ញុំមិនច្បាស់លាស់នេះ! ហើយលោក ខៀវ សំផន ក៏ខ្ញុំអត់ច្បាស់លាស់ ព្រោះកាលហ្នឹង ខ្ញុំអត់ទាន់ស្គាល់គាត់ដែរ។ វាអត់ច្បាស់ដែរ មិនដឹងខាងណាធិបតីខ្លះផង។

[១៥:៤៦:១២]

**ស៖** បាទ មិនអីទេ អរគុណ ហើយតើសមាសភាពដែលសមាជិកនៃកិច្ចប្រជុំកាលពេលនោះគឺមានចំនួនច្រើនទេ តាមដែលលោកស្រីកត់សម្គាល់ឃើញ? តើមានចំនួនច្រើនទេ? ហើយសមាសភាពនោះ គេមកពីមជ្ឈមណ្ឌលណាខ្លះទៅ?

**ឆ៖** កាលមកប្រជុំហ្នឹង តាមខ្ញុំដឹង តាមខេត្តៗមកទាំងអស់។ តាមខ្ញុំដឹង។ ប៉ុនដល់មជ្ឈដ្ឋានផ្សេងៗ ដូចជាផ្សេងៗ ខ្ញុំអត់បានដឹងទេ ប៉ុន្តែបើខាងតំបន់ គឺមក មកប្រជុំ។ ប៉ុនខាងកងទ័ពខាងអី ខ្ញុំអត់បានស្គាល់ មិនដឹងជាមកមិនមក ខ្ញុំមិនបានស្គាល់អស់។ ប៉ុនបើគិតទៅ មនុស្សប្រហែលជាបីបួនរយនាក់ដែរ។ ប៉ុនមិនដឹងខាងមជ្ឈមណ្ឌលណាខ្លះ។ ខ្ញុំវាអត់ស្គាល់ទាំងអស់។

**ស៖** បាទ អរគុណ។ ហើយចុះកម្រិតត្រឹមជានៅក្នុងគណៈកម្មាធិការថ្នាក់ស្រុក ដូចជាលេខាស្រុក អនុលេខាស្រុក ឬក៏ជាសមាជិកស្រុកអីចឹង គាត់អញ្ជើញ ត្រូវបានគេកោះអញ្ជើញឲ្យមកចូលរួមប្រជុំនោះដែរឬទេ? កុំអាលទាន់ៗឆ្លើយ។

**ឆ៖** កាលនោះ ដូចមិនទាន់ ដឹងបានហៅគណៈស្រុក ឬក៏មិនហៅ ខ្ញុំក៏ដូចជាភ្លេចដែរ។ ប៉ុនខ្ញុំឃើញគណៈតំបន់ គឺមក។ តែចំពោះស្រុក ខ្ញុំមិនបានចាំដែរ មិនដឹងមកអត់។

**ស៖** បាទ អរគុណ។ ឥឡូវ និយាយពីរឿងការងារដំណើរការប្រព្រឹត្តទៅនៃកិច្ចប្រជុំវិញ។ តើក្រៅពីកត់សម្គាល់ពីគណៈអធិបតីអម្បាញ់មិញនេះ តើលោកស្រីមានបានកត់សម្គាល់ថា តើបុគ្គលណាដែលបានឡើងធ្វើ ថ្លែងសេចក្ដីថ្លែងការណ៍នៅក្នុងវេទិកានៃកិច្ចប្រជុំនោះដែរឬទេ?

[១៥:៤៨:៤៨]

**ឆ៖** នៅពេលប្រជុំបានលើក ថ្លែងការណ៍នៅក្នុងពេលប្រជុំនោះ គឺមានអ៊ំ អ៊ំ ប៉ុល ពត គាត់

លើកប្រជុំ។ កាលហ្នឹង គាត់យកមកអត្ថាធិប្បាយក្នុងកន្លែងប្រជុំ។ តែក្រៅពីនោះទៀត គាត់អត់មាន -- អត់មានឃើញក្រៅពីគាត់ទេ គាត់ប្រជុំរហូត តាំងពីព្រឹករហូតដល់ល្ងាច គឺគាត់អ្នកអត្ថាធិប្បាយប្រជុំ។

**ស៖** ខ្លឹមសារជារួម ដែលថ្លែងការណ៍ដោយ ប៉ុល ពត ដែលគាត់អ្នកនិយាយតាំងពីព្រឹកទាល់ល្ងាចនុំង គឺមានតែ ប៉ុល ពត ម្នាក់ហ្នឹង តើគាត់និយាយពីបញ្ហាអ្វីខ្លះទៅ លោកស្រីអាចសង្ខេបនូវបញ្ហាចម្បងៗនៃខ្លឹមសារដែលគាត់និយាយនៅក្នុងកិច្ចប្រជុំថ្ងៃនោះដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបអំពីកិច្ចប្រជុំ ខ្លឹមសារដែលប្រជុំ ខ្ញុំមិនបានចាំអស់ទេ។ មិនដឹងគាត់លើកពីបញ្ហាអី ខ្ញុំក៏វាអត់ ក្តាប់អត់បានដែរ។ មិនដឹងថាលើកពីបញ្ហាអ្វីយកមកប្រជុំក្នុងអង្គប្រជុំហ្នឹង ខ្ញុំមិនបានចាំទេ។

**ស៖** ឥឡូវលោកស្រីរំឭកឡើងវិញមើល តើសេចក្តីថ្លែងការណ៍នុំងមានការពាក់ព័ន្ធជាមួយនឹងការផ្សព្វផ្សាយនូវគោលនយោបាយ ដូចជា គោលនយោបាយរបស់បក្សចំពោះអតីតមន្ត្រីរបប លន់ នល់ របបសាធារណរដ្ឋខ្មែរ ចំពោះសាសនា និង/ឬ ក៏ចំពោះវិស័យកសិកម្ម ឬក៏សហករណ៍ជាដើម។ តើមានបានលើកឡើងថ្លែងការណ៍ និយាយអំពីបញ្ហាអស់ហ្នឹងដែរឬទេ?

**ឆ៖** កាលសម័យនោះលើកគោលការណ៍ គោលការណ៍ក្រោយពីរៀនចប់យើងផ្សព្វផ្សាយអំពីការធ្វើសហករណ៍។ បានផ្សព្វផ្សាយបញ្ហាទី១។ បញ្ហាទី២ ក៏លើកគោលការណ៍អំពីបង្កើតវត្តអារាមវិញ ក្រៅពីនោះទៀត ខ្ញុំអត់ចាំ ប៉ុន្តែខ្ញុំឃើញគោលការណ៍បង្កើតសហករណ៍ គឺមានក្នុង៧៥។ បានផ្សព្វផ្សាយឲ្យប្រជាជនធ្វើ។

[១៥:៥២:០៦]

**ស៖** កុំអាលទាន់ៗឆ្លើយ! លោកស្រីអំមិញនិយាយថា មានគោលនយោបាយ និយាយពីគោលនយោបាយបង្កើតវត្តអារាម ឬក៏យ៉ាងម៉េច ឲ្យច្បាស់លាស់អំពីបញ្ហាវត្តអារាម?

**ឆ៖** កាលនុំងមានគោលការណ៍បង្កើត ទី១ ឲ្យបង្កើតសហករណ៍មុនគេ រៀបចំប្រជាជន។ ទី២ ឲ្យមានវត្តអារាម។ អាហ្នឹងតាមការបង្កើតរបស់គាត់ ឲ្យបង្កើតមុនគេ ព្រោះយើងត្រូវការសាសនាដែរ ប្រជាពលរដ្ឋយើង ព្រោះយើងមិនរំដោះទឹកដីបានហើយ គាត់និយាយអ៊ីចេះ។ អាហ្នឹងខ្ញុំចាំ តែក្រៅពីនោះ មិនដឹងជាគោលការណ៍អីទៀត ខ្ញុំវាមិនបានចាំទាំងអស់។

**ស៖** អំពីបញ្ហាសាសនាអំមិញ លោកស្រីឆ្លើយតបទៅនឹងសំណួររបស់សហមេធាវីជាតិ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីថា តើមានវត្តអារាមដែរឬទេនៅស្រុកកំពង់សៀម ដែលលោក

ស្រីបានទៅទទួលតំណែងជាលេខាស្រុកនៅពេលនោះ គឺលោកស្រីថាអត់មានទេ ពេញក្នុងរបបកម្ពុជាប្រជាធិបតេយ្យតែម្តង តាំងពីក្រោយថ្ងៃរំដោះឆ្នាំ១៩៧៥ រហូតដល់៧៩។ ហើយឥឡូវនេះ លោកស្រីនិយាយពីរឿងគោលនយោបាយរបស់ជាតិ ដែលថ្លែងដោយ ប៉ុល ពត នៅក្នុងសម័យប្រជុំដំបូងនៅទីក្រុងភ្នំពេញ ក្រោយថ្ងៃរំដោះ ១៧ មេសា ៧៥។ លោកស្រីឆ្លើយថា គោលនយោបាយរបស់បក្សហ្នឹងដែលថ្លែងដោយ ប៉ុល ពត នោះថា ឲ្យបង្កើតវត្តអារាម។ វាយ៉ាងម៉េចទៅបញ្ហានេះ? វាផ្ទុយគ្នា គោលនយោបាយឲ្យបង្កើតវត្ត ប៉ុន្តែជាក់ស្តែង គឺនៅក្នុងពេញរបបដែលលោកស្រីឆ្លើយអំមិញថា មិនមានវត្តអារាមទេ មិនមានការគោរពអីសាសនាអ្វីទេ ដែលឆ្លើយតបជាមួយនឹងសំណួររបស់ដើមបណ្តឹង -- អ៎! មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញ។ វាយ៉ាងម៉េចដែរ លោកស្រីលើកបញ្ហាដែលផ្ទុយនេះ គោលនយោបាយជាមួយនឹងការអនុវត្តជាក់ស្តែងនេះ?

[១៥:៥៤:៣៧]

**ឆ៖** ផ្ទុយនឹងការអនុវត្តជាក់ស្តែង និយាយទៅ ខ្ញុំនិយាយដូចជាមិនចាំ។ អ៊ីចឹងដល់និយាយទៅដូចជាមានការខុសត្រង់រហូត។ នេះ ខ្ញុំសូមជម្រាប។ ហ៎! ពី៧៥យើងរំដោះហើយ យើងត្រូវមានវត្តអីអ៊ីចឹង។ ដល់ក្រោយមកខ្ញុំនិយាយជាមួយមេធាវីថាអត់មានវត្ត ហើយអ៊ីចឹងខ្ញុំដូចមានការខុស និយាយទៅដូចវាអត់ច្បាស់លាស់ខ្លួនឯង ដូចថាវិលវល់ វិលវង់ដែរ។ នេះ ខ្ញុំសូមជម្រាប។ អ៊ីចឹងគោលការណ៍របស់ ប៉ុល ពត លើកថា ឲ្យមាន៧៥ យើងរំដោះហើយ គឺមានវត្តអារាម។ ហើយដល់ក្រោយមក ខ្ញុំនិយាយថា អត់មានវត្តអារាម អាហ្នឹង ព្រោះផ្ទុយគ្នាដែរ។ អ៊ីចឹងខ្ញុំដូចជាមិនច្បាស់លាស់ខ្លួនឯង។

**ស៖** អរគុណ។ ហើយចុះក្រៅពី ប៉ុល ពត អំមិញ គឺលោកស្រីនិយាយថា ប៉ុល ពត ថ្លែងនៅថ្ងៃទី០១ គឺពេញមួយថ្ងៃ ហើយការប្រជុំហ្នឹង គឺមានការប្រព្រឹត្តទៅរហូតដល់បីថ្ងៃ -- ពីរបីថ្ងៃ រហូតដល់ប្រាំថ្ងៃឯណោះ លោកស្រីមិនចងចាំច្បាស់ទេ។ ចុះត្រង់ថ្ងៃផ្សេងទៀតនុះ តើមានអ្នកណាឡើងធ្វើសេចក្តីថ្លែងការណ៍ដែរឬទេ ថ្លែងការណ៍នយោបាយ ជម្រាបជូនដល់សមាជិក សមាជិកា ដល់អង្គពិធី អង្គប្រជុំហ្នឹងទាំងមូលនោះ ដែរឬទេ?

**ឆ៖** ការប្រជុំរយៈកាលប្រាំថ្ងៃ មាន អ៊ំពត – អ៊ំប៉ុល ពត – ក្នុងហ្នឹងមានតែ សោ ភឹម មាន តាម៉ុក គាត់អ្នកថ្លែងការណ៍ជាមួយ។ គាត់បានធ្វើនៅកន្លែងចំណោមការរៀនសូត្រនេះ គឺមាន សោ ភឹម មាន តាម៉ុក។ គាត់តែជួយមតិនៅក្នុងសាលាទាំងអស់ហ្នឹង គឺគាត់ចែកពេលម៉ោងគ្នាម្តងម្នាក់ៗ។

[១៥:៥៧:០៤]

**ស៖** បាទ អរគុណ។ ហើយសូមបញ្ជាក់សាជាថ្មីម្ដងទៀតថា ចុះគោលនយោបាយផ្សេងទៀតរបស់បក្ស ដូចជាការអនុវត្តគោលនយោបាយចំពោះអតីតរបបលន់នល់ អតីតមន្ត្រីៗអ្នករដ្ឋការ និងទាហាន អតីតរបបលន់នល់ តើលោកស្រីបានឮការ សេចក្ដីថ្លែងការណ៍របស់ថ្នាក់ដឹកនាំជាន់ខ្ពស់ហ្នឹងនិយាយពាក់ព័ន្ធជាមួយនឹងការអនុវត្តគោលនយោបាយរបស់បក្សចំពោះអតីតមន្ត្រី ឬក៏ទាហាន អតីតរបបលន់ នល់ ដែរឬទេ? ហើយបើគេនិយាយដល់ តើគេនិយាយយ៉ាងម៉េចខ្លះ ពាក់ព័ន្ធជាមួយនឹងក្រុមមន្ត្រីរដ្ឋ -- អ្នករដ្ឋការ និងទាហានរបស់លន់នល់នោះ?

**ឆ៖** ខ្ញុំសូមជម្រាបអំពីគោលការណ៍របស់រដ្ឋការចាស់។ ខ្ញុំនិយាយរួម គឺអត់ទាន់បាន អត់ទាន់ដឹងដែរ និយាយរួមគឺអត់ច្បាស់ដែរបញ្ហាហ្នឹង។ មិនដឹងថាគាត់យកគោលការណ៍យ៉ាងម៉េច យកវិធានការអី ទៅដាក់លើទាហានលន់នល់ ទាហានអី ខ្ញុំអត់ច្បាស់ដែរ។ ហើយខ្ញុំអត់ចាំទៀត មិនដឹងថាធ្វើយ៉ាងម៉េច អីយ៉ាងម៉េច ខ្ញុំអត់ចាំ។

**ស៖** បាទ មិនអីទេ។ ចុះៗចំពោះគោលនយោបាយមានឮទេ ពីការថ្លែងការណ៍អំពីគោលនយោបាយរបស់បក្សកាលនោះ ចំពោះគោលដៅផ្សេងទៀត ដូចជាជនជាតិចាម ហើយនិងសាសនាអ៊ីស្លាមហ្នឹង ដែលគេបាននិយាយដល់ដែរឬទេ?

**ឆ៖** កាលហ្នឹង ដូចមិនទាន់ដល់ -- និយាយដល់ទេ ព្រោះគោលការណ៍ហ្នឹង អត់ទាន់មានផង។ តាមខ្ញុំដឹង ដូចអត់ទាន់មាន។ ចាមអី ដូចថានៅធម្មតា អត់មានអីផង អត់ទាន់មានយកគោលការណ៍អីផង។ មិនទាន់ដាក់ផែនការអីតឹងរ៉ឹង តាមខ្ញុំស្ដាប់ទៅ ដូចជាអត់ទាន់មានផែនការអីតឹងរ៉ឹងចំពោះចាមចំពោះអីហ្នឹង គឺអត់ទាន់មានទេ។ តាមខ្ញុំក្ដាប់បាន តាមខ្ញុំដឹង និយាយរួមតាមខ្ញុំដឹង មិនទាន់មានគោល-ការណ៍។

[១៦:០០:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី ប្រាក់ យុត។

សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២០ ខែមករា ឆ្នាំ ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ប្រាក់ យុត នៅពេលព្រឹក និងផ្ដើមសក្ខីកម្មសាក្សីដែលមានរហស្ស

នាម -- ដែលស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-844 ពីចម្ងាយតាមរយៈប្រព័ន្ធសោទស្សន៍។ ហើយដែលអង្គជំនុំជម្រះសាលាដំបូងក៏នឹងបម្រុងទុកនៅដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត 2-TCCP-869 សម្រាប់នៅពេលរសៀលដែរ ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ការប្រព្រឹត្តទៅលើក្រុមគោលដៅជាក់លាក់ចំពោះជនជាតិវៀតណាម។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកស្រី ប្រាក់ យុត ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកស្រីរហូតមកដល់ពេលនេះមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឱ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះកោះសូមអញ្ជើញលោកមកចូលរួមប្រឹក្សាសាក្សីរូបនេះ បន្តដែលធ្វើឡើងនៅថ្ងៃព្រឹកថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី ប្រាក់ យុត វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងសូមអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកវិញដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោកជនជាប់ចោទ ខៀវ សំផន និង នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកវិញឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២នាទី)*